# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale De Droit Et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការបង្កើត និងការរំលាយកិច្ចសន្យា

ស្រាវជ្រាវពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០ ដល់ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ឃូ ស្រ៊ុនប៉ាវ**

**ម៉ិច រី**

សាស្ត្រាចារ្យណែនាំ

លោក **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០១៦

ជំនាន់ទី **២០**

ឆ្នាំសរសេរសារណា ២០២០

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រអស់រយៈពេលបួនឆ្នាំមកនេះ ឃើញថាមានទាំងភាពសប្បាយរីករាយ និងកើតទុកបានលាយឡំចូលគ្នា ហើយជាពិសេសមានមុខវិជ្ជារៀនក៏ច្រើនពីមួយឆ្នាំទៅមួយឆ្នាំ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ពួកយើងសប្បាយរីករាយ និងទទួលយកដើម្បីទទួលបានចំណេះដឹងថ្មីៗ។ ក្នុងចំណោមមុខវិជ្ជាទាំងអស់ដែលកម្មវិធីសាលាបានដាក់ឱ្យពួកយើងធ្វើការសិក្សា គឺក្រុមយើងខ្ញុំពេញចិត្តទៅលើផ្នែករដ្ឋប្បវេណីជាខ្លាំង។

ដោយមើលឃើញថា នៅក្នុងសង្គមរស់នៅនាពេលបច្ចុប្បន្ន ការទំនាក់ទំនងរវាងបុគ្គលឯកជន និងបុគ្គលឯកជន ក៏ដូចជាក្រុមហ៊ុនមានសារៈសំខាន់ និងមានភាពចាំបាច់ក្នុងការវិនិយោគ ក៏ដូចជាតម្រូវការក្នុងការរស់នៅ។ យ៉ាងណាមិញ ការទំនាក់ទំនងទាំងនោះប្រាកដណាស់នឹងនាំឱ្យមាននូវចំណងទាក់ទងគតិយុត្តរវាងគូភាគី ហើយចាំបាច់ណាស់ក្នុងការតម្រូវឱ្យមានកិច្ចសន្យា។ នៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងផងដែរនូវប្រភេទនៃកិច្ចសន្យាជាច្រើន ដែលមានការប្រើប្រាស់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា។ ហេតុដូច្នេះ ទើបធ្វើឱ្យក្រុមរបស់យើងខ្ញុំធ្វើការជ្រើសរើសនូវប្រធានបទមួយស្ដីពី “ **ការបង្កើតកិច្ចសន្យា និងការរំលាយកិច្ចសន្យា** ”។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ពួកខ្ញុំបាទបានខិតខំរកឯកសារ និងធ្វើការស្វែងយល់អំពីប្រធានបទមួយនេះ រហូតដល់ពួកយើងទទួលបាននៅភាពជោគជ័យនៅសារណាមួយនេះ។ នៅក្នុងស្នាដៃនេះបានសរសេររៀបរាប់ពីការប្រាស្រ័យទាក់ទងគ្នា ការបង្កើតកិច្ចសន្យា តួនាទី កាតព្វកិច្ច ការទទួលខុសត្រូវរបស់គូភាគី និងការរំលាយកិច្ចសន្យាទៅវិញ។ យើងខ្ញុំសង្ឃឹមថាស្នាដៃ នៃការសិក្សាស្រាវជ្រាវនូវសារណាមួយនេះ និងផ្តល់ជាឯកសារដែលបានអត្ថប្រយោជន៍ និងចូលរួមផ្តល់នៅចំណេះដឹងផ្នែកច្បាប់ទៅដល់ប្រជាពលរដ្ឋ សិស្សនិស្សិត និងអ្នកស្រាវជ្រាវជំនាន់ក្រោយ ដើម្បីចូលរួមលើកស្ទួយវិស័យគតិយុត្តិធម៌ វិស័យឯកជនក៏ដូចជាវិស័យផ្សេងៗ និងជាពិសេសជួយឱ្យនីតិរដ្ឋនៅកម្ពុជាកាន់តែរីកចម្រើន។

ទន្ទឹមនឹងនេះផងដែរ យើងខ្ញុំក៏សូមខន្តីអភ័យទោសទុកជាមុននៅរាល់កំហុសឆ្គាំឆ្គង ដែលកើតមានឡើងដោយអចេតនា ពីព្រោះថានៅក្នុងការសិក្សាស្រាវជ្រាវតែងតែ មាននូវចំណុចខ្វះខាតមួយចំនួនជាក់ជាមិនខាន គ្រាន់តែកំហុសមានតិច ឬច្រើនប៉ុណ្ណោះ ទាំងអក្ខរាវិរុទ្ធក្តី ទាំងពាក្យពេចន៍ និងទាំងអត្ថន័យក្តី។ ដូច្នេះហើយ យើងខ្ញុំរង់ចាំជានិច្ចនូវ រាល់មតិរិះគន់ដើម្បីស្ថាបនាដោយសេចក្ដីរីករាយពី សំណាក់លោកសាស្ត្រាចារ្យ ក៏ដូចជាមិត្តអ្នកអានទាំងអស់ដែលនឹងកំពុងបានអាននូវសារណារបស់យើងខ្ញុំ។

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **ម៉ិច រី** និង ខ្ញុំបាទឈ្មោះ **ឃូ ស្រ៊ុនប៉ាវ** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកឪពុក និងអ្នកម្តាយ** ជាទីគោរពស្រឡាញ់ ដឹងគុណរបស់កូន ដែលលោកទាំងពីរមានគុណធំធេងបំផុត ពុំមានអ្វីមកប្រៀបផ្ទឹមបានឡើយ ចាប់តាំងពីកូនបានចាប់កំណើតក្នុងផ្ទៃអ្នកម្តាយ រហូតបានប្រសូតមក លោកឪពុក-អ្នកម្តាយ តែងតែយកចិត្តទុកដាក់ ចិញ្ចឹមបីបាច់ ស្រឡាញ់ថ្នាក់ថ្នម ប្រៀនប្រដៅធ្វើយ៉ាងណាបណ្តុះផ្នត់គំនិតឱ្យកូនក្លាយជាកូនល្អ ពលរដ្ឋល្អនៅក្នុងសង្គម។ លុះកូនឈានដល់វ័យចូលសាលាត្រូវសិក្សា លោកទាំងពីរមិនដែលរុញរា ឬមួយបង្អាក់បង្ខានកូនមិនឱ្យចូលរៀនទេ មានតែបង្ខំ ជម្រុញកូនឱ្យទៅរៀន និងឱ្យកូនចូលរៀន ដោយចង់ឱ្យកូនមានចំណេះដឹង។ បន្ទាប់ពីបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ទោះបីជាគ្រួសារមានជីវភាពមិនសូវ ធូធារ និងមិនសូវល្អប្រសើរដូចគេយ៉ាងណាក្តី ក៏លោកនៅតែផ្តល់ឱកាស ជំរុញនិងលើកទឹកចិត្តកូនជានិច្ច ព្រមទាំងឧបត្ថម្ភទាំងសម្ភារៈ ថវិកា យានជំនិះ នឹងទឹកចិត្តដ៏ថ្លៃថ្លារបស់លោកទាំងពីរដើម្បីឱ្យកូនបានបន្តការសិក្សាដល់ថ្នាក់ឧត្តមរហូតមកដល់ពេលនេះ ដែលជារយៈ ពេលចុងក្រោយ ក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់កូន។

យើងខ្ញុំសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់គោរពជូន **ឯកឧត្តម លុយ ចណ្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដោយលោកយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងយ៉ាងម៉ត់ចត់ ធ្វើយ៉ាងណាឱ្យសាកលវិទ្យាល័យមួយនេះ មានការរីកចម្រើន និងអភិវឌ្ឍន៍ ប្រកបដោយនិរន្តរភាព។ ហើយសូមគោរពអរគុណដល់ **លោកគ្រូ អ្នកគ្រូ** ដែលជាសាស្រ្តាចារ្យ ដែលបានយកចិត្តទុកដាក់ ក្នុងការបង្រៀន ចែករំលែកនូវបទពិសោធន៍ និងដំបូន្មានល្អៗ ចាប់តាំងពីថ្នាក់មូលដ្ឋាននៃការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត រហូតដល់បញ្ចប់ នៃការសិក្សាឆ្នាំទី ៤នេះ។

ជាពិសេស សូមថ្លែងអំណរគុណដល់ លោកសាស្រ្តាចារ្យ **ទេព សុខ** ដែលបានចំណាយពេលដ៏មានតម្លៃ ក្នុងការបង្ហាត់បង្ហាញ ណែនាំ ដល់យើងខ្ញុំ ចំពោះការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្តរហូតដល់ទទួលបានជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំ សូមលើកហត្ថាប្រណម បួងសួង ដល់វត្ថុសក្តិសិទ្ធិ ទេព្តា ក្នុងលោកសូមប្រសិទ្ធិពរជ័យសិរីសួស្តីជូនចំពោះ **លោកឪពុក អ្នកម្តាយ ឯកឧត្តម សាកលវិទ្យាធិការ សាស្រ្តាចារ្យលោកគ្រូ អ្នកគ្រូ បងប្អូន មិត្តភក្តិ** សូមជួបប្រទះតែសេចក្តីសុខសប្បាយ សុខភាពល្អ ជោគជ័យគ្រប់ភារកិច្ច ព្រមទាំងជួបប្រទះតែពុទ្ធពរទាំងឡាយ ៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ** និង**ពលៈ**កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

## សេចក្តីផ្តើម

ទំព័រ

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ២

៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ២

## ជំពូកទី ១

## ទិដ្ឋភាពទូទៅនៃកិច្ចសន្យា

**១.១ ចំណាត់ថ្នាក់នៃកិច្ចសន្យា** ........ ៤

១.១.១. កិច្ចសន្យាដែលយកតម្លៃថ្នូរ និង កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ ........ ៤

១.១.២. កិច្ចសន្យាទ្វេភាគី / កិច្ចសន្យាឯកតោភាគី ........ ៤

១.១.៣. កិច្ចសន្យាមានឈ្មោះ / កិច្ចសន្យាគ្មានឈ្មោះ ........ ៤

១.១.៤. កិច្ចសន្យាត្រឹមការព្រមព្រៀង / កិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ / កិច្ចសន្យាជាលក្ខណៈទម្រង់ ........ ៥

១.១.៥. កិច្ចសន្យាអនុវត្តម្តង / កិច្ចសន្យាអនុវត្តបន្តបន្ទាប់ ........ ៥

**១.២. លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃកិច្ចសន្យា** ........ ៥

១.២.១. លក្ខខណ្ឌទូទៅទាក់ទងនឹងភាគី ........ ៦

១.២.២. លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារ ........ ៧

## ជំពូកទី ២

## ការបង្កើតកិច្ចសន្យា

**២.១. សំណើ** ........ ៩

**២.២. ស្វីការ** ........ ៩

**២.៣. សំណើមាន ឬ គ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ**.................................. ១០

២.៣.១. សំណើមានការកំណត់អំឡុងពេលសម្រាប់ស្ទីការ.................................................. ១០

២.៣.២. សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ.............................................. ១០

**២.៤. អានុភាពនៃកិច្ចសន្យាទ្វេភាគី**....................................................................... ១១

២.៤.១. លក្ខណៈទៅវិញទៅមកក្នុងការបង្កើតកិច្ចសន្យាទ្វេភាគី ៖ អលទ្ធភាពតាំងពីដំបូង........ ១១

២.៤.២. លក្ខណៈ " ទៅវិញទៅមក " នៅក្នុងការអនុវត្តកិច្ចសន្យាទ្វេភាគី ............................... ១២

២.៤.៣. លក្ខណៈទៅវិញទៅមក នៅក្នុងអត្ថិភាពដែលត្រូវបានបន្ត ....................................... ១៧

## ជំពូកទី ៣

## ការរំលាយកិច្ចសន្យា

**៣.១. ប្រភពនៃការរំលាយកិច្ចសន្យា** ........................................................................ ២០

៣.១.១. សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់ដោយនៅក្នុងច្បាប់ .................................... ២០

៣.១.២. សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងកិច្ចសន្យា ........................................ ២០

៣.១.៣. សិទ្ធិរំលាយកិច្ចសន្យា ដោយផ្អែកលើបញ្ញត្តិពិសេស.............................................. ២០

**៣.២. ប្រព័ន្ធប្រហាក់ប្រហែល ទៅនឹងការរំលាយកិច្ចសន្យា** ................................... ២០

៣.២.១. ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង ........................................................... ២១

៣.២.២. ការលុបចោលកិច្ចសន្យា.................................................................................. ២១

**៣.៣. លក្ខខណ្ឌ និងវិធីអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យា**.................................... ២១

៣.៣.១. លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ..................................................................... ២១

៣.៣.២. វិធីអនុវត្តរំលាយកិច្ចសន្យា ............................................................................. ២៥

**៣.៤. អានុភាព និងការរលត់នូវសិទ្ធិនៃការរំលាយកិច្ចសន្យា**................................... ២៦

៣.៤.១. ទ្រឹស្តីអានុភាពនៃការរំលាយកិច្ចសន្យា................................................................ ២៦

៣.៤.២. អានុភាពប្រតិសកម្ម ....................................................................................... ២៨

៣.៤.៣. អានុភាពមិនប្រតិសកម្ម.................................................................................. ២៩

៣.៤.៤. អានុភាពចំពោះភាគី ....................................................................................... ២៩

៣.៤.៥. អានុភាពចំពោះតតិយជន....................................................................................................៣២

៣.៤.៦. ការរំលាយកិច្ចសន្យា និងតតិយជន ......................................................................................៣៤

**៣.៥.. ការរំលត់នូវសិទ្ធិរំលាយកិច្ចសន្យា**.........................................................................................៣៤

៣.៥.១. នៅក្នុងករណីដែលការខូចខាត ជាអាទិ៍ នៃកម្មវត្ថុនៃកិច្ចសន្យា កើតឡើងដោយចេតនា.៣៤

៣.៥.២. ការរលត់ដោយសារអាជ្ញាយុកាល..........................................................................................៣៥

៣.៥.៣. ការរំលត់ដោយសារអនុវត្តកាតព្វកិច្ច ឬដោយសារសំណើរផ្តល់ការអនុវត្តកាតព្វកិច្ច.....៣៥

**សេចក្តីសន្និដាន និង អនុសាសន៍** ..........................................................................................៣៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ជាការពិតណាស់ សម្រាប់ការរស់នៅក្នុងសង្គមគឺត្រូវតែមានទំនាក់ទំនង ឬការប្រាស្រ័យទាក់ទងចំពោះគ្នាទៅវិញទៅមក ដែលនេះ ជាកត្តាចម្បងមិនអាចខ្វះបាន សម្រាប់ការរស់នៅរបស់បុគ្គលគ្រប់ៗរូប ហើយក៏គ្មាននរណាម្នាក់អាចរស់នៅដោយឯកាបាននោះដែរ ដាច់ខាតត្រូវតែមានការពឹងពាក់រវាងគ្នានឹងគ្នាជានិច្ច។ ជាក់ស្តែងបើយើងសង្កេតមើលទៅលើការរស់នៅរបស់ប្រជាពលរដ្ឋសព្វថ្ងៃវិញ ឃើញថាពិតជាមានភាពចាំបាច់ណាស់ក្នុងការបង្កើតនូវទំនាក់ទំនងទាំងនេះ ដែលការប្រាស្រ័យទាក់ទងគ្នានេះ គឺក្នុងគោលបំណងទទួលបាននូវផលប្រយោជន៍ទៅតាមអ្វីដែលខ្លួនចង់បាន ជាពិសេសនៅក្នុងវិស័យពាណិជ្ជកម្មដែលកំពុងតែមានសកម្មភាពសន្ទុះយ៉ាងខ្លាំង។ ទន្ទឹមនឹងនេះផងដែរ ដើម្បីឱ្យមានភាពជាក់ច្បាស់រវាងគ្នានឹងគ្នា គឺតម្រូវឱ្យមានភាពជឿជាក់ និងស្មោះត្រង់រវាងគ្នានឹងគ្នាផងដែរ ទើបមិនធ្វើឱ្យមានការខូចខាតប្រយោជន៍ចំពោះគ្នាទៅវិញទៅមក ។

កាលណាយើងនិយាយអំពីកិច្ចសន្យា យើងរមែងគិតថាកិច្ចសន្យាដែលពាក់ព័ន្ធទៅនឹងកាតព្វកិច្ចដែលកើតចេញពីសកម្មភាពនានារបស់បុគ្គលម្នាក់ៗ។ ក្នុងជីវភាពប្រចាំថ្ងៃស្ទើរតែគ្រប់សកម្មភាពរបស់បុគ្គលម្នាក់ៗតែងតែបង្កើតឱ្យមានកាតព្វកិច្ចដែលកាតព្វកិច្ចនោះ អាចកើតចេញពីព្រឹត្តិការណ៍គតិយុត្តិ ឬកិច្ចគតិយុត្តិ។ ការស្រាវជ្រាវអំពីការបង្កើត និងការរំលាយកិច្ចសន្យានៅពេលនេះ គឺជាការសិក្សាស្រាវជ្រាវផ្តោតទៅលើកិច្ចសន្យាទូទៅដែលផ្ទុកនូវធាតុកាតព្វកិច្ច និងគោលគារណ៍គ្រឹះនៃកិច្ចសន្យាទូទៅ ក្នុងវត្ថុបំណងស្វែងយល់អំពីទិដ្ឋភាពច្បាប់ផង និងទិដ្ឋភាពសង្គមផង។ វត្ថុបំណងនេះដើរតួយ៉ាងសំខាន់ដោយផ្តោតលើ ទស្សនទានជាមូលដ្ឋានគ្រឹះនៃវិទ្យាសាស្ត្រគតិយុត្ត ដែលពាក់ព័ន្ធនិងការបង្កើតកិច្ចសន្យាតាមប្រភេទនីមួយៗ។ ក្នុងការអនុវត្តជាញឹកញាប់ក្នុងជីវភាពប្រចាំថ្ងៃមនុស្សម្នាក់ៗតែងតែជួបប្រទះនិងការធ្វើកិច្ចសន្យា ព្រមទាំងមានការជួបនៅបញ្ហានៃការទទួលខុសត្រូវដែលពាក់ព័ន្ធនឹងចំណងគតិយុត្ត ជាកាតព្វកិច្ចដែលកើតចេញពីការបង្កើតកិច្ចគតិយុត្តទាំងនោះ ដោយឈរលើគោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យាដែលមានចែងក្នុងច្បាប់ដោយប្រកាន់នូវគោលការណ៍សុចរិត និងស្មោះត្រង់លើការប្រើសិទ្ធិ និងការអនុវត្តករណីកិច្ច របស់ខ្លួនដើម្បីបង្កើនទំនុកចិត្តដល់ភាគីពាក់ព័ន្ធ។

ក្នុងករណីនេះ ដើម្បីធានាឱ្យបាននូវគោលការណ៍នៃភាពស្មោះត្រង់ និងភាពសុចរិតចំពោះគ្នានឹងគ្នា ទៅវិញទៅមក គឺបុគ្គលបានរួមគ្នាបង្កើតនូវកិច្ចសន្យាសម្រាប់ចងនូវកាតព្វកិច្ចរវាងគូភាគីពីរ ឬក៏ពហុភាគីដើម្បីកុំឱ្យមានភាពផុយស្រួយ និងងាយបាត់បង់នូវផលប្រយោជន៍ទាំងនោះជាពិសេស គឺផ្នែកសេដ្ឋកិច្ច(ប្រាក់កាស) តែម្តង។ រាល់ការបង្កើតនូវកិច្ចសន្យា គឺមានលក្ខណៈមិនចាប់បង្ខំភាគីអនុវត្តនោះទេ ពោលគឺមានការព្រមព្រៀងគ្នាជាមុនសិនអំពីកាតព្វកិច្ច និងលក្ខន្តិកៈដែលមានចែងនៅក្នុងកិច្ចសន្យានោះ ទើបអាចមានការកកើតនូវកិច្ចសន្យាមួយបាន។ ប៉ុន្តែទោះបីជា មានការព្រមព្រៀងគ្នារវាងគ្នានឹងគ្នារួចរាល់ហើយក៏ដោយ តែអ្វីដែលសំខាន់ គឺការអនុវត្តកាតព្វកិច្ចរបស់គូភាគីនៃកិច្ចសន្យា ត្រូវប្រាដកថាតើមានប្រសិទ្ធិភាពដែរឬទេ? ពីព្រោះមានករណីមួយចំនួនដែលកំពុងតែមានភាពចម្រូងចម្រាស់សម្រាប់គូភាគី នៅពេលដែលកំពុងតែអនុវត្តពោលគឺ កិច្ចសន្យាដែលបានបង្កើតរួចរាល់ហើយ បែរជាត្រូវរលត់កាតព្វកិច្ចទៅវិញដោយសារ តែគូភាគីបានបំពេញនូវកាតព្វកិច្ចរួចរាល់ ឬមួយដោយសារតែកំហុសរបស់ភាគីណាមួយនៅក្នុងកិច្ចសន្យា នេះគឺជាមូលហេតុដែលនាំឱ្យភាគីម្ខាងទៀតត្រូវបានបាត់បង់ផលប្រយោជន៍។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តើការបង្កើតកិច្ចសន្យា និងការរំលាយកិច្ចសន្យាមានន័យដូចម្ដេច? ចូរនិយាយអំពីនីតិវិធីដែលនាំឱ្យមានការបង្កើតកិច្ចសន្យា និងនីតិវិធីនៃការរំលាយកិច្ចសន្យា? តើនៅពេលដែលបង្កើតកិច្ចសន្យាឡើង ភាគីនីមួយៗទទួលបានសិទ្ធិ និងកាតព្វកិច្ចអ្វីខ្លះ ហើយវាបានផ្ដល់សារៈសំខាន់អ្វីដល់គូភាគី? តើការរំលាយកិច្ចសន្យាដោយសារកត្តាអ្វីខ្លះ? តើការរំលាយកិច្ចសន្យាវាមានអានុភាពចំពោះគូភាគី ដូចម្ដេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងដែលយើងខ្ញុំទាំងពីរនាក់បានជ្រើសរើសនូវប្រធានបទនេះ គឺចង់ស្វែងយល់ឱ្យកាន់តែ ស៊ីជម្រៅនៃការបង្កើតកិច្ចសន្យា និងការរំលាយកិច្ចសន្យា។ ការបង្កើតកិច្ចសន្យាត្រូវតែគោរពទៅលើលក្ខខណ្ឌ ហើយកិច្ចសន្យាដែលបានបង្កើតឡើងវាបានធ្វើឱ្យគូភាគីទទួលបានសិទ្ធិ និងកាតព្វកិច្ចនៅពេលដែលបង្កើតកិច្ចសន្យានោះឡើង។ ហើយសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីនោះ នឹងត្រូវបានរលត់ទៅវិញដោយសារមូលហេតុនៃការរំលាយកិច្ចសន្យាដែលបានបង្កើតឡើងនោះ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនេះ គឺទាក់ទងនឹងរឿងរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងការបង្កើតកិច្ចសន្យា នឹងការរំលាយកិច្ចសន្យាដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ជាធរមាន ហេតុដូច្នេះ យើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវផ្ដោតទៅលើច្បាប់សារជាតុតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវជ្រាវ គឺចង់ឱ្យអ្នកសិក្សានៅគ្រប់មជ្ឈដ្ឋានបានសិក្សាស្វែងយល់ពីការបង្កើត កិច្ចសន្យា និងការរំលាយកិច្ចសន្យា និងដើម្បីទុកជាឯកសារសម្រាប់អ្នកជំនាន់ក្រោយក្នុងការសិក្សាស្វែងយល់ និងជាពិសេសធ្វើឱ្យយើងជាអ្នកដែលតាក់តែងនូវសារណានេះឡើង ឱ្យមានភាពកាន់តែច្បាស់ក្នុងបង្កើតកិច្ចសន្យា និងការរំលាយកិច្ចសន្យានោះទៅវិញ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទនៃ ការបង្កើតកិច្ចសន្យា និងការរំលាយកិច្ចសន្យា យើងសិក្សាទៅលើ ៣ ជំពូកៈ

**ជំពូកទី ១ វិធានទូទៅនៃការបង្កើតកិច្ចសន្យា**

**១.១ ចំណាត់ថ្នាក់នៃកិច្ចសន្យា**

**១.២ លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃកិច្ចសន្យា**

**ជំពូកទី ២ ការបង្កើតកិច្ចសន្យា**

**២. គោលការណ៍នៃការបង្កើតកិច្ចសន្យា**

**២.១ សំណើ**

**២.២ ស្វីការ**

**២.៣ សំណើមាន ឬ គ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ**

**២.៤ អានុភាពនៃកិច្ចសន្យាទ្វេភាគី**

**ជំពូកទី ៣ ការរំលាយកិច្ចសន្យា**

**៣.១ ប្រភពនៃការរំលាយកិច្ចសន្យា**

**៣.២ ប្រព័ន្ធប្រហាក់ប្រហែល ទៅនឹងការរំលាយកិច្ចសន្យា**

**៣.៣ លក្ខខណ្ឌ និងវិធីអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យា**

**៣.៤ អានុភាព និងការរលត់នូវសិទ្ធិនៃការរំលាយកិច្ចសន្យា**

**៣.៥ ការរំលត់នូវសិទ្ធិរំលាយកិច្ចសន្យា**

ដូច្នេះយើងនឹងសិក្សាលម្អិតទាំង ៣ ជំពូកខាងលើឱ្យបានស៊ីជម្រៅនៅទំព័រខាងមុខបន្តបន្ទាប់ទៀត។

# ជំពូកទី ១
# វិធានទូទៅនៃកិច្ចសន្យា

## ១.១ ចំណាត់ថ្នាក់នៃកិច្ចសន្យា

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់ មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវសិទ្ធិ និងកាតព្វកិច្ច។[1] កិច្ចសន្យា ជាប្រភពមួយនៃការបង្កើតឱ្យមានកាតព្វកិច្ច ដែលជាចំណងគតិយុត្តិចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់ មានករណីកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។

### ១.១.១. កិច្ចសន្យាដែលយកតម្លៃថ្នូរ និង កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ

1. **កិច្ចសន្យាដែលយកតម្លៃថ្នូរ** ៖ ភាគីទាំងពីរមានកាតព្វកិច្ចផ្តល់នូវកម្រៃទៅវិញទៅមកដែលមានតម្លៃស្មើគ្នា។ **ឧទាហរណ៍:** កិច្ចសន្យាលក់ទិញ ភាគីអ្នកកលក់ មានកាតព្វកិច្ចប្រគល់វត្ថុ រីឯអ្នកទិញ មានកាតព្វកិច្ចប្រគល់ប្រាក់។
2. **កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ** ៖ កិច្ចសន្យានេះ មានន័យថា មានតែភាគីម្ខាង ផ្តល់នូវកម្រៃ ចំណែកឯភាគីម្ខាងទៀត មិនមានកាតព្វកិច្ច ឬ មានបន្ទុកដែលមិនសមមូល។ **ឧទាហរណ៍** ដ៏សាមញ្ញនៃកិច្ចសន្យានេះ គឺភាគច្រើនជាប្រទានកម្ម។ ទាក់ទងនឹងកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ នៅក្នុងករណីនៃប្រទានកម្ម គឺវាមានលក្ខណៈបន្ធូរបន្ថយចំពោះកាតព្វកិច្ចរបស់ទាយក។ វាមានន័យថា ជាគោលការណ៍ទាយក មិនចាំបាច់ទទួលខុសត្រូវចំពោះវិការៈ ដែលបានកើតមានឡើងដោយសារកិច្ចសន្យានេះទេ។[2]

### ១.១.២. កិច្ចសន្យាទ្វេភាគី / កិច្ចសន្យាឯកតោភាគី

1. កិច្ចសន្យាទ្វេភាគី ៖ ភាគីទាំងពីរមានកាតព្វកិច្ចអនុវត្តកិច្ចសន្យាដែលមានតម្លៃសមមូលគ្នា។
2. កិច្ចសន្យាឯកតោភាគី ៖ មានតែភាគីម្ខាងមានកាតព្វកិច្ច ចំណែកឯភាគីម្ខាងមិនមានកាតព្វកិច្ច ឬគ្រាន់តែមានបន្ទុក តែមានតម្លៃមិនសមមូល។ ប្រសិនបើភាគីម្ខាងទៀតមានបន្ទុក ប៉ុន្តែមានតម្លៃមិនសមមូល ក្រមរដ្ឋប្បវេណី បានចែងនូវមាត្រាដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងកិច្ចសន្យាទ្វេភាគីដែរ ដូចជា ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់ ការតវ៉ាអោយអនុវត្តព្រមគ្នា ការរំលាយកិច្ចសន្យា។[3] **ឧទាហរណ៍៖ ក** បានធ្វើប្រទានកម្មថា នឹងប្រគល់ផ្ទះទៅអោយ **ខ** តែ **ខ** ត្រូវអោយកូនរបស់ **ក** រស់នៅលើផ្ទះមួយផ្នែកដែរ។ នៅក្នុងករណីនេះ **ខ** មានបន្ទុកក្នុងការអនុញ្ញាតអោយកូនរបស់ **ក** ប្រើប្រាស់ផ្នែកមួយនៃផ្ទះនោះ ប៉ុន្តែ វាមិនសមមូលទៅនឹងកាតព្វកិច្ចរបស់ **ក**។ ទន្ទឹមនឹងនេះ កិច្ចសន្យានេះ គឺជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ។

### ១.១.៣. កិច្ចសន្យាមានឈ្មោះ / កិច្ចសន្យាគ្មានឈ្មោះ

1. កិច្ចសន្យាមានឈ្មោះ ជាកិច្ចសន្យានីមួយៗដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី។

**ឧទាហរណ៍:** កិច្ចសន្យាលក់ទិញ, កិច្ចសន្យាម៉ៅការ, កិច្ចសន្យាជួលជាដើម។

---

[1] មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី ២០០៧

[2] មាត្រា ៥៧៤ នៃក្រមរដ្ឋប្បវេណី ២០០៧

[3] មាត្រា ៥៧៦ កថាខណ្ឌទី ២.៣និង ៥នៃក្រមរដ្ឋប្បវេណី

2. កិច្ចសន្យាគ្មានឈ្មោះ កិច្ចសន្យាប្រភេទនេះ មិនមានចែងក្នុងក្រមរដ្ឋប្បវេណី។ កិច្ចសន្យាប្រភេទនេះ ត្រូវបានបង្កើតឡើងដោយកិច្ចសន្យាជាច្រើនរួមបញ្ចូលគ្នាតែមួយ ដូចជាការរួមបញ្ចូលគ្នានៃកិច្ចសន្យាគ្មានឈ្មោះ និងកិច្ចសន្យាគ្មានឈ្មោះ ឬ កិច្ចសន្យាមានឈ្មោះ និងកិច្ចសន្យាគ្មានឈ្មោះ។ ដូច្នេះគេ មិនអាចកំណត់ច្បាស់ពីប្រភេទនៃកិច្ចសន្យានេះ។ នៅពេលដែលធ្វើការបកស្រាយនូវកិច្ចសន្យាគ្មានឈ្មោះ វាមានលក្ខណៈសំខាន់ណាស់ក្នុងការធ្វើអោយមានភាពច្បាស់លាស់នូវអ្វីដែលជាឆន្ទៈពិតប្រាកដរបស់ភាគី ។

**ឧទាហរណ៍:** កិច្ចសន្យារវាងជាងកាត់ដេរសំលៀកបំពាក់ និងអតិថិជនដែលបានចែងថាជាងកាត់ដេរសំលៀកបំពាក់ ត្រូវផ្តល់នូវក្រណាត់។ យើងអាចឃើញថាកិច្ចសន្យានេះ មិនមានចែងពីប្រភេទ នៃកិច្ចសន្យាច្បាស់ទេ ព្រោះកិច្ចសន្យានេះ កើតឡើងដោយកិច្ចសន្យាពីរបញ្ចូលគ្នាគឺ:

**ក. កិច្ចសន្យាម៉ៅការ** ៖ ជាងកាត់សំលៀកបំពាក់ មានកាតព្វកិច្ចសម្រេចការងាររបស់ខ្លួន និងប្រគល់សំលៀកបំពាក់នោះ ចំណែកឯ អតិថិជនត្រូវបង់ប្រាក់កម្រៃ។

**ខ. កិច្ចសន្យាលក់ទិញ** ៖ អតិថិជន ត្រូវបង់ប្រាក់កម្រៃ។

### ១.១.៤. កិច្ចសន្យាត្រឹមការព្រមព្រៀង / កិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ / កិច្ចសន្យាជាលក្ខណៈទម្រង់

1. **កិច្ចសន្យាព្រមព្រៀង** ៖ ជាទូទៅកិច្ចសន្យាមួយ មានសុពលភាពនៅពេលសំណើរ និងស្នីការត្រូវគ្នា។[4]
2. **កិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ**៖ កិច្ចសន្យានេះ មានសុពលភាពនៅពេលប្រគល់វត្ថុ។

**ឧទាហរណ៍:** កិច្ចសន្យាខ្ចីប្រើ [5]

3. **កិច្ចសន្យាជាលក្ខណៈទម្រង់**៖ វាសំដៅទៅលើកិច្ចសន្យា ដែលមានសុពលភាពដោយផ្អែកទៅលើទម្រង់ជាក់លាក់ជាកំណត់។ **ឧទាហរណ៍:** ការផ្ទេរលទ្ធកម្មលើកម្មសិទ្ធិ តាមរយៈកិច្ចសន្យាមានសុពលភាពលុះត្រាធ្វើជាលិខិតយថាភូត។[6]

### ១.១.៥. កិច្ចសន្យាអនុវត្តម្តង / កិច្ចសន្យាអនុវត្តបន្តបន្ទាប់

1. កិច្ចសន្យាអនុវត្តម្តង គឺជាកិច្ចសន្យាដែលអនុវត្តតែម្តង គឺត្រូវបានបញ្ចប់តែម្តង។ **ឧទាហរណ៍:** កិច្ចសន្យាលក់ទិញត្រូវបញ្ចប់ ជាទូទៅនៅពេលដែលអ្នកលក់ប្រគល់ទំនិញ រីឯអ្នកទិញប្រគល់ប្រាក់។
2. កិច្ចសន្យាអនុវត្តបន្តបន្ទាប់ គឺជាកិច្ចសន្យាដែលការអនុវត្តកាតព្វកិច្ចត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលវែង វាមានន័យថា យើងអាចពន្លាការអនុវត្តបាន។ **ឧទាហរណ៍:** កិច្ចសន្យាជួល. កិច្ចសន្យាអាណត្តិ គឺជាកិច្ចសន្យាអនុវត្តបន្តបន្ទាប់។

## ១.២. លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃកិច្ចសន្យា

កិច្ចសន្យា មានអានុភាពនៅពេលដែលសំណើ និងស្នីការត្រូវគ្នា។ [7] ប៉ុន្តែនៅក្នុងករណីដែលការបង្ហាញឆន្ទៈមានវិការៈ ឬខ្លឹមសារនៃសកម្មភាព [8] នេះផ្ទុយនឹងច្បាប់ ឬភាពត្រឹមត្រូវនៅក្នុងសង្គម នោះអានុភាពនឹងត្រូវ

[4] មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី ២០០៧

[5] មាត្រា ៦២៦ នៃក្រមរដ្ឋប្បវេណី ២០០៧

[6] មាត្រា ៣៣៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ២០០៧

បានបដិសេធដោយក្រមរដ្ឋប្បវេណី។ ដូចនេះ ដើម្បីឱ្យកិច្ចសន្យាមួយមានសុពលភាព និងកិច្ចសន្យានោះត្រូវបំពេញនូវលក្ខខណ្ឌចាំបាច់ គឺសំណើ នឹងស្វីការត្រូវគ្នា និងលក្ខខណ្ឌគ្រប់គ្រាន់គឺ លក្ខខណ្ឌទូទៅទាក់ទងនឹងភាគី (១.២.១) និង លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារ (១.២.២)។

### ១.២.១. លក្ខខណ្ឌទូទៅទាក់ទងនឹងភាគី

លក្ខខណ្ឌទូទៅទាក់ទងនឹងភាគីដើម្បីឱ្យកិច្ចសន្យាមានសុពលភាព គឺភាគីត្រូវមានសមត្ថភាពទទួលសិទ្ធិ ត្រូវមានសមត្ថភាពខាងឆន្ទៈ ត្រូវមានសមត្ថភាពក្នុងការធ្វើសកម្មភាព និងគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ។ ការកម្រិតលក្ខខណ្ឌបែបនេះ ក្នុងគោលបំណងដើម្បីការពារកុំឱ្យមានការខូចខាតដល់កិច្ចការជំនួញរបស់ជនទាំងឡាយដែលខ្វះសមត្ថភាពដូចបានកំណត់ខាងលើ។

**ក. ភាគីត្រូវមានសមត្ថភាពទទួលបានសិទ្ធិ**

សំដៅទៅលើស្ថានភាពជាក់លាក់របស់រូបវន្តបុគ្គលម្នាក់ៗដែលភាគី ក្នុងការទទួលបាននូវសិទ្ធិ ដូចជាសិទ្ធិក្នុងការបង្កើតកិច្ចសន្យា សិទ្ធិទទួលបានមរតក សិទ្ធិទាមទារសំណងខូចខាតជាដើម។ ជាគោលការណ៍ រូបវន្តបុគ្គលគ្រប់រូប មានសមត្ថភាពទទួលបាននូវសិទ្ធិបុគ្គល ដូចៗគ្នា មិនថាជនជាតិខ្មែរ ឬបរទេសឡើយ។ ប៉ុន្តែជនជាតិបរទេសមិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធិមួយចំនួន ដែលត្រូវបានកំណត់ឡើយ ក្នុងករណីមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ឬសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។[9] ជាក់ស្តែង នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤៤ កថាខណ្ឌទី១ បានចែងថា " មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី "។

**ខ. ភាគីត្រូវមានសមត្ថភាពខាងឆន្ទៈ**

សំដៅទៅលើភាគីដែលមានសមត្ថភាពអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន បើមិនដូច្នោះទេសកម្មភាពនោះ អាចនឹងត្រូវលុបចោលបាន។[10]

**គ. ភាគីត្រូវមានសមត្ថភាពក្នុងការធ្វើសកម្មភាព**

សំដៅទៅលើជនក្រៅដែលត្រូវបានកម្រិតសមត្ថភាពធ្វើសកម្មភាព ដូចដែលបានកំណត់នៅក្នុងមាត្រា ១៦ នៃក្រមរដ្ឋប្បវេណី។ ជនដែលត្រូវបានកម្រិតសមត្ថភាព មានបីប្រភេទ គឺអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។ កិច្ចសន្យាដែលបង្កើតឡើងដោយជនក្រៅពីជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព គឺមានសុពលភាពពេញលេញ ប្រសិនបើពុំមានមូលហេតុផ្សេងទៀតដែលនាំឱ្យមោឃៈភាព ឬមូលហេតុដែលអាចលុបចោលកិច្ចសន្យាបាន។

**ឃ. ភាគីគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ**[11]

ភាពគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ សំដៅទៅលើការបង្ហាញឆន្ទៈដែលមានសុពលភាព ដែលជាលក្ខខណ្ឌដើម្បីឱ្យកិច្ចសន្យាមានអានុភាពចងភាគីទាំងពីរ។ ក្នុងករណីដែលការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់

---

[7] មាត្រា ៣៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[8] ពាក្យ « សកម្មភាព » នៅទីនេះសំដៅទៅលើកិច្ចសន្យា ឬសកម្មភាពឯតោភាគី

[9] មាត្រា ៧ នៃក្រមរដ្ឋប្បវេណី ២០០៧

[10] មាត្រា ១៤ នៃក្រមរដ្ឋប្បវេណី ២០០៧

[11] សូមមើលផ្នែកទី២ «វិការៈក្នុងការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា » មាត្រា ៣៤៥ ដល់មាត្រា ៣៥៥ នៃក្រមរដ្ឋប្បវេណី ២០០៧

ច្រឡំ ដោយការឆបោក ឬការគម្រាមកំហែង ឬការបង្ហាញឆន្ទៈមិនពិតរបស់ភាគីម្ខាងទៀត និងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ នោះគេហៅថា ការបង្ហាញឆន្ទៈដែលមានវិការៈ។ ក្នុងករណីបែបនេះ កិច្ចសន្យាអាចត្រូវលុបចោល ដោយសារមានវិការៈក្នុងការបង្ហាញឆន្ទៈ។

### ១.២.២. លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារ

ចំពោះលក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារ មាន៤ គឺៈ

**ក. ភាពច្បាស់លាស់**

ប្រសិនបើកិច្ចសន្យា មានភាពមិនច្បាស់លាស់ វានឹងនាំអោយមានមោឃៈ ព្រោះខ្លឹមសារនៃកាតព្វកិច្ចក្នុងកិច្ចសន្យាមិនអាចយកទៅអនុវត្តបានតាមរយៈតុលាការ។

**ឧទាហរណ៍** លោក **ក** បានសន្យាថា បើ **ខ** អាយុ ១៨ឆ្នាំ លោក **ក** នឹងធ្វើអ្វីៗល្អដល់ **ខ**។ ចំពោះខ្លឹមសារនៃកិច្ចសន្យាបែបនេះ តុលាការមិនអាចចេញសាលក្រម ឬ មិនអាចអនុវត្តកាតព្វកិច្ចដោយបង្ខំបានទេដោយហេតុថា ខ្លឹមសារនៃកិច្ចសន្យា មានភាពមិនច្បាស់លាស់។ ក៏ប៉ុន្តែ វាមិនមានភាពចាំបាច់ ក្នុងការសម្រេចថារាល់ខ្លឹមសារទាំងអស់នៅក្នុងកិច្ចសន្យា ត្រូវតែមានភាពច្បាស់លាស់នោះទេ។ វាគឺមានលក្ខណៈគ្រប់គ្រាន់ដែលបង្ហាញពីភាពច្បាស់លាស់ ប្រសិនបើផ្នែកសំខាន់នៃកិច្ចសន្យា អាចត្រូវបានបង្ហាញអោយឃើញច្បាស់លាស់តាមរយៈការបកស្រាយ។ ដូចនេះ ភាពច្បាស់លាស់នៅទីនេះ ភាពច្បាស់លាស់នៅទីនេះ គឺសំដៅតែ **ផ្នែកសំខាន់នៃកិច្ចសន្យា** តែប៉ុណ្ណោះ។

**ឧទាហរណ៍** កិច្ចសន្យាលក់ទិញរវាង **ក** និង **ខ** មិនបានកំណត់ថ្លៃ។ កិច្ចសន្យានេះ មិនត្រូវបានចាត់ទុកជាមោឃៈ ជាចាំបាច់នោះទេ ប្រសិនបើពួកគាត់ បានព្រមព្រៀងអំពីវិធីកំណត់ថ្លៃទិញ នៅពេលអនាគត[12] ឬនិយាយម្យ៉ាងទៀត ភាគីកំណត់ប្រាក់ថ្លៃទិញ នៅពេលអនុវត្តកិច្ចសន្យាក៏បាន មិនចាំបាច់នៅពេលបង្កើតកិច្ចសន្យាទេ។ ប្រសិនបើមានការព្រមព្រៀងអំពីកំណត់ថ្លៃទិញ ប៉ុន្តែភាគីមិនមានការឯកភាពលើតម្លៃលក់ទិញ នោះភាគីអាចប្តឹងទៅតុលាការ។ តុលាការត្រូវសម្រេចពីប្រាក់ថ្លៃទិញបាន ដោយធ្វើការពិចារណាទៅលើឆន្ទៈពិតប្រាកដរបស់ភាគី តម្លៃនៅលើទីផ្សារ និង ទំនៀមទម្លាប់នៃកិច្ចការជំនួញជាអាទិ៍។

**ខ. ភាពស្របច្បាប់**

ប្រសិនបើខ្លឹមសារនៃកិច្ចសន្យា ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយនោះ វាត្រូវបានចាត់ទុកជាមោឃៈ។ [13] បញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺសំដៅទៅលើបញ្ញត្តិដែលបដិសេធរាល់អានុភាពនៃសកម្មភាពគតិយុត្តិដែលបានធ្វើឡើងផ្ទុយនឹងបញ្ញត្តិនេះ។ **ឧទាហរណ៍** នៅក្នុងករណីដែលគូភាគី បានព្រមព្រៀងគ្នាថា ភាគីម្ខាង មិនអាចលុបចោលកិច្ចសន្យាបានទេ ទោះបីជាគាត់បានបង្ហាញឆន្ទៈដោយសារគំរាមកំហែងក៏ដោយ ការព្រមព្រៀងបែបនេះ ត្រូវបានចាត់ទុកជា មោឃៈ ព្រោះវាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ។

**គ. ភាពសមស្របតាមស្ថានភាពសង្គម**

ភាពសមស្របតាមស្ថានភាពសង្គម វាមានន័យថា ទោះបីជាភាគី បង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈដែរប្រសិនបើខ្លឹមសារនៃកិច្ចសន្យាផ្ទុយពីស្ថានភាពសង្គម ទំនៀមទម្លាប់ល្អ។[14]

---

[12] មត្រា ៥២១ នៃក្រមរដ្ឋប្បវេណី ២០០៧

[13] មាត្រា ៣៥៤ ចំណុច កថាខណ្ឌទី១.ក នៃក្រមរដ្ឋប្បវេណី

[14] មាត្រា ៣៥៤ ចំណុច កថាខណ្ឌទី១.ខ នៃក្រមរដ្ឋប្បវេណី

**ឃ. គ្មានការបង្ហាញឆន្ទៈមិនពិត**

លក្ខខណ្ឌនេះ សំដៅកិច្ចសន្យាអាចមានអានុភាពបានលុះត្រាតែគ្មានការបង្ហាញឆន្ទៈមិនពិត។ មានន័យថា បើកិច្ចសន្យាធ្វើឡើងដោយមានការឃុបឃិតជាមួយភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ។[15]

**ឧទាហរណ៍** លោក **ក** លក់ដីទៅលោក **ខ** ដោយឃុបឃិតគ្នា នៅក្នុងគោលបំណងបញ្ចៀសនូវការរឹបអូសពីម្ចាស់បំណុល។ បន្ទាប់មក **ក** បានផ្ទេរការចុះបញ្ជីនៃដីទៅអោយ **ខ**។ នេះគឺជាការបង្ហាញឆន្ទៈមិនពិត។ នៅក្នុងករណីនៃការបង្ហាញឆន្ទៈមិនពិត កិច្ចសន្យារវាង **ក** និង **ខ** ត្រូវបានចាត់ទុកជាមោឃៈ។

ចំពោះលក្ខខណ្ឌទាំងបួននេះ លក្ខខណ្ឌចាប់ពីលេខរៀង **២** ដល់ **៤** គឺជាលក្ខខណ្ឌសំខាន់ ព្រោះមានចែងច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណី រីឯលក្ខខណ្ឌទី**១** មិនមានសរសេរនៅក្នុងច្បាប់ទេ។ ក៏ប៉ុន្តែភាពច្បាស់លាស់នៅក្នុងកិច្ចសន្យា គឺត្រូវបានទទួលស្គាល់ទៅតាមលក្ខណៈនៃកាតព្វកិច្ច។

[15] មាត្រា ៣៥៣ នៃក្រមរដ្ឋប្បវេណី ២០០៧

# ជំពូកទី ២

# ការបង្កើតកិច្ចសន្យា

## គោលការណ៍នៃការបង្កើតកិច្ចសន្យា

យោងតាមមាត្រា ៣៣៦ កថាខណ្ឌទី ១ កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្វីការត្រូវគ្នា ។ ទន្ទឹមនឹងនេះ កិច្ចសន្យាត្រូវបានបង្កើតឡើងនៅពេលដែលដំណឹងអំពីស្វីការបានមកដល់អ្នកស្នើ។[16]

## ២.១. សំណើ

សំណើ គឺជាការសុំបង្កើតកិច្ចសន្យា ដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀត ចំពោះសំណើនេះ។[17]

សំណើ ត្រូវមានអានុភាព នៅពេលសំណើនោះបានដល់ភាគីម្ខាងទៀត។[18]

ពាក្យថា បានដល់មានន័យថា **ឧទាហរណ៍** ដូចជា វាមិនមានភាពចាំបាច់ដែលអ្នកទទួលសំណើបានទទួល ឬ បានបើកអានសំណើនោះទេ គឺអោយតែបានទៅដល់។ **ឧទាហរណ៍** អ្នករស់នៅជាមួយនឹងអ្នកទទួលសំណើបានទទួល ឬ សំណើ បានទៅដល់ប្រអប់សំបុត្រនៃផ្ទះអ្នកទទួលសំណើ(ភាគីម្ខាងទៀត)។

## ២.២. ស្វីការ

ស្វីការគឺជាការបង្ហាញឆន្ទៈ ដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។[19]

**ករណីសិក្សា**

**ក** បានចុះកិច្ចសន្យាជាមួយនឹង **ខ** ក្នុងការលក់នូវនាឡិកាដៃបុរាណរបស់ **ក**។ តើនៅពេលណាមួយខាងក្រោមនេះ ចាប់ពី ១ ដល់ ៥ ដែលកិច្ចសន្យា ត្រូវបានបង្កើតឡើង?

1. **ក** បានផ្ញើសំបុត្រ នៅថ្ងៃទី១ ខែសីហា ដើម្បីផ្តល់សំណើលក់នាឡិកាដៃ ក្នុងតម្លៃ ១០០០ដុល្លារ
2. **ខ** បានទទួលសំបុត្ររបស់ **ក** ហើយ បានអាននៅថ្ងៃទី៣ ខែសីហា
3. នៅថ្ងៃទី៤ ខែសីហា **ខ** បានទូរស័ព្ទទៅ **ក** និង បាននិយាយប្រាប់ **ក** ថា គាត់នឹងប្រគល់ប្រាក់នៅផ្ទះរបស់ **ក** ដើម្បីទិញនាឡិកាដៃនោះ ក្នុងតម្លៃ១០០០ដុល្លារ។
4. **ខ** បានមកដល់ផ្ទះរបស់ **ក** និង បានបង់ប្រាក់ចំនួន ១០០០ដុល្លារ នៅថ្ងៃទី៥ ខែសីហា។ ក៏ប៉ុន្តែនាឡិកាដៃនោះ ខូច ដូច្នេះ **ខ** បានស្នើសុំអោយ **ក** ធ្វើការជួសជុល និង យកទៅប្រគល់អោយនៅផ្ទះរបស់ **ខ**។ **ក** ក៏បានយល់ព្រម។
5. **ក** បានប្រគល់នាឡិកាដៃ នៅផ្ទះរបស់ **ខ** នៅថ្ងៃទី ៨ ខែសីហា។

**សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង**

---

[16] មាត្រា ៣៤០ នៃក្រមរដ្ឋប្បវេណី ២០០៧

[17] មាត្រា ៣៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[18] មាត្រា ៣៣៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

[19] មាត្រា ៣៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ២០០៧

កិច្ចសន្យានេះ ត្រូវបានបង្កើតឡើងនៅក្នុង ចំណុចលេខ ៣។

កិច្ចសន្យា មានអានុភាពដោយសារសំណើ និង ស្ទីការត្រូវគ្នា[20] ហើយសំណើ ត្រូវមានអានុភាពនៅពេលសំណើនោះបានដល់ភាគីម្ខាងទៀត។[21] ដូច្នេះ សំណើរបស់ **ក** មានអានុភាពនៅថ្ងៃទី៣ ខែសីហា។ បន្ទាប់មក **ខ** បានទូរស័ព្ទទៅ **ក** ហើយបានប្រាប់ថា **ខ** យល់ព្រមទៅសំណើរបស់ **ក**។ ឬនិយាយម៉្យាងទៀត ស្ទីការរបស់ **ខ** បានដល់ **ក** ភ្លាមៗនោះដែរ។ នៅពេលនោះ កិច្ចសន្យារវាង **ក** និង **ខ** ត្រូវបានមានអានុភាព។

## ២.៣. សំណើមាន ឬ គ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ

សំណើ អាចជាសំណើដែលមាន ឬ គ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ។

### ២.៣.១. សំណើមានការកំណត់អំឡុងពេលសម្រាប់ស្ទីការ

តាមមាត្រា ៣៣៨ នៃក្រមរដ្ឋប្បវេណី សំណើ អាចភ្ជាប់ជាមួយនឹងរយៈពេលសម្រាប់ស្ទីការ។ ប្រសិនបើវាមិនមានភាពច្បាស់លាស់ ថាតើអ្នកស្នើ បានកំណត់ថ្ងៃណាមួយនោះទេ នោះវាត្រូវគិតចាប់ពីថ្ងៃដែលសំណើត្រូវបានផ្ញើចេញ។ សំណើនេះ ត្រូវបានធ្វើឡើង ដើម្បីជាប្រយោជន៍របស់អ្នកស្នើខ្លួនឯងផ្ទាល់ ព្រោះអ្នកស្នើអាចធ្វើសំណើនេះ ទៅបុគ្គលផ្សេងទៀតបាន ប្រសិនបើគាត់មិនបានទទួលស្ទីការ នៅក្នុងអំឡុងពេលនោះ។ អ្នកស្នើមិនចាំបាច់ដកសំណើរបស់ខ្លួននៅ ក្រោយអំឡុងពេលសម្រាប់ស្ទីការនោះទេ។ ការកំណត់អំឡុងពេលពេលនេះគឺដើម្បីបញ្ជាក់អំពីឆន្ទៈរបស់អ្នកស្នើក្នុងការរង់ចាំអំឡុង ពេលសម្រាប់ស្ទីការ ហើយ ប្រសិនបើអ្នកស្នើ អាចដកសំណើនោះនៅពេលដែលគាត់ចង់ នោះអ្នកទទួលសំណើ អាចទទួលរងនូវការខូតខាតដែលមិនអាចរំពឹងទុកជាមុន។ ដូច្នេះ កថាខណ្ឌទី ២ នៃមាត្រា ៣៣៨ មិនអនុញ្ញាតអោយដកសំណើវិញបាន។ ប្រសិនបើមិនមានការឆ្លើយតបទៅនឹងសំណើនោះ ឬក៏អ្នកធ្វើស្ទីការបដិសេធទៅនឹងសំណើនៅក្នុងអំឡុងពេលនោះ សំណើនោះនឹងបាត់បង់អានុភាព។[22]

### ២.៣.២. សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ

ប្រសិនបើភាគីកំពុងនិយាយចរចារគ្នា **ឧទាហរណ៍** ដូចជា ភាគីកំពុងនិយាយទល់មុខគ្នា ឬ និយាយតាមទូរស័ព្ទ ហើយបើភាគីដែលទទួលសំណើ មិនបានឆ្លើយតបដោយភ្លាមៗ ហើយមិនផ្តល់ស្ទីការទេ[23] សំណើនោះនឹងបាត់បង់អានុភាព។

**ឧទាហរណ៍:** **ក** បានផ្តល់សំណើលក់ប៊ិចធម្មតាទៅអោយ **ខ** នៅពេលដែលកំពុងនិយាយគ្នា។ ប្រសិនបើ **ខ** មិនបានឆ្លើយតបភ្លាមៗនោះទេ សំណើនឹងបាត់បង់អានុភាព។

ចំពោះសំណើ ដែលភាគីមិនកំពុងនិយាយគ្នា អ្នកស្នើមិនអាចដកសំណើរបស់ខ្លួនបានទេ ក្នុងអំឡុងពេលមួយដែលសមរម្យ។[24] អ្នកស្នើអាចដកសំណើរបស់ខ្លួនបាន តែពេលដែលការជូនដំណឹងអំពីការដកសំណើ បានដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀត ជូនដំណឹងអំពីស្ទីការទៅអ្នកស្នើ។[25]

---

[20] មាត្រា ៣៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[21] មាត្រា ៣៣៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

[22] មាត្រា ៣៣៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ២០០៧

[23] មាត្រា ៣៣៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[24] មាត្រា ៣៣៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

* **អំឡុងពេលសមរម្យ** ៖ ជាការបកស្រាយតាមស្ថានភាពជាក់ស្តែង ខ្លឹមសារនៃកិច្ចសន្យា និងទំហំនៃវត្ថុជាដើម ។

**ឧទាហរណ៍១ ៖ ក** ផ្ញើសំណើលក់ប៊ិចរបស់ខ្លួនធ្វើអំពីមាសតាមសំបុត្រ ហើយ **ខ** មិនបានឆ្លើយតបទេ ។ ប៉ុន្តែ **ក** មិនអាចដកសំណើបានទេ គឺត្រូវទុកពេលអោយ **ខ** គិតក្នុងពេលមួយសមរម្យ។

* **ករណីលើកលែង** ៖ ការជួញដូរអចលនវត្ថុ

កិច្ចសន្យា មានអានុភាពដោយសំណើ និងស្វីការត្រូវគ្នា។[26] នេះគឺជាគោលការណ៍ទូទៅ។ ប៉ុន្តែទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី១ក្នុងមាត្រា ៣៣៦ នេះក៏ដោយក៏កិច្ចសន្យាដែលភាគីម្ខាង ទទួលករណីកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិ ឬករណីកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនឹងមានអានុភាពលុះត្រាតែបានធ្វើលិខិតយថាភូត។[27]

មូលហេតុដែលក្រមរដ្ឋប្បវេណី ចែងថា លិខិតយថាភូត តម្រូវអោយមានក្នុងការធ្វើអនុប្បទានលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ គឺមានដូចខាងក្រោមៈ

១. ការពារចំពោះអ្នកដែលមានការយល់ដឹងតិចតួចចំពោះការផ្ទេរ

២. ការពារចំពោះអ្នកទិញ ឬ អ្នកដែលមានការយល់ដឹងតិចតួច

៣. មធ្យោបាយបង្ហាញភស្តុតាងសម្រាប់បញ្ជាក់ពីអត្ថិភាព និងខ្លឹមសារនៃកិច្ចសន្យា

## ២.៤. អានុភាពនៃកិច្ចសន្យាទ្វេភាគី

កិច្ចសន្យាទ្វេភាគី គឺជាកិច្ចសន្យាមួយ ដែលគូភាគីត្រូវមានកាតព្វកិច្ចបំពេញអោយគ្នាទៅវិញទៅមក។ ដូច្នេះភាគីនៃកិច្ចសន្យា គឺមានលក្ខណៈជិតស្និត ដោយសារតែមូលហេតុនេះ ទើបគេថាកិច្ចសន្យានេះមានលក្ខណៈទៅវិញទៅមក។

* **លក្ខណៈទៅវិញទៅមកនៃកិច្ចសន្យាទ្វេភាគី មាន៣ គឺៈ**

១. លក្ខណៈទៅវិញទៅមក ក្នុងការបង្កើតកិច្ចសន្យាទ្វេភាគី

២. លក្ខណៈទៅវិញទៅមក ក្នុងការអនុវត្តកិច្ចសន្យាទ្វេភាគី

៣. លក្ខណៈទៅវិញទៅមក នៅក្នុងអត្ថិភាពដែលត្រូវបន្ត

### ២.៤.១. លក្ខណៈទៅវិញទៅមកក្នុងការបង្កើតកិច្ចសន្យាទ្វេភាគី ៖ អលទ្ធភាពតាំងពីដំបូង

ទោះបីជាខ្លឹមសារនៃកិច្ចសន្យា មិនអាចសម្រេចបាន តាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះ មិនត្រូវបានចាត់ទុកថាជាមោឃៈដោយមូលហេតុនៃអលទ្ធភាពនោះដែរ។[28]

ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងដល់ភាគីនៅក្នុងកិច្ចសន្យា ក្នុងការលុបកិច្ចសន្យាដោយការភាន់ច្រឡំឡើយប្រសិនបើលក្ខខណ្ឌនៃការភាន់ច្រឡំបានបំពេញ។

អលទ្ធភាពមាន ២ ផ្នែកៈ

---

[25] មាត្រា ៣៣៩ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ២០០៧

[26] មាត្រា ៣៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[27] មាត្រា ៣៣៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

[28] មាត្រា ៣៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

អលទ្ធភាពដោយផ្នែក
អលទ្ធភាពទាំងស្រុង } ស្នួរថា តើកូនបំណុលមានកំហុសដែលនាំអោយមានលទ្ធភាព

ប្រសិនបើ**អលទ្ធភាពដោយផ្នែក** កើតឡើងនោះ វាគឺជាបញ្ហានៃការទទួលខុសត្រូវនៅក្នុងធានា។

ទន្ទឹមនឹងនេះ ប្រសិនបើអលទ្ធភាពទាំងស្រុង កើតឡើងដោយសារកំហុសរបស់កូនបំណុល នោះកូនបំណុលត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច។

**អលទ្ធភាពទាំងស្រុង:** ករណីដែលកូនបំណុលពុំមានកំហុសទេ នោះម្ចាស់បំណុលមិនអាចទាមទារអោយអនុវត្តបាន ឬ មិនអាចទាមទារសំណងការខូចខាត ឬ ជម្ងឺចិត្តបានទេ។[29]

**ឧទាហរណ៍: ក** លក់ផ្ទះអោយ **ខ**

- លទ្ធភាពតាំងពីដំបូង មាត្រា ៤១៥ ( ការលក់កាតព្វកិច្ចរបស់ភាគី )
- អលទ្ធភាពដោយសារគ្មានកំហុសរបស់កូនបំណុល មាត្រា ៤១៥ និង ៣៩៨ កថាខណ្ឌទី ២ត្រូវយកមកអនុវត្ត

## ២.៤.២. លក្ខណៈ " ទៅវិញទៅមក " នៅក្នុងការអនុវត្តកិច្ចសន្យាទ្វេភាគី

### ក. ការតវ៉ាអោយអនុវត្តព្រមគ្នា

### ក.១ តួនាទី

សិទ្ធិតវ៉ាអោយអនុវត្តព្រមគ្នារវាងភាគីកូនបំណុល និង ភាគីម្ចាស់បំណុល ដូចជាៈ ជំរុញអោយមានការអនុវត្តកាតព្វកិច្ច និង ជៀសវាងនូវការខូចខាត ក្នុងករណីមិនអនុវត្តកាតព្វកិច្ច។[30] ជាគោលការណ៍ប្រសិនបើច្បាប់ មិនបានចែងអំពីការតវ៉ាអោយអនុវត្តព្រមគ្នាក្នុងកិច្ចសន្យាអញ្ញមញ្ញនោះទេ គឺធ្វើអោយមានភាពមិនស្មើគ្នាកើតឡើង ក្នុងការអនុវត្តកាតព្វកិច្ច ពីព្រោះភាគីម្ខាងមិនមានសិទ្ធិតវ៉ា ក្នុងករណីដែលភាគីម្ខាងទៀតបានអាក់ខានមិនព្រមអនុវត្ត រឺ ព្រងើយកណ្តើយជាមួយនឹងការអនុវត្តរបស់ខ្លួន។ ឬនិយាយម៉្យាងទៀត បើគ្មានការតវ៉ាអោយអនុវត្តព្រមគ្នានោះទេ ម្ចាស់បំណុលត្រូវអនុវត្តកាតព្វកិច្ចតប ឬ រំលាយកិច្ចសន្យានៅពេលក្រោយ ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នៅក្នុងករណីនេះ កូនបំណុលអាចនឹងប្រើប្រាស់ប្រាក់ដែរបានទទួល ឬ លក់នូវកម្មវត្ថុនៃកិច្ចសន្យា ហើយម្ចាស់បំណុល មិនអាចទទួលបាននូវកម្មវត្ថុដែលត្រូវបានអនុវត្តរួចរាល់ហើយ។ ដូច្នេះ ភាគីម្ខាងនៃកិច្ចសន្យាអាចប្រកែកមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន រហូតដល់ភាគីម្ខាងទៀតអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ការតវ៉ាអោយអនុវត្តព្រមគ្នា មានតួនាទីបញ្ចៀសនូវការខូចខាតនៅក្នុងករណីនេះ។

### ក.២ លក្ខខណ្ឌ

នៅក្នុងមាត្រា ៣៨៦ ក៏បានចែងពីលក្ខខណ្ឌនៃការតវ៉ាអោយអនុវត្តព្រមគ្នាមួយចំនួនដូចជា៖

1) វត្តមាននៃកាតព្វកិច្ច ដែលសមមូលដែលកើតចេញពីកិច្ចសន្យាទ្វេភាគីតែមួយ
2) កាតព្វកិច្ចរបស់ភាគីម្ខាងទៀត គឺដល់ពេលកំណត់
3) ភាគីម្ខាងទៀត ទាមទារអោយអនុវត្តកាតព្វកិច្ចដោយមិនបានផ្តល់នូវការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

[29] មាត្រា ៣៩៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[30] មាត្រា ៣៨៦ នៃក្រមរដ្ឋប្បវេណី ២០០៧

នៅក្នុងករណីដែលពេលសម្រាប់អនុវត្តកាតព្វកិច្ចរបស់ ភាគីម្ខាងទៀត មិនទាន់មកដល់ ភាគីនោះមិនអាចអះអាងពីការតវ៉ាអោយអនុវត្តព្រមគ្នាបានទេ។[31] ភាគីនោះមិនអាចសម្រេចនូវសិទ្ធិលើបំណុលរបស់ខ្លួន តាមរយៈការអនុវត្តដោយបង្ខំទេ ព្រោះកូនបំណុលមានផលប្រយោជន៍នៃការកំណត់ពេលវេលា។[32]

**ក.៣ អានុភាព**

**ក.៣.១ អានុភាពជាអត្ថិភាព**

ដរាបណាភាគី មានការតវ៉ាចំពោះការអនុវត្តព្រមគ្នានោះ ភាគីនឹងមិនស្ថិតក្នុងការភាពយឺតយ៉ាវទេ ទោះបីជាភាគីដែលមានការតវ៉ាអោយអនុវត្តព្រមគ្នា មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន នៅពេលកាលបរិច្ឆេទកំណត់ព្រោះ ភាគី មានសិទ្ធិស្របច្បាប់ក្នុងការបដិសេធមិនអនុវត្តកាតព្វកិច្ច នៅក្នុងស្ថានភាពនេះ។ ការយឺតយ៉ាវក្នុងការអនុវត្ត ក៏ជាប្រភេទមួយនៃការមិនអនុវត្តកាតព្វកិច្ចដែរ។ ការយឺតយ៉ាវក្នុងការអនុវត្តកើតឡើង ប្រសិនបើការកំណត់ពេល ត្រូវអនុវត្តដែលជាពេលវេលាដែលកូនបំណុល ត្រូវផ្តល់តាវកាលិកកន្លងហួស។

ការយឺតយ៉ាវក្នុងការអនុវវត្ត មាន ៣ប្រភេទ [33]៖

1) ប្រសិនបើមានកំណត់ពេលពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដល់កាលកំណត់នោះ

2) ប្រសិនបើមានកំណត់ពេលមិនពិតប្រាកដ សម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដែលកូនបំណុលដឹងថាដល់ពេលកំណត់ហើយ

3) ប្រសិនបើមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ចទេ នៅពេលដែលកូនបំណុលទទួលការទាមទារអោយអនុវត្ត។

ការទូទាត់គឺជាប្រព័ន្ធមួយដើម្បីរំលត់កាតព្វកិច្ចទេ ដោយការបង្ហាញឆន្ទៈជាឯកតោភាគីម្ខាង ដូច្នេះកាតព្វកិច្ចដែលភ្ជាប់នឹងសិទ្ធិតវ៉ា ត្រូវបានការពារមិនអោយធ្វើការទូទាត់ឡើយ។

**ក.៣.២ អានុភាពកើតពីការអនុវត្តការតវ៉ាអោយអនុវត្តព្រមគ្នានៅក្នុងនីតិវិធីបណ្តឹង**

ភាគីដែលមានការតវ៉ាអោយអនុវត្តព្រមគ្នា អាចអះអាងពីការតវ៉ានេះ នៅក្នុងនីតិវិធីបណ្តឹងបាន។ នៅក្នុងករណីនេះ ប្រសិនបើតុលាការ ទទួលស្គាល់នូវការតវ៉ានេះ តុលាការត្រូវចេញសាលក្រមអនុវត្ត ជាថ្នូរនឹងតាវកាលិកតប។ **ឧទាហរណ៍** ដើមចោទ **ក**បានដាក់ពាក្យបណ្តឹងចំពោះ **ខ** ដោយទាមទារអោយបង់ប្រាក់ចំនួន ៥០០០ ដុល្លារ ដែលជាប្រាក់ថ្លៃលក់រថយន្ត ហើយ **ខ** បានអះអាងពីការតវ៉ាអោយអនុវត្តព្រមគ្នា នៅក្នុងនីតិវិធីបណ្តឹង។ ប្រសិនបើតុលាការទទួលស្គាល់នូវការតវ៉ារបស់ **ខ** នោះសាលក្រម គឺសម្រេចថា ចុងចម្លើយត្រូវបង់ប្រាក់ចំនួន ៥០០០ ដុល្លារ ជាថ្នូរនឹងការប្រគល់រថយន្តរបស់ **ក**។

**ករណីសិក្សា**

តើ **ក** អាចបដិសេធនូវការទាមទាររបស់ **ខ** អោយផ្ទេរនូវកម្មវត្ថុ នៅក្នុងករណីខាងក្រោមនេះដែរ ឬទេ?

1) **ក** គឺជាម្ចាស់ហាងលក់ស្រាមួយកន្លែង។ អតិថិជន **ខ** បានចូលមកក្នុងហាង។ **ក** មិនដែលស្គាល់ **ខ** ទេ ។ **ខ** ស្នើទិញស្រាបៀចំនួន ១០ ដប ក្នុងតម្លៃ៦ ដុល្លារ។ **ក** បានយល់ព្រមនឹងសំណើរបស់ **ខ**

[31] មាត្រា ៣៨៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី

[32] មាត្រា ៣៣០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

[33] មាត្រា ៣៩១ នៃក្រមរដ្ឋប្បវេណី

ហើយបានរៀបចំស្រាបៀចំនួន ១០ ដប សម្រាប់ **ខ** ។ ក៏ប៉ុន្តែ **ខ** បានប្រាប់ថា ខ្ញុំភ្លេចយកកាបូបលុយមកហើយ។ ខ្ញុំនឹងបង់ប្រាក់នៅពេលក្រោយ ឥឡូវនេះ សូមផ្តល់អោយខ្ញុំនូវស្រាបៀ ១០ ដបសិនមក។

2) នៅក្នុងករណីទី១ ខាងលើ **ខ** បានប្រាប់ទៅ **ក** ខ្ញុំយកកាបូបលុយមកជាមួយតែ ១ ដុល្លារទេ។ ខ្ញុំនឹងបង់ប្រាក់អោយ ១ ដុល្លារសិន ហើយសូមផ្តល់អោយខ្ញុំនូវស្រាបៀ ១០ដប។ ហើយខ្ញុំ នឹងបង់ប្រាក់ដែលនៅសល់នៅពេលក្រោយ។

3) **ក** បានលក់រថយន្តរបស់ខ្លួនអោយទៅ **ខ** ក្នុងតម្លៃ ៥០០០ដុល្លារ។ កាលបរិច្ឆេទនៃកាតព្វកិច្ចទាំងពីរ គឺនៅថ្ងៃទី១០ ខែកញ្ញា។ ក៏ប៉ុន្តែ **ក** និង **ខ** មិនធ្វើសំណើផ្តល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួន នៅកាលបរិច្ឆេទកំណត់នោះទេ។ ក្រោយមក **ខ** បានទាមទារអោយ **ក** ប្រគល់រថយន្ត ដោយមិនបានធ្វើសំណើផ្តល់ការអនុវត្តទេ។

4) **ក** បានលក់រថយន្តរបស់ខ្លួនអោយទៅ **ខ** នៅក្នុងតម្លៃ៥០០០ ដុល្លារ ហើយភាគីបានព្រមព្រៀងគ្នា **ខ** ត្រូវបង់ប្រាក់នៅថ្ងៃទី ១០ ខែកញ្ញា ហើយ **ក** ត្រូវប្រគល់រថយន្តទៅអោយ **ខ** នៅថ្ងៃទី ៣០ ខែកញ្ញា។ **ខ** បានបង់ប្រាក់នៅថ្ងៃទី ១០ ខែកញ្ញា ទៅអោយ **ក**។ ក្រោយមក **ខ** បានទាមទារអោយ **ក** ប្រគល់រថយន្តនៅថ្ងៃទី១៥ ខែកញ្ញា។

5) **ក** បានបង្កើតកិច្ចសន្យាលក់រថយន្តរបស់ខ្លួនអោយទៅ **ខ** ក្នុងតម្លៃ៥០០០ ដុល្លារ ហើយបានព្រមព្រៀងគ្នាថា **ខ** ត្រូវបង់ប្រាក់នៅថ្ងៃទី ១០ ខែ កញ្ញា និង **ក** ត្រូវប្រគល់រថយន្តនៅថ្ងៃទី ៣០ ខែកញ្ញា។ **ក** មិនបានប្រគល់ រថយន្តទៅអោយ **ខ** នៅកាលបរិច្ឆេទកំណត់នោះទេ ហើយ **ខ** បានទាមទារអោយ **ក** ប្រគល់រថយន្តនៅថ្ងៃទី ១៥ ខែកញ្ញា ដោយមិនបានធ្វើសំណើផ្តល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

6) **នៅក្នុងករណីទី៥** ទាំង **ក** និង **ខ** មិនបានធ្វើសំណើផ្តល់ការអនុវត្តកាតព្វកិច្ច នៅកាលបរិច្ឆេទកំណត់។ បន្ទាប់នៅថ្ងៃទី ១ ខែតុលា **ខ** បានទាមទារអោយ **ក** ប្រគល់រថយន្តអោយមិនបានធ្វើសំណើផ្តល់ការអនុវត្តរបស់ខ្លួន។

*** សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង**

១) **ក** អាចបដិសេធការទាមទាររបស់ **ខ**

ដោយផ្អែកលើអង្គហេតុ និង មាត្រា ៣៨៦ វាគឺជារឿងធម្មតាសម្រាប់ការអនុវត្តកាតព្វកិច្ចទូទៅ នៅក្នុងកិច្ចសន្យា នៅក្នុងប្រតិបត្តិការជំនួញធម្មតា ដូចជានៅពេលដែលយើងទិញវត្ថុអ្វីមួយ យើងចាំបាច់ត្រូវបង់ប្រាក់ទៅអោយអ្នកលក់ និងអ្នកលក់នោះ ត្រូវប្រគល់វត្ថុនោះ ដោយអនុវត្តកាតព្វកិច្ចព្រមគ្នា។ ក៏ប៉ុន្តែ នៅក្នុងករណីទី១) **ខ** បានទិញស្រាបៀពី **ក** ប៉ុន្តែ **ខ** មិនបានបង់ប្រាក់ទៅ **ក** ទេ ដោយសារតែ **ខ** ភ្លេចយកកាបូបលុយមក។ ដូច្នេះ **ក** បានសិទ្ធិក្នុងការតវ៉ា និង បដិសេធមិនព្រមប្រគល់ស្រាបៀទៅអោយ **ខ** រហូតដល់ **ខ** អនុវត្តកាតព្វកិច្ចបង់ប្រាក់អោយទៅ **ក** ដោយព្រមគ្នា។

២) **ក** អាចបដិសេធការទាមទាររបស់ **ខ**

បញ្ញត្តិដែលពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ច ( មាត្រា ៤៣៤ រហូតដល់មាត្រា ៤៦៣) ត្រូវយកមកអនុវត្ត ចំពោះការអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា។ ដោយផ្អែកលើមាត្រា ៤៤១ ម្ចាស់បំណុលមិនបានតម្រូវអោយទទួលយកនូវការសងមួយភាគនោះទេ ព្រោះការសងមួយភាគ មិនត្រូវបានចាត់ទុកថា បានបំពេញនូវគោលបំណងនៃ

កិច្ចសន្យាឡើយ។ ដូច្នេះ ទោះបីជា **ខ** បានបង់ប្រាក់ចំនួន ១ ដុល្លារ ក៏ដោយ ក៏វាមិនមែនជា " **អនុវត្តកាតព្វកិច្ចដែរ** " ហើយ **ក** អាចបដិសេធចំពោះការទាមទាររបស់ **ខ**។

៣) **ក** អាចបដិសេធការទាមទាររបស់ **ខ**

នៅក្នុងករណីនេះ កាតព្វកិច្ចទាំងពីរ ត្រូវបានចាត់ទុកថា ស្ថិតនៅក្នុងលក្ខខណ្ឌដូចគ្នា គឺកាតព្វកិច្ចមិនបានកំណត់ពេល ( មាត្រា ៣៩១ កថាខណ្ឌទី ៣) ព្រោះកាតព្វកិច្ចទាំងពីរបានដល់ពេលកំណត់ដូចគ្នា។ ដូច្នេះ **ក** អាចបដិសេធការទាមទាររបស់ **ខ** បាន ប្រសិនបើ **ខ** បានទាមទារអោយ **ក** ប្រគល់រថយន្ត ដោយមិនបានធ្វើសំណើផ្តល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

៤) **ក** អាចបដិសេធការទាមទាររបស់ **ខ**

**ក** មិនចាំបាច់ប្រគល់រថយន្ត រហូតដល់ថ្ងៃទី ៣០ ខែកញ្ញា។ ឬនិយាយម្យ៉ាងទៀត **ខ** មិនអាចតម្រូវអោយ **ក** អនុវត្តកាតព្វកិច្ច មុនពេលចាប់ផ្តើមនៃកាលកំណត់ បានមកដល់ឡើយ។[34] **ក** មានផលប្រយោជន៍ក្នុងការកំណត់ពេលវេលា(មាត្រា ៣៣០)។

៥) **ក** មិនអាចបដិសេធការទាមទាររបស់ **ខ**

កាតព្វកិច្ចរបស់ **ក** បានមកដល់ពេលកំណត់នៅថ្ងៃទី ១០ ខែកញ្ញា ។ វាមានន័យថា កាតព្វកិច្ចរបស់ភាគីម្ខាងទៀត បានមកដល់សម្រេច **ខ**។ ផ្ទុយទៅវិញ កាតព្វកិច្ចរបស់ **ខ** មិនទាន់ដល់ទេនៅថ្ងៃទី ១៥ ខែកញ្ញា។ ដូច្នេះ **ក** មិនអាចបដិសេធការទាមទាររបស់ **ខ** បានទេ។[35]

៦) **ក** អាចបដិសេធ/ មិនអាចបដិសេធការទាមទាររបស់ **ខ**

នៅក្នុងករណីនេះ កាតព្វកិច្ចរបស់ភាគីទាំងសងខាង ត្រូវបានចាត់ទុកថា ស្ថិតនៅក្នុងស្ថានភាពដូចគ្នាគឺកាតព្វកិច្ច មិនបានកំណត់ពេល ដូចនៅក្នុងករណីទី៣) ដែរ។ ក៏ប៉ុន្តែនៅក្នុងករណីនេះ **ក** មានកាតព្វកិច្ច ដែលត្រូវអនុវត្តមុន **ខ**។ ក្រោយកាលបរិច្ឆេទកំណត់ **ក** ត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវក្នុងការអនុវត្ត។ បញ្ហា គឺនៅត្រង់ថា តើ វា មានភាពយុត្តិធម៌ដែរ ឬ អត់ ដែលអនុញ្ញាតឱ្យជន ដូចជា **ក** ធ្វើការបដិសេធការទាមទាររបស់ **ខ** ដោយផ្អែកលើការតវ៉ាអោយអនុវត្តព្រមគ្នា។

មានគំនិតចំនួនពីរ។ **ទី១** គឺ គំនិតដែលបដិសេធនូវការតវ៉ាអោយអនុវត្តព្រមគ្នារបស់ **ក** ព្រោះ **ក** មានកាតព្វកិច្ចដែលតម្រូវអោយអនុវត្តមុន **ខ** ។ **ទី២** គឺមានគំនិតដែលគាំទ្រដល់តវ៉ាអោយអនុវត្តព្រមគ្នារបស់ **ក** ព្រោះមាត្រា ៣៨៦ តម្រូវអោយមានតែ ការមកដល់នៃពេលវេលានៃការអនុវត្តកាតព្វកិច្ចទាំងពីរ។ ជាងនេះទៅទៀតវាហាក់ដូចជាអយុត្តិធម៌ ប្រសិនបើ **ក** ត្រូវអនុវត្តកាតព្វកិច្ចមុន **ខ** ទោះបីជាមានការព្រួយបារម្ភគួរអោយកត់សម្គាល់ថា **ខ** នឹងមិនអនុវត្តកាតព្វកិច្ចតាមខ្លឹមសារនៃកាតព្វកិច្ច។

### ខ. ការតវ៉ាដោយមានការបារម្ភ

មាត្រា ៣៨៧ បានចែងថា " ភាគីដែលត្រូវអនុវត្តកាតព្វកិច្ចជាមុន នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ អាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន ក្នុងករណីដែលមានការបារម្ភដែលគួរអោយកត់សម្គាល់ថា ភាគីម្ខាងទៀត

[34] មាត្រា ៣២៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[35] មាត្រា ៣៨៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

នឹងមិនអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀត ដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការផ្សេងទៀតដើម្បីរំលត់ការបារម្ភនោះ ”។

ឧទាហរណ៍ៈ **ក** បានលក់រថយន្តអោយទៅ **ខ** នៅថ្ងៃទី ៣១ ខែវិច្ឆិកា ឆ្នាំ ២០១០ ហើយ ពួកគាត់ បានព្រមព្រៀងគ្នាថា **ក** ត្រូវប្រគល់រថយន្តរបស់ខ្លួន នៅថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ ២០១០ ហើយ **ខ** ត្រូវបង់ប្រាក់អោយ **ក** នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០១០។ ក៏ប៉ុន្តែ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០ **ខ** បានក្ស័យធន។

ក្នុងករណីនេះ **ក** មានការបារម្ភចំពោះការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដោយលើកមូលហេតុ **ខ** បានក្ស័យធន។ ឆ្លើយតបនឹងការលើកឡើងនេះ **ក** គឺជាភាគី ដែលអាចអះអាងពីការតវ៉ាដោយមានការបារម្ភ និង បដិសេធក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

ផ្ទុយទៅវិញ បើ **ខ** បានដាក់ប្រាតិភោគ គឺ **ក** មិនអាចបដិសេធការអនុវត្តកាតព្វកិច្ចរបស់គាត់បានឡើយ។

### ខ.១ តួនាទីនៃការតវ៉ាដោយមានការបារម្ភ

1. ភាពអយុត្តិធម៌ នឹងកើតមាន ក្នុងករណីដែលមានការបារម្ភគួរអោយកត់សម្គាល់ថា **ខ** នឹងមិនអនុវត្តកាតព្វកិច្ចបាន តែបែរជាបង្ខំអោយ **ក** ធ្វើការអនុវត្តកាតព្វកិច្ច។
2. ជួយអោយ ក ជៀសផុតពីការខូចខាត នៅក្នុងករណីដែល ខ ពុំអាចអនុវត្តកាតព្វកិច្ចបាន។

### ខ. ២ លក្ខខណ្ឌនៃការតវ៉ាដោយមានការបារម្ភ

1. មានវត្តមាននៃកាតព្វកិច្ចដែល ភាគីម្ខាងនៃកិច្ចសន្យាទទួលភាគីតម្រូវអោយអនុវត្តមុនភាគីម្ខាងទៀត
2. មានការបារម្ភគួរអោយកត់សម្គាល់ថា ភាគីម្ខាងទៀត មិនអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យា

មូលហេតុនៃការបារម្ភដែលអាចកើតមានដូចជាៈ

- ក្ស័យធន
- អសាធនីយន៍
- កង្វះទ្រព្យធននៅក្នុងរយៈពេលខ្លី

លើសពីនេះទៀត ករណីខាងក្រោមនេះ ក៏អាចចាត់ទុកថាជាការបារម្ភដែលមិនមែនជាសេដ្ឋកិច្ចៈ

- ការលាឈប់របស់ជំនួយការដ៏សំខាន់ណាម្នាក់
- ការចេញនូវបំរាមថ្មីរបស់រដ្ឋាភិបាល ដែលហាមឃាត់នូវការនាំចូលវត្ថុធាតុដើមដ៏សំខាន់

**ឧទាហរណ៍ៈ ក** បានលក់វត្ថុសិល្បៈទៅអោយ **ខ** ដោយមាន **គ** ជាអ្នកធ្វើវត្ថុសិល្បៈនោះអោយ ដែលសិប្បករគ្មានអ្នកជំនួស។ ក្រោយពីធ្វើកិច្ចសន្យាហើយ **គ** មកជំនួសនោះនឹងនាំអោយមានការរំលត់ការបារម្ភ ដោយការចាត់វិធានការណ៍ ក្រៅពីការដាក់ប្រាតិភោគ។

ដូច្នេះ ការបារម្ភនោះ មិនត្រឹមតែផ្តោតទៅលើបញ្ហាសេដ្ឋកិច្ចនោះទេ គឺថែមទាំងផ្តោតទៅលើបញ្ហាមិនមែនសេដ្ឋកិច្ចផងដែរ ដូចជា កត្តាមនុស្ស។ វាមានន័យថា ប្រសិនបើភាគីម្ខាង បានអនុវត្តកាតព្វកិច្ចរួចហើយនោះ ការតវ៉ាដោយមានការបារម្ភ ក៏ពុំអាចកើតមានឡើយ លើកលែងតែ ករណីភាគីទាំងសងខាង ពុំទាន់មានភាគីណាមួយអាចឈានទៅសម្រេចការអនុវត្តកាតព្វកិច្ចបាន។

3. ភាគីម្ខាងទៀត មិនបានផ្តល់នូវប្រាតិភោគ ឬ ចាត់ចែងវិធានការណ៍ ដើម្បីរំលត់ការបារម្ភ

ប្រាតិភោគក្នុងករណីនេះ មិនកំណត់ន័យត្រឹមការដាក់ប្រាតិភោគ ដោយវត្ថុដូចជា ការបញ្ចាំ ឬ ហ៊ីប៉ូតែក គឺថែមទាំងជាប្រាតិភោគដោយបុគ្គលផងដែរ ដូចជាអ្នកធានា។

**ឧទាហរណ៍ទី១៖ ក** បានលក់រថយន្តរបស់ខ្លួនអោយទៅ **ខ** ហើយ ពួកគាត់បានព្រមព្រៀងគ្នាថា **ក** ត្រូវប្រគល់រថយន្តនោះ នៅមុនការបង់ប្រាក់ ។ ទោះបីជា **ខ** បានក្ស័យធននៅពេលដែលអនុវត្តកាតព្វកិច្ចរបស់ **ក** ក៏ដោយ ក៏ **ក** មិនអាចអះអាងពីការតវ៉ាដោយមានការបារម្ភ នៅក្នុងករណីដែល **ខ** រកអ្នកធានា។

**ឧទាហរណ៍ទី២៖ ក** បានព្រមព្រៀងលក់ផលិតផលសិល្បៈទៅអោយ **ខ** ដោយមាន **គ** គឺជាសិប្បករម្នាក់ដ៏សំខាន់។ មិនទាន់បានធ្វើផង **គ** បានទទួលមរណភាព។ ក៏ប៉ុន្តែ **ក** មិនអាចអះអាងពីការតវ៉ាដោយមានការបារម្ភទេ ប្រសិនបើ **ខ** បានជួលសិប្បករថ្មី **ឃ** ដែលមានទឹកដៃដូច **គ** ដែរ។

ក្នុងឧទាហរណ៍ទី១ និងទី ២ គឺស្ថិតនៅក្នុងករណី **<u>រំលត់ការបារម្ភ</u>**។

**គ. អានុភាពនៃការតវ៉ាដោយមានការបារម្ភ**

១). ដរាបណា ភាគីមានការតវ៉ាដោយមានការបារម្ភ គាត់អាចបដិសេធការអនុវត្តកាតព្វកិច្ចបាន រហូតដល់ភាគីម្ខាងទៀត បានផ្តល់នូវប្រាតិភោគ ឬ ចាត់ចែងវិធានការណ៍ផ្សេងៗ ដើម្បីរំលត់ការបារម្ភនោះ។

**ឧទាហរណ៍៖ ក** បានលក់រថយន្តរបស់ខ្លួនទៅអោយ **ខ** នៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១០ ដោយបានព្រមព្រៀងគ្នាថា **ក** ត្រូវប្រគល់រថយន្តនៅ ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១០ ហើយ **ខ** ត្រូវបង់ប្រាក់ថ្លៃទិញនៅថ្ងៃទី ១ ខែធ្នូ ឆ្នាំ២០១០។ ក៏ប៉ុន្តែ **ខ** បានក្ស័យធន នៅក្រោយពេលបង្កើតកិច្ចសន្យា។

ក្នុងករណី **ក** បានលើកឡើងពីតវ៉ាដោយមានការបារម្ភ ប្រសិនបើ **ខ** ចាត់វិធានការរំលត់ការបារម្ភនៅមុនថ្ងៃទី២៥ ខែវិច្ឆិកា នោះ**ក** មិនអាចអះអាងពីការតវ៉ាដោយមានការបារម្ភទេ ហើយគាត់ ត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវនៅក្នុងការអនុវត្ត ប្រសិនបើ **ក** មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃទី២៥ ខែវិច្ឆិកា។

ម៉្យាងវិញទៀត ប្រសិនបើ **ខ** មិនបានដាក់ប្រាតិភោគ ឬ ចាត់វិធានការណ៍ដើម្បីរំលត់ការបារម្ភ នៅមុន ថ្ងៃទី២៥ ខែវិច្ឆិកា ទេ **ក** មិនត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវក្នុងការអនុវត្តទេ។

២). ភាគីដែលមានការតវ៉ាដោយមានការបារម្ភ អាចអះអាងពីការតវ៉ានេះ នៅក្នុងនីតិវិធីបណ្តឹង។

នៅក្នុងករណីដែល **ខ** បានអះអាងដោយតវ៉ាតបថា ខ្លួនបានផ្តល់នូវប្រាតិភោគគ្រប់គ្រាន់ហើយ ឬ បានចាត់វិធានការណ៍ ដើម្បីរំលត់ការបារម្ភហើយ នោះតុលាការ ត្រូវច្រានចោលការទាមទាររបស់ **ក** នៅក្នុងសាលក្រម។

## ២.៤.៣. លក្ខណៈទៅវិញទៅមក នៅក្នុងអត្ថិភាពដែលត្រូវបានបន្ត

**ក. គោលគំនិតនៃការទទួលបន្ទុកហានិភ័យ**

ឧទាហរណ៍៖ **ក** បានលក់នាឡិកាមួយតម្លៃ ១០០ ដុល្លារអាមេរិកទៅអោយ **ខ**។ ប្រសិនបើ **ក** បានបំផ្លាញនាឡិកានោះដោយចេតនា។ តើ **ក** នឹងមានផលវិបាកយ៉ាងដូចម្តេច?

- ការអនុវត្តដោយបង្ខំ
- ទាមទារការខូចខាត
- ការរំលាយកិច្ចសន្យា

} ជាការសង្គ្រោះទូទៅដែល **ខ** ទាមទារបាន។

ករណីនាឡិកាបុរាណ មិនអាចជំនួសបាន ហើយជាវត្ថុជាក់លាក់

- **ខ** មិនអាចទាមទារការអនុវត្តដោយបង្ខំបានទេ
- **ខ** អាចទាមទារការខូចខាតបាន
- **ខ** អាចរំលាយកិច្ចសន្យាបាន

នៅក្នុងករណីដែល **ខ** ជ្រើសរើសយកការទាមទារសំណងនៃការខូចខាត កាតព្វកិច្ចក្នុងការប្រគល់វត្ថុដែល **ក** ត្រូវអនុវត្ត ត្រូវប្តូរទៅជាសងការខូចខាត។

នៅក្នុងករណីដែល មានកំហុសនៃការបំពានកិច្ចសន្យាធ្ងន់ធ្ងរ នោះ **ក** អាចរំលាយកិច្ចសន្យាបាន [36] និង ទាមទារសំណងនៃការខូចខាត ក៏ប៉ុន្តែមិនអាចទាមទារសំណងនៃការខូចខាតបានទេ។ ក៏ប៉ុន្តែ មិនអាចទាមទារសំណងនៃការខូចខាតបានទេ។[37] ហើយបន្ទាប់មក ចុះចំពោះករណីដែល **ក** មិនមានកំហុសចំពោះអលទ្ធភាពនៅក្នុងអនុវត្តកិច្ចសន្យា តើវា នឹងទៅជាយ៉ាងណា?

នៅក្នុងករណីនៃកិច្ចសន្យាទ្វេភាគី ភាគីទាំងសងខាង គឺមានកាតព្វកិច្ច និង សិទ្ធិទាមទារចំពោះគ្នា ទៅវិញទៅមក។

**ឧទាហរណ៍៖** អ្នកលក់ **ក** មានកាតព្វកិច្ចផ្ទេរកម្មវត្ថុ (**ក**) និង សិទ្ធិទាមទារអោយបង់ប្រាក់ (**គ**)។ ទន្ទឹមនឹងនេះ **ខ** មានកាតព្វកិច្ចបង់ប្រាក់ (**ឃ**) និងសិទ្ធិទាមទារអោយផ្ទេរ (**ខ**)។ នៅក្នុងទំនាក់ទំនងនេះ កាតព្វកិច្ចផ្ទេរ (**ក**) និង សិទ្ធិទាមទារអោយផ្ទេរ (**ខ**) ហើយនិង កាតព្វកិច្ចបង់ប្រាក់ (**ឃ**) និងសិទ្ធិទាមទារអោយបង់ប្រាក់ (**គ**) គឺដូចជា " មុខពីរនៅលើកាក់តែមួយ "។ ដូច្នេះ ប្រសិនបើកាតព្វកិច្ចផ្ទេរ (**ក**) ត្រូវរលត់ នោះ សិទ្ធិទាមទារ អោយផ្ទេរ (**គ**) ក៏ត្រូវរលត់ដែរ។

ដោយផ្អែកតាមមាត្រា ៤១៥ ប្រសិនបើកូនបំណុល គ្មានកំហុសចំពោះអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច នោះ កាតព្វកិច្ច ត្រូវរលត់ ហើយម្ចាស់បំណុលមិនអាចទាមទារតាវកាលិកបានទេ។ " **កូនបំណុល** " នៅទីនេះ សំដៅទៅលើបុគ្គល ដែលត្រូវទទួលបន្ទុកកាតព្វកិច្ចផ្ទេរកម្មវត្ថុ និង " **ម្ចាស់បំណុល** " សំដៅទៅលើភាគីម្ខាងទៀត។ ដូច្នេះប្រសិនបើ កម្មវត្ថុនៃកិច្ចសន្យាលក់ទិញ ត្រូវបានខូតខាតដោយគ្មានកំហុសរបស់ **ក** នោះ កាតព្វកិច្ចផ្ទេរ (**ក**) ត្រូវរលត់ ហើយ **ខ** មិនអាចទាមទារការផ្ទេរ (**ខ**) កម្មវត្ថុបានទៀតទេ។

បន្ទាប់មក តើវានឹងទៅជាយ៉ាងណាចំពោះតាវកាលិកតប? តើ **ក** អាចទាមទារ **ខ** បង់ប្រាក់បានដែរ ឬទេនៅក្នុងករណីខាងលើ? បញ្ហានៃ " បន្ទុកហានិភ័យ " សំដៅទៅលើ " តើនរណាដែលទទួលបន្ទុលហានិភ័យប្រសិនបើ កាតព្វកិច្ចផ្ទេរក្លាយជាអលទ្ធភាព? កូនបំណុល ឬម្ចាស់បំណុល? " ឬ និយាយម៉្យាងទៀត នៅក្នុងករណីដែលកម្មវត្ថុដែលត្រូវធ្វើការផ្ទេរ ត្រូវបានធ្វើអោយខូតខាត ដោយគ្មានកំហុសរបស់ភាគីទាំងសងខាង នោះ កាតព្វកិច្ចតប ត្រូវរលត់ ឬអត់។

ទាក់ទងនឹងចំណុចនេះ គឺមានគោលគំនិតចំនួនន ២

(១). គោលគំនិត ដែលតាវកាលិកតបត្រូវរលត់

នៅក្នុងករណីខាងលើ ប្រសិនបើកាតព្វកិច្ចបង់ប្រាក់របស់ **ខ** ត្រូវរលត់ នោះ**ខ** មិនបង់ប្រាក់ថ្លៃទិញទៀតទេ។ វាមានន័យថា **ក** គឺជាអ្នកបាត់បង់ផលប្រយោជន៍។ វាមានន័យថា **ក** ត្រូវទទួលបន្ទុកហានិភ័យ។

(២). គោលគំនិត ដែលតាវកាលិកតប មិនត្រូវបានរលត់

[36] មាត្រា ៤០៨ ក្រមរដ្ឋប្បវេណី

[37] មាត្រា ៣៩៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

ប្រសិនបើតាវកាលិកតប មិនត្រូវរលត់ **ខ** នៅតែមានកាតព្វកិច្ចបង់ប្រាក់ ទោះបីជាកម្មវត្ថុនៃកិច្ចសន្យាត្រូវបានធ្វើអោយខូចខាត និង អលទ្ធភាពក្នុងការផ្ទេរ ។ វាមានន័យថា ម្ចាស់បំណុលត្រូវទទួលបន្ទុកហានិភ័យ។ វាគឺអាស្រ័យទៅលើប្រភេទនៃកម្មវត្ថុដែលគំនិតត្រូវយកមកអនុវត្ត។

ដោយយោងទៅលើ មាត្រា ៤១៦ កថាខណ្ឌទី ១ ក្នុងកិច្ចសន្យាអញ្ញមញ្ញ ដែលមានអត្ថន័យផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់ ក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យា ត្រូវបានបាត់បង់ ឬ ខូចខាតដោយគ្មានកំហុសរបស់ភាគីទាំងសងខាងទេ កូនបំណុលត្រូវទទួលបន្ទុកហានិភ័យ។

ទន្ទឹមនឹងនេះ ដោយផ្អែកទៅលើមាត្រា ៤១៦ កថាខណ្ឌទី ២ ចំពោះហានិភ័យដោយសារការបាត់បង់ ឬ ខូចខាតវត្ថុជាកម្មវត្ថុនៃកិច្ចសន្យា ត្រូវផ្ទេរទៅម្ចាស់បំណុលនៅក្នុងលក្ខខណ្ឌកំណត់មួយចំនួន។ ឧទាហរណ៍ **ក** បានប្រគល់នាឡិកានៅផ្ទះរបស់ **ខ** តាមកាលបរិច្ឆេទកំណត់ ។ ក៏ប៉ុន្តែ **ខ** បដិសេធមិនព្រមយកនាឡិកានោះដោយមិនមានមូលហេតុត្រឹមត្រូវ។ ក្រោយមក នាឡិកានោះត្រូវបានធ្វើអោយខូចខាត ហើយកាតព្វកិច្ចប្រគល់ក្លាយជា អលទ្ធភាព។ ក្នុងករណីនេះ នៅពេលដែល **ក** បានប្រគល់នាឡិកា ហានិភ័យ ក៏ត្រូវបានផ្ទេរមកដែរដោយផ្អែកទៅលើ មាត្រា៤១៦ កថាខណ្ឌទី ២ ចំណុច **ខ**។ ដូច្នេះ **ខ** ត្រូវបង់ប្រាក់ថ្លៃទិញ ទោះបីជា **ខ** មិនបានទទួលយកនាឡិកាក៏ដោយ។

ជាងនេះទៅទៀត ដោយផ្អែកទៅលើ មាត្រា ៤១៨ កថាខណ្ឌទី ១ ចំពោះកិច្ចសន្យាអញ្ញមញ្ញ ដែលមានគោលបំណងផ្ទេរកម្មសិទ្ធិលើវត្ថុ ដែលមិនបានកំណត់ជាក់លាក់ ក្នុងករណីវត្ថុដែលត្រូវផ្តល់មិនទាន់បានកំណត់ ទោះបីជាវត្ថុដែលខ្លួន បានរៀបចំដើម្បីអនុវត្តបាត់បង់ដោយគ្មានកំហុសរបស់ខ្លួនក៏ដោយ ក៏កាតព្វកិច្ចនោះ មិនត្រូវរលត់ដែរ ។ ឬនិយាយម្យ៉ាងទៀត នៅក្នុងករណីនេះ កូនបំណុលត្រូវទទួលបន្ទុកហានិភ័យ។

# ជំពូកទី ៣

# ការរំលាយកិច្ចសន្យា

## ៣.១. ប្រភេទនៃការរំលាយកិច្ចសន្យា

ការរំលាយកិច្ចសន្យា សំដៅទៅលើ សកម្មភាពឯកតោភាគី ដែលធ្វើឱ្យភាគីទាំងសងខាងរួចផុតពីករណីកិច្ចរបស់ខ្លួន នៅក្នុងកិច្ចសន្យា លើកលែងតែករណីកិច្ចសងការខូចខាត។[38] ការរំលាយកិច្ចសន្យា ធ្វើឱ្យមានអានុភាពជាឯកតោភាគី ហើយមិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតទេ ព្រោះវា គឺជាសកម្មភាពឯកតោភាគី។[39]

### ៣.១.១. សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់ដោយនៅក្នុងច្បាប់

សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងច្បាប់ ត្រូវបានបញ្ញត្តិឡើងដោយមាត្រា ៤០៧ ដល់មាត្រា ៤១៣ នៃក្រមរដ្ឋប្បវេណី។ **ឧទាហរណ៍** នៅក្នុងករណីដែល លោក **ក** មិនបានប្រគល់នូវវត្ថុនៅក្នុងអំឡុងពេលសមរម្យ នៅក្រោយកាលបរិច្ឆេទទេ ទោះបីជាមានការដាស់តឿនរបស់ **ខ** នោះ **ខ** អាចលើកឡើងពីការរំលាយកិច្ចសន្យាបាន។ នៅក្នុងករណីនេះការរំលាយកិច្ចសន្យារបស់ **ខ** ត្រូវបានអនុវត្តដោយផ្អែកលើមាត្រា ៤០៨ កថាខណ្ឌ១ ចំណុច ក នៃក្រមរដ្ឋប្បវេណី។

### ៣.១.២. សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងកិច្ចសន្យា

សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងកិច្ចសន្យា គឺជាសិទ្ធិរំលាយកិច្ចសន្យា ដែលភាគីម្ខាង ឬសងខាង អាចរំលាយកិច្ចសន្យាបានដោយផ្អែកលើកិច្ចសន្យានោះផ្ទាល់តែម្តង។ **ឧទាហរណ៍** ប្រសិនបើភាគីបានធ្វើការព្រមព្រៀងគ្នា នៅក្នុងកិច្ចសន្យាជាមុនថា " អ្នកទិញ អាចរំលាយកិច្ចសន្យាជាឯកតោភាគី នៅពេលណាក៏បាន ក្នុងរយៈពេល ១សប្តាហ៍ ក្រោយពេលប្រគល់នូវកម្មវត្ថុ " ដូច្នេះ អ្នកទិញអាចរំលាយកិច្ចសន្យា បានតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យានោះផ្ទាល់តែម្តង។

អានុភាព ឬវិធីក្នុងការអនុវត្តសិទ្ធិរំលាយកិច្ចសន្យា គឺត្រូវអនុវត្តដូចគ្នាទៅនឹង សិទ្ធិរំលាយកិច្ចសន្យាដែលមានចែងនៅក្នុងច្បាប់ លើកលែងតែ ភាគី បានព្រមព្រៀងគ្នាផ្សេងពីនេះ។[40]

### ៣.១.៣. សិទ្ធិរំលាយកិច្ចសន្យា ដោយផ្អែកលើបញ្ញត្តិពិសេស

បញ្ញត្តិមួយចំនួននៅក្នុង កិច្ចសន្យាសំខាន់ៗ បានចែងអំពីសិទ្ធិរំលាយកិច្ចសន្យាពិសេស នៅក្នុងកិច្ចសន្យានីមួយៗ។

## ៣.២. ប្រព័ន្ធប្រហាក់ប្រហែល ទៅនឹងការរំលាយកិច្ចសន្យា

វាមានប្រព័ន្ធមួយចំនួន ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងការរំលាយកិច្ចសន្យា ប៉ុន្តែ វាមិនមែនជាការរំលាយកិច្ចសន្យានោះទេ។

---

[38] មាត្រា ៤១១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[39] មាត្រា ៣១២ នៃក្រមរដ្ឋប្បវេណី ២០០៧

[40] មាត្រា ៤១៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

### ៣.២.១. ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង

ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង មានន័យថាការរំលាយកិច្ចសន្យាដោយផ្អែកទៅលើ ការព្រមព្រៀងថ្មីរបស់ភាគី នៅក្នុងករណីដែលភាគី មិនបានចែងអំពីការរំលាយកិច្ចសន្យានេះ នៅក្នុងកិច្ចសន្យារបស់ខ្លួន។ **ឧទាហរណ៍** អ្នកទិញ **ខ** បានទាមទារអោយរំលាយកិច្ចសន្យាលក់ទិញ ជាមុន ដោយសារតែមានភាពលំបាកនៅក្នុងការប្រមូលប្រាក់ ហើយ **ក** ក៏បានយល់ព្រម។ នៅក្នុងករណីនេះ ការព្រមព្រៀងថ្មីដើម្បីរំលាយកិច្ចសន្យាត្រូវបានចាត់ទុកថា បានបង្កើតឡើង។ នៅក្នុងករណីនេះ ដែលផ្ទុយនឹងការរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងច្បាប់ **ខ** មិនអាចរំលាយកិច្ចសន្យា ដោយការបង្ហាញឆន្ទៈជាឯកតោភាគីបានឡើយ។ ការព្រមព្រៀងថ្មី ឬម្យ៉ាងទៀតត្រូវបានគេហៅថា កិច្ចសន្យាថ្មី ដែលខុសពីកិច្ចសន្យាចាស់ ត្រូវបានតម្រូវឱ្យមានដើម្បីរំលាយកិច្ចសន្យា។ ជាងនេះទៅទៀត ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង ដែលរំលាយកិច្ចសន្យាមុន ដោយការព្រមព្រៀងថ្មី មានលក្ខណៈខុសពីការរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងកិច្ចសន្យា ដែលត្រូវបានអនុវត្ត ដោយផ្អែកលើលក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ដែលបានព្រមព្រៀងគ្នា ជាមុន នៅក្នុងកិច្ចសន្យាដើម។

### ៣.២.២. ការលុបចោលកិច្ចសន្យា

នៅក្នុងករណីដែលកិច្ចសន្យា ត្រូវបានលុបចោល នោះកិច្ចសន្យា ត្រូវបានចាត់ទុកថា មោឃៈតាំងពីដំបូង។[41]

ការលុបចោលកិច្ចសន្យា និងការរំលាយកិច្ចសន្យា មានចំណុចដូចគ្នា ៖

i. ភាគីទាំងសងខាង ត្រូវបានរួចផុតពីកាតព្វកិច្ចនៅក្នុងកិច្ចសន្យា
ii. មានអានុភាពជាឯកតោភាគី ដោយសារវា គឺជាសកម្មភាពឯកតោភាគី

ក៏ប៉ុន្តែ សិទ្ធិរំលាយកិច្ចសន្យា កើតឡើង ដោយផ្អែកលើមូលហេតុនៃការបំពានកិច្ចសន្យាធ្ងន់ធ្ងររបស់ភាគីម្ខាងទៀត ក្រោយពីកិច្ចសន្យា ត្រូវបានបង្កើតឡើងដោយធម្មតា។ ផ្ទុយទៅវិញ ចំពោះការលុបចោលកិច្ចសន្យា មូលហេតុ (ការឆបោក ការបង្ខិតបង្ខំ ជាអាទិ៍ ) ត្រូវបានតម្រូវឱ្យមាននៅពេលបង្កើតកិច្ចសន្យា។

## ៣.៣. លក្ខខណ្ឌ និងវិធីអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យា

### ៣.៣.១. លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា

លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច មានដូចខាងក្រោមៈ [42]

a) នៅក្នុងកិច្ចសន្យាទ្វេភាគី
b) ភាគីម្ខាងបានបំពានកាតព្វកិច្ចយ៉ាងធ្ងន់ធ្ងរ។

វាមិនតម្រូវឱ្យការមិនអនុវត្តកាតព្វកិច្ចនេះ កើតឡើងដោយកំហុសនោះទេ។ ការបំពានកាតព្វកិច្ចធ្ងន់ធ្ងរត្រូវបានចាត់ទុកថា កើតមានឡើងប្រសិនបើវា ធ្លាក់ចូលទៅក្នុងចំណុចណាមួយទាំងបួនខាងក្រោម។ ដូច្នេះនៅពេលដែលបានអង្គហេតុណាមួយ ដែលបានបញ្ញត្តិ ត្រូវគេបានទទួលស្គាល់នោះ វាមិនអាចលុបចោលវិញបានឡើយ។ ម្យ៉ាងវិញទៀត ទោះជាអង្គហេតុមិនត្រូវនឹងចំណុច ដែលបានបញ្ញត្តិនៅក្នុងក្រម ក៏ដោយក៏គេនៅតែទទួលស្គាល់អង្គហេតុផ្សេងទៀតថា **ជាការបំពានកាតព្វកិច្ចធ្ងន់ធ្ងរ**។[43]

[41] មាត្រា ៣៥៨ ក.២ នៃក្រមរដ្ឋប្បវេណី

[42] មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី ២០០៧

[43] មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី ២០០៧

### ក. ការរំលាយកិច្ចសន្យាដោយមូលហេតុការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច

ភាគីម្ខាងបាន ដាស់តឿនភាគីម្ខាងទៀត ដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ដោយកំណត់អំឡុងពេលសមស្របដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនបានអនុវត្តនៅក្នុងអំឡុងពេលនោះភាគី អាចរំលាយកិច្ចសន្យាបានភ្លាម។

**ឧទាហរណ៍៖ ក** បានចុះកិច្ចសន្យាលក់ឡានជាមួយ **ខ** ហើយ **ក** ប្រគល់ឡានទៅឱ្យ **ខ**។ ក៏ប៉ុន្តែ **ខ**មិនបានបង់ប្រាក់ថ្លៃទិញទៅឱ្យ **ក** នាកាលបរិច្ឆេទឡើយទេ។ នៅក្នុងករណីនេះ ប្រសិនបើ **ក** ដាស់តឿន **ខ** ឱ្យបង់ប្រាក់ថ្លៃទិញ ដោយកំណត់អំឡុងពេលសមរម្យសំរាប់អនុវត្តកាតព្វកិច្ច ហើយ **ខ** មិនបានបង់ប្រាក់ថ្លៃទិញនៅក្នុងអំឡុងពេលនោះ **ក** អាចរំលាយកិច្ចសន្យាបាន។

លក្ខខណ្ឌនោះមានចំនួន ៣ ដូចខាងក្រោម ៖

- កូនបំណុល មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន តាមពេលកំណត់
- ម្ចាស់បំណុល ដាស់តឿនភាគី ដែលមិនអនុវត្តកាតព្វកិច្ចឱ្យអនុវត្តកាតព្វកិច្ច ដោយកំណត់អំឡុងពេលសមរម្យសម្រាប់អនុវត្ត
- កូនបំណុលមិនអនុវត្តកាតព្វកិច្ច នៅក្នុងអំឡុងពេលសមរម្យ។

1) កូនបំណុល មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន តាមពេលកំណត់

តាម**ឧទាហរណ៍** ខាងលើគឺ **ខ** មិនបានបង់ថ្លៃទិញតាមពេលកំណត់។

ទាក់ទងនឹងលក្ខខណ្ឌនេះ វាមានភាពចាំបាច់ ដែលការអនុវត្តកាតព្វកិច្ច គឺអាចអនុវត្តទៅបាន។ ប្រសិនបើកូនបំណុល មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដោយសារតែអលទ្ធភាពនៃការអនុវត្តនោះវា គឺជាបញ្ហា។[44]

2) ម្ចាស់បំណុល បានដាស់តឿនភាគី ដែលមិនអនុវត្តកាតព្វកិច្ចឱ្យអនុវត្តកាតព្វកិច្ច ដោយកំណត់ក្នុងពេលសមរម្យ សម្រាប់អនុវត្តៈ

នៅក្នុងករណីខាងលើ ប្រសិនបើ **ខ** មិនបានបង់ប្រាក់ថ្លៃទិញ នៅកាលបរិច្ឆេទទេ **ក** ត្រូវដាស់តឿន **ខ** ឱ្យបង់ប្រាក់ថ្លៃទិញ ដោយកំណត់អំឡុងពេលសមរម្យ។

3) កូនបំណុលមិនអនុវត្តកាតព្វកិច្ច នៅអំឡុងពេលដែលបានដាស់តឿនៈ

នៅពេលដែល **ខ** មិនបានបង់ប្រាក់ថ្លៃទិញ នៅកាលបរិច្ឆេទកំណត់ទេ **ក** ត្រូវដាស់តឿនឱ្យ **ខ** អនុវត្តកាតព្វកិច្ច ដោយកំណត់អំឡុងពេលសមរម្យមួយ។ នៅក្នុងករណីដែល **ខ** នៅតែមិនអនុវត្តកាតព្វកិច្ច នៅក្នុងអំឡុងពេលសមរម្យ ដែលបានដាស់តឿននោះទេ **ក** អាចរំលាយកិច្ចសន្យាបាន។

ចំពោះលក្ខខណ្ឌទី ២ វាគឺជាបញ្ហាថាតើ ត្រូវដោះស្រាយ ដែលទាក់ទងជាមួយការយឺតយ៉ាវនៃការអនុវត្តកាតព្វកិច្ចយ៉ាងដូចម្តេច។ ប្រសិនបើមានមូលហេតុត្រឹមត្រូវចំពោះការយឺតយ៉ាវ កូនបំណុល មិនស្ថិតនៅក្នុងស្ថានភាពយឺតយ៉ាវទេ។ **ឧទាហរណ៍ ក** បានលក់រថយន្តទៅឱ្យ **ខ** ហើយពួកគេ បានកំណត់កាលបរិច្ឆេទ។ នៅកាលបរិច្ឆេទ **ក** មិនបានប្រគល់រថយន្តរបស់ខ្លួនទេ ដោយសារតែ **ខ** មិនបានស្នើផ្តល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នៅក្នុងករណីនេះ ទាំង **ក** និង **ខ** មិនត្រូវស្ថិតនៅក្នុងភាពយឺតយ៉ាវទេ ទោះបីជាគាត់ មិនបានប្រគល់រថយន្តដោយសារការតវ៉ាឱ្យអនុវត្តព្រមគ្នា។[45] ដូច្នេះ **ក** ត្រូវស្នើផ្តល់ការអនុវត្តកាតព្វកិច្ច ដើម្បីធ្វើឱ្យ **ខ**ស្ថិតនៅក្នុងស្ថាន

[44] មាត្រា ៤០៨ ក.១ ចំណុច គ នៃក្រមរដ្ឋប្បវេណី ២០០៧

[45] មាត្រា ៣៨៦ នៃក្រមរដ្ឋប្បវេណី ២០០៧

ភាពយឺតយ៉ាវ ប្រសិនបើ **ក** ចង់រំលាយកិច្ចសន្យា។ បន្ទាប់មក តើ **ក** ត្រូវស្នើផ្តល់ការអនុវត្តកាតព្វកិច្ចដើម្បី ធ្វើឱ្យ **ខ** ស្ថិតនៅក្នុងស្ថានភាពយឺតយ៉ាវ? តើ **ក** ត្រូវធ្វើការដាស់តឿនឱ្យអនុវត្តកាតព្វកិច្ចដោយកំណត់អំឡុងពេលសមរម្យ នៅពេលផ្សេងគ្នា?

* តើតម្រូវឱ្យ **ក** ត្រូវស្នើផ្តល់ ការអនុវត្តកាតព្វកិច្ច និងដាស់តឿន ឱ្យអនុវត្តកាតព្វកិច្ច ដោយដាច់ពីគ្នា?

ចំពោះការបកស្រាយគេអាចគិតថា ម្ចាស់បំណុល អាចរំលាយកិច្ចសន្យាបាន ក្រោយពេលការស្នើផ្តល់ការអនុវត្តកាតព្វកិច្ច ដើម្បីកូនបំណុល ស្ថិតនៅក្នុងភាពយឺតយ៉ាវ ហើយក្រោយមកដាស់តឿនឱ្យអនុវត្តកាតព្វកិច្ច។

ហើយម្យ៉ាងទៀត គេអាចគិតថា ម្ចាស់បំណុល អាចដាស់តឿនឱ្យអនុវត្តកាតព្វកិច្ច ស្របពេលជាមួយនឹងការស្នើផ្តល់ការអនុវត្តកាតព្វកិច្ច ព្រោះមាត្រានេះបានបញ្ញត្តិថា កាតព្វកិច្ចមិនត្រូវអនុវត្ត នៅអំឡុងពេលនោះមិនមែនករណីដែលកូនបំណុល ស្ថិតក្នុងភាពយឺតយ៉ាវទេ។

ដោយផ្អែកលើគំនិតនេះ ម្ចាស់បំណុល មិនចាំបាច់ដាស់តឿនឱ្យអនុវត្តកាតព្វកិច្ច ក្នុងអំឡុងពេលសមរម្យពីការស្នើផ្តល់ការអនុវត្តកាតព្វកិច្ច ព្រោះ តាមរយៈការកំណត់អំឡុងពេលសមរម្យ គឺដើម្បីផ្តល់ឱកាសចុងក្រោយដល់កូនបំណុល ថាតើគាត់ អនុវត្តកាតព្វកិច្ចដែរ ឬទេ។

* **ក** អាចស្នើផ្តល់ការអនុវត្តកាតព្វកិច្ច និង ដាស់តឿនឱ្យ **ខ** អនុវត្តកាតព្វកិច្ច នៅពេលជាមួយគ្នា។

ហើយបន្ទាប់មក តើរយៈពេលប៉ុន្មាន ដែលត្រូវចាត់ទុកថា អំឡុងពេលសមរម្យ? វា មានគំនិតមួយចំនួន ។ គំនិតមួយនៅក្នុងចំណោមគំនិតទាំងនេះ គឺជាគំនិតដែលអំឡុងពេលសមរម្យ សំដៅទៅលើអំឡុងពេល ដែលសម្រាប់តម្រូវ ឱ្យរៀបចំ និងអនុវត្តកាតព្វកិច្ច ក្រោយពីការដាស់តឿនរបស់ **ក**។ គំនិតមួយទៀត គឺថា គ្រាន់តែតម្រូវឱ្យមានអំឡុងពេលសម្រាប់អនុវត្តកាតព្វកិច្ច គឺគ្រប់គ្រាន់ហើយ ដោយផ្អែកលើមូលហេតុថា **ខ**បានបញ្ចប់នូវការរៀបចំរបស់ខ្លួនហើយ។

ដោយផ្អែកលើគំនិតទី២ វាមិនមានភាពចាំបាច់ នៅក្នុងការការពារកូនបំណុល ដែលមិនគោរពកិច្ចសន្យាហើយ សូម្បីតែគាត់ មិនបានទាំងរៀបចំដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ **ឧទាហរណ៍ ក** បានចុះកិច្ចសន្យាលក់ ទូរទស្សន៍ចំនួន ១០ គ្រឿង ដែលជាវត្ថុមិនជាក់លាក់ ឱ្យទៅ **ខ** ប៉ុន្តែ **ក** មិនបានប្រគល់ទូរទស្សន៍នោះ នៅកាលបរិច្ឆេទទេ។ បន្ទាប់មក **ខ** បានដាស់តឿនឱ្យ **ក** អនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នៅក្នុងករណីនេះ អំឡុងពេលសមរម្យត្រូវសម្រេច ឱ្យផ្អែកលើចំណុចថា **ក** បានបញ្ចប់ការទុកដាក់កម្មវត្ថុដាច់ដោយឡែក ពីវត្ថុដទៃទៀតហើយ និងបានបញ្ចប់នូវការរៀបចំដើម្បីប្រគល់ទៀតផង។

### ខ. ការរំលាយកិច្ចសន្យាដោយសារការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ក្នុងករណីដែលពេលវេលា គឺជាចំណុចសំខាន់

នៅក្នុងករណីដែលគោលបំណងនៃកិច្ចសន្យា មិនបានសំរេច ប្រសិនបើការអនុវត្តកាតព្វកិច្ច មិនត្រូវបានបំពេញ នៅក្នុងពេលកំណត់នោះ វា ត្រូវបានគេចាត់ទុកថាជា ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ប្រសិនបើកូនបំណុលមិនបានបំពេញកាតព្វកិច្ចនៅពេលកំណត់នោ។

នៅក្នុងចំណុចនេះវា មានកិច្ចសន្យា ២ប្រភេទ ៖

**ប្រភេទទី ១** គឺកិច្ចសន្យាដែលមានគោលបំណងរបស់វា មិនអាចសម្រេចបានសោះ តាមលក្ខណៈរបស់កិច្ចសន្យានោះ ប្រសិនបើការអនុវត្តកាតព្វកិច្ច មិនត្រូវបានធ្វើឡើង នៅក្នុងពេលកំណត់។

**ឧទាហរណ៍៖ ក** បញ្ជារឱ្យជាងកាត់សំលៀកបំពាក់ **ខ** កាត់សំលៀកបំពាក់អាពាហ៍ពិពាហ៍ សម្រាប់ស្លៀកក្នុងពិធីរៀបអាពាហ៍ពិពាហ៍ នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១០ ។ ប៉ុន្តែដល់ថ្ងៃទី ០៧ ខែ វិច្ឆិកា មកដល់ហើយ ជាងកាត់សំលៀកបំពាក់ មិនទាន់ដេររួចរាល់ទៀត។ ក្នុងករណីនេះ **ក** អាចរំលាយកិច្ចសន្យាបានដោយសារ **ខ** បានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ វាមានលក្ខណៈច្បាស់លាស់ថា គោលបំណងនៃកិច្ចសន្យានេះ មិនត្រូវបានសម្រេច ប្រសិនបើការអនុវត្តកាតព្វកិច្ច មិនត្រូវបានធ្វើឡើង តាមលក្ខណៈនៃខ្លឹមសារនៃកិច្ចសន្យា។

**ប្រភេទ ១ទៀត** គឺជាកិច្ចសន្យា ដែលត្រូវអនុវត្តកាតព្វកិច្ច នៅក្នុងពេលកំណត់ ដោយស្របទៅតាមឆន្ទៈរបស់ភាគី។

**ឧទាហរណ៍៖ ក** បានបញ្ជារទិញស្រាបៀរជាច្រើនកេស សម្រាប់ពិធីជប់លៀងពេលល្ងាចរបស់ខ្លួន ប៉ុន្តែឈ្មួញលក់ស្រាបៀរ **ខ** មិនអាចប្រគល់ស្រាបៀរនោះ នៅថ្ងៃនៃពិធីជប់លៀង។ នៅក្នុងករណីនេះ **ក** ចាំបាច់ត្រូវប្រាប់ថាគាត់ ត្រូវការស្រាបៀរជាច្រើនកេស នៅថ្ងៃណាមួយជាក់លាក់ ដើម្បីអះអាងថា វាត្រូវចាត់ទុកជាការបំពានកិច្ចសន្យាធ្ងន់ធ្ងររបស់ **ខ** ព្រោះវា មិនមានភាពច្បាស់លាស់ទេថា គោលបំណងនៃកិច្ចសន្យានេះ មិនត្រូវបានសម្រេច ប្រសិនបើការអនុវត្តកាតព្វកិច្ច មិនត្រូវបានធ្វើឡើងនៅកាលបរិច្ឆេទកំណត់។

ប្រសិនបើ **ក** បានប្រាប់ថា គាត់ត្រូវការស្រាបៀរជាច្រើនកេស នៅថ្ងៃជប់លៀង ទោះបីជា **ខ** អនុវត្តកាតព្វកិច្ចរបស់ខ្លួន នៅពេលក្រោយមកក៏ដោយ ក៏វា គ្មានប្រយោជន៍សម្រាប់ម្ចាស់បំណុលដែរ។ ដូច្នេះម្ចាស់បំណុល អាចរំលាយកិច្ចសន្យាបានភ្លាម ក្រោយពេលកំណត់នោះ។

### គ. ការរំលាយកិច្ចសន្យាដោយមូលហេតុអលទ្ធភាពនៃការអនុវត្តកាតព្វកិច្ច

ភាគី មិនអាចអនុវត្តករណីកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបាន ភាគីម្ខាងទៀត អាចរំលាយកិច្ចសន្យាបាន។[46]

**តាវកាលិកចម្បង** គឺជាសកម្មភាព ដែលភាគី មិនអាចសម្រេចគោលបំណងនៃកិច្ចសន្យា ប្រសិនបើតាវកាលិកនោះ មិនត្រូវបានផ្តល់ឱ្យ។

តាវកាលិកចម្បង ត្រូវតែសម្រេចដោយផ្អែកលើលក្ខណៈ ឬខ្លឹមសារនៃកិច្ចសន្យា និងឆន្ទៈរបស់គូភាគី។

**ឧទាហរណ៍** ប្រសិនបើ **ក** ចុះកិច្ចសន្យាលក់ ទិញរថយន្តជាមួយ **ខ** ។ **ក** គឺជាអ្នកលក់ ហើយ **ខ** គឺជាអ្នកទិញ។ ក្រោយបង្កើតកិច្ចសន្យារួច **ខ** បានបង់ថ្លៃលក់រថយន្តទៅឱ្យ **ក** ក៏ប៉ុន្តែ ម៉ាស៊ីនរបស់រថយន្តនោះ គឺខូចដោយសារទឹកជំនន់ នៅមុនពេលប្រគល់។

នៅក្នុងករណីនេះ ទោះបីជារថយន្ត ស្ថិតក្នុងទ្រង់ទ្រាយដើមក៏ដោយ ក៏កាតព្វកិច្ច ក្លាយជាលទ្ធភាពដែរ ព្រោះ **ខ** មិនអាចបើករថយន្តនោះ បានទៀតទេ។ ដូច្នេះ **ខ** អាចរំលាយកិច្ចសន្យាទិញ លក់នោះបានភ្លាម ព្រោះថា **ក** មិនអាចប្រគល់រថយន្ត ដែលជាតាវកាលិកចម្បងនៃកិច្ចសន្យាទិញលក់ទៅឱ្យ **ខ** បាន។

ផ្ទុយទៅវិញនៅក្នុងករណីដែល មានកាតព្វកិច្ចបន្ទាប់បន្សំ ក្រៅពីកាតព្វកិច្ចចម្បងនោះ ម្ចាស់បំណុលមិនអាចរំលាយកិច្ចសន្យា ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ទោះបីជាកូនបំណុល មិនបានអនុវត្តកាតព្វកិច្ចបន្ទាប់បន្សំ។

**ឧទាហរណ៍ ក** បានចុះកិច្ចសន្យាលក់ដីរបស់ខ្លួន ឱ្យទៅ **ខ** បានព្រមព្រៀងគ្នាថា **ក** ត្រូវបង់ថ្លៃចុះបញ្ជី។ ក្រោយពីការបង្កើតកិច្ចសន្យា **ខ** បានបង់ថ្លៃចុះបញ្ជីជំនួស **ក** ប៉ុន្តែ **ក** មិនបានបង់ថ្លៃចុះបញ្ជីនេះ ទៅឱ្យ **ខ** ទេ។

[46] មាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច .គ. នៃក្រមរដ្ឋប្បវេណី ២០០៧

នៅក្នុងករណីនេះ ការបង់ថ្លៃចុះបញ្ជី គឺជាកាតព្វកិច្ចបន្ទាប់បន្សំ ដូច្នេះគេ អាចគិតពិចារណាថា ខ មិនអាចរំលាយកិច្ចសន្យា ដោយផ្អែកទៅលើមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច។

**ឃ. ការរំលាយកិច្ចសន្យាដោយមូលហេតុបាត់បង់ជំនឿចិត្តរវាងគូភាគី**

បើការបំពានកិច្ចសន្យា មានភាពហួសហេតុ ដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាពេលអនាគតបាន ភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យាបាន។[47]

ក៏ប៉ុន្តែ ការរំលាយកិច្ចសន្យាប្រភេទនេះ គឺពុំមានភាពច្បាស់លាស់ឡើយ។ ទំនាក់ទំនងនៃទំនុកចិត្តនៅក្នុងកិច្ចសន្យា មានខុសគ្នា ចាប់ពីកិច្ចសន្យាលក់ទិញធ្វើឡើងដោយការជួបគ្នាទល់មុខ ដែលទំនាក់ទំនងនៃទំនុកចិត្តគឺមិនមានសារៈសំខាន់ រហូតដល់ កិច្ចសន្យាលក់ទិញបន្តបន្ទាប់ ឬ កិច្ចសន្យាម៉ៅការ ដែលផ្អែកទៅលើទំនាក់ទំនងយ៉ាងខ្លាំង។

**ឧទាហរណ៍ ក** បានលក់វត្ថុធាតុដើមសម្រាប់ផលិតផល ទៅឱ្យ **ខ** ជាបន្តបន្ទាប់ ហើយ **ខ** បានផលិតនូវផលិតផលរបស់ខ្លួនពីវត្ថុធាតុដើមនោះ។ **ក** ផ្គត់ផ្គង់នូវវត្ថុធាតុដើមនោះ មានការយឺតយ៉ាវ ២ ទៅ ៣ ថ្ងៃជារឿយៗ ហើយជាលទ្ធផលគឺ **ខ** មិនអាចផលិតនូវផលិតផលរបស់ខ្លួនបានដែរ កើតមានជាញឹកញាប់។ វាមាន លក្ខណៈលំបាកសម្រាប់ **ខ** ក្នុងការរក្សានូវទំនុកចិត្តជាមួយ **ក** ទោះបីជា ការបំពានកិច្ចសន្យាម្តងៗ មិនមានលក្ខណៈធ្ងន់ធ្ងរក៏ដោយ។ ដូច្នេះ **ខ** អាចរំលាយកិច្ចសន្យា ដោយសារតែការបាត់បង់ជំនឿចិត្តរវាងគូភាគី។

ចំពោះការរំលាយកិច្ចសន្យាប្រភេទនេះ ច្រើនកើតមាននៅលើកិច្ចសន្យា ដែលធ្វើរវាងភតិកៈ និងភតិបតី (ភតិសន្យា)។

**ឧទាហរណ៍** ក្នុងការបង់ថ្លៃឈ្នួលជាដើម ហើយប្រសិនបើការខកខានបង់ប្រាក់ឈ្នួល ០១ ដង ឬ ០២ដង យើងអាចបកស្រាយថាមិនមែនជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរទេ ( ដូច្នេះ ភតិបតី មិនអាចរំលាយកិច្ចសន្យាបានឡើយ)។ ប៉ុន្តែបើ ភតិកៈ មិនបានបង់ថ្លៃឈ្នួល ដែលមានចំនួន ០៤ ដង ឬ ០៥ ដង យើង អាចបកស្រាយបានថាជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរ (ដូច្នេះ ភតិបតី អាចរំលាយកិច្ចសន្យាបាន)។ ជាការអនុវត្តនៅប្រទេសជប៉ុន ការមិនបង់ប្រាក់ឈ្នួល មានចំនួន ០៦ ដងទើបចាត់ទុកថាបានបំពានកិច្ចសន្យាធ្ងន់ធ្ងរ។

### ៣.៣.២. វិធីអនុវត្តរំលាយកិច្ចសន្យា

ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យាបាន ដោយបង្ហាញឆន្ទៈរំលាយ ចំពោះភាគីម្ខាងទៀតបាន [48]

- ការបង្ហាញឆន្ទៈ អាចធ្វើនៅក្រៅតុលាការបាន និង ក្នុងតុលាការក៏បាន។ ដោយសារតែវា អាចជាបន្ទុកការងារដ៏ច្រើន ប្រសិនបើភាគី អាចរំលាយកិច្ចសន្យាបានតែតាមផ្លូវតុលាការនោះ។
- ការបង្ហាញឆន្ទៈរំលាយ មិនដកវិញបានទេ។ ប្រសិនបើភាគី អាចដកឆន្ទៈនៃការរំលាយកិច្ចសន្យានោះ អានុភាពនៃកិច្ចសន្យា នឹងត្រូវផ្លាស់ប្តូរហើយជាលទ្ធផល ឋានៈរបស់ភាគីម្ខាងទៀត ឬ ភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធ នឹងក្លាយជាអស្ថេរភាព។ ក៏ប៉ុន្តែ គេអាចចាត់ទុកថា ជនដែលមានសិទ្ធិរំលាយអាចដកនូវឆន្ទៈរំលាយ

[47] មាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមរដ្ឋប្បវេណី ២០០៧

[48] មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី ២០០៧

កិច្ចសន្យាបាន នៅក្នុងករណីដែល ការជូនដំណឹងពីការដកឆន្ទៈ បានដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នា ឬមុនពេលឆន្ទៈរំលាយព្រោះ ការរំលាយ មានអានុភាព នៅពេលដែលវាបានដល់។

• ការបង្ហាញឆន្ទៈរំលាយ អាចដាក់លក្ខខណ្ឌបង្អង់បាន។ លក្ខខណ្ឌ សំដៅទៅលើព្រឹត្តការណ៍ដែលកើតឡើងនាពេលអនាគត ហើយមិនទៀតទាត់។[49]

## ៣.៤. អានុភាព និងការរលត់នូវសិទ្ធិនៃការរំលាយកិច្ចសន្យា

ក្រោយពេលភាគីបង្ហាញឆន្ទៈរំលាយកិច្ចសន្យា នោះកិច្ចសន្យាត្រូវបញ្ចប់នូវអានុភាព មានន័យថា កាតព្វកិច្ចដែលមិនទាន់អនុវត្តត្រូវរលត់ ហើយគ្មានភាពចាំបាច់ត្រូវអនុវត្ត។[50] ប្រសិនបើកិច្ចសន្យាមួយត្រូវ បានរំលាយ ចំណងកិច្ចសន្យានេះនឹងត្រូវរលត់។ ការរំលាយកិច្ចសន្យានឹងរលត់នូវរាល់កាតព្វកិច្ចទាំងឡាយរបស់ភាគីដែលកើតឡើងដោយកិច្ចសន្យា និងនាំឱ្យភាគីរួចផុតពីកិច្ចសន្យានោះ។ ប៉ុន្តែ ក្នុងករណីរំលាយកិច្ចសន្យា ដោយមូលហេតុមកពីការមិនអនុវត្តន៍កាតព្វកិច្ច នោះករណីកិច្ចសងសំណងការខូចខាតរបស់កូនបំណុលដែល មិនអនុវត្តកាតព្វកិច្ចនៅតែមានអានុភាព។[51]

គេបានធ្វើការចាត់ថ្នាក់កិច្ចសន្យាដែលមានទំនាក់ទំនងជាមួយនឹងអានុភាពប្រតិសកម្មជាពីរចំណាត់ថ្នាក់ គឺ កិច្ចសន្យាអនុវត្តម្តងចប់ និងកិច្ចសន្យាដែលអនុវត្តបន្តបន្ទាប់។ ដោយអានុភាពនៃការរំលាយកិច្ចសន្យាអនុវត្តចប់តម្រូវឱ្យមានអានុភាពប្រតិសកម្ម រីឯអានុភាពនៃកិច្ចសន្យាអនុវត្តបន្តបន្ទាប់ មិនមានអានុភាពប្រតិសកម្មជាចាំបាច់នោះទេ។ នេះក៏ព្រោះតែការអនុវត្តន៍កាតព្វកិច្ចជាបន្តបន្ទាប់វាធ្វើឱ្យភាគីម្ខាង ខាតបង់ច្រើនបើសិនជាតម្រូវឱ្យមានការបដិទានឡើងវិញ។

**ឧទាហរណ៍៖** កិច្ចសន្យាជួលដែល ភតិបតី បានជួលផ្ទះឱ្យ ភតិកៈ កំណត់៥ឆ្នាំ ប៉ុន្តែភតិកៈ នៅបានតែ១ឆ្នាំក៏ឈប់បង់ប្រាក់ទៅឱ្យភតិបតីទៀត ដែលជាហេតុធ្វើឱ្យភតិបតីរំលាយកិច្ចសន្យាចោល។ នៅក្នុងករណីនេះ បើសិនជាអនុវត្តនាំឱ្យមានអានុភាពប្រតិសកម្មនោះនាំឱ្យភតិបតីត្រូវសងនូវប្រាក់ឈ្នួលផ្ទះដែលខ្លួនទទួលបានទៅឱ្យភតិកៈវិញ ព្រោះវាគ្មានកិច្ចសន្យាតាំងពីដំបូង រីឯភតិបតីវិញមានសិទ្ធិត្រឹមតែ ទាមទារឱ្យបដិទានផ្ទះឱ្យដូចដើមវិញ និងទាមទារសំណងការខូចខាតដោយការបំពានកិច្ចសន្យាប៉ុណ្ណោះ។

### ៣.៤.១. ទ្រឹស្តីអានុភាពនៃការរំលាយកិច្ចសន្យា

អានុភាពដែលកើតចេញពីការរំលាយកិច្ចសន្យា គឺមានដូចខាងក្រោម ៖[52]

a) ការរំលាយកិច្ចសន្យានាំឱ្យគូភាគីរួចផុតពី ករណីកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីកិច្ចសងការខូចខាត។

b) គូភាគី មានកាតព្វកិច្ច ធ្វើបដិទានឡើងវិញទៅស្ថានភាពដើមរបស់ភាគីម្ខាងទៀត។

---

[49] មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី ២០០៧

[50] សាស្ត្រាចារ្យ UMEMOTO YUMI , ការរំលាយកិច្ចសន្យា , (ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់ , នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ) ទំព័រទី ៣៨

[51] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២គន្ថីទី ៤,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ៤០៩, ទំព័រ ១២៩

[52] មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី ២០០៧

c) ភាគី ត្រូវសងប្រាក់ជាមួយនឹងការប្រាក់ ឬបង្វិលវត្ថុជាមួយនឹងផលប្រយោជន៍ ដែលបានទទួលពីកម្មវត្ថុនោះ ។

ក៏ប៉ុន្តែ វាមិនមានបញ្ញត្តិណាមួយ ដែលចែងច្បាស់ថា ហេតុអ្វី បានជាអានុភាពទាំងនេះកើតឡើង។

ចំពោះអានុភាពនៃការរំលាយកិច្ចសន្យានេះ មានគំនិត ២ ដែលគំនិតទី ១ ដែលទទួលស្គាល់អានុភាព នៃការរំលាយកិច្ចសន្យា មានអានុភាពប្រតិសកម្ម ( គំនិត ១ ) នឹងគំនិតមួយទៀត គឺមិនទទួលស្គាល់អានុភាព នៃការរំលាយកិច្ចសន្យា មានអានុភាពប្រតិសកម្ម (គំនិត ២ )។

**ក. អានុភាពប្រតិសកម្ម** ( **គំនិត ១** )

ផ្អែកតាមគំនិតនេះ នៅក្នុងករណីដែលកិច្ចសន្យា ត្រូវបានរំលាយ វាត្រូវបានចាត់ទុក គ្មានកិច្ចសន្យាតាំងពីដំបូង ។ ដូច្នេះ ប្រសិនបើភាគី បានទទួលតាវកាលិក នៅមុនពេលរំលាយ គាត់ត្រូវធ្វើបដិទានឡើងវិញទៅស្ថានភាពដើមរបស់ភាគីម្ខាងទៀត ដោយផ្អែកលើសេចក្តីចម្រើនឥតហេតុ។

នៅក្នុងករណីសេចក្តីចម្រើនឥតហេតុ កាតព្វកិច្ចត្រូវសងជាទូទៅ ត្រូវបានកម្រិតត្រឹមតែផលប្រយោជន៍ដែលទទួលបាន។[53] ឧទាហរណ៍ នៅក្នុងករណីដែល **ខ** បានទិញអង្ករ ១០ គីឡូក្រាមពី **ក** នៅក្នុងតម្លៃ ១០០ ដុល្លារ ហើយ បានបង់ប្រាក់ ៥០ ដុល្លារ។ ក្រោយមកនៅពេលដែល **ខ** បានបរិភោគអង្ករអស់ ៤ គីឡូក្រាម **ក** បានរំលាយកិច្ចសន្យា ព្រោះ **ខ** មិនបានបង់ប្រាក់ ៥០ ដុល្លារទៀត ។ កាតព្វកិច្ចដែល **ខ** ត្រូវសង ក្នុងករណីសេចក្តីចម្រើនឥតហេតុ ត្រូវបានកម្រិតត្រឹម ៦ គីឡូក្រាម។[54] ក៏ប៉ុន្តែ នៅក្នុងករណីនៃការរំលាយកិច្ចសន្យា **ខ** ត្រូវមានកាតព្វកិច្ចធ្វើបដិទានទៅស្ថានភាពដើមរបស់ **ក**។[55] នៅក្នុងករណីនេះ **ខ** ត្រូវសង ៤០ ដុល្លារ ចំពោះអង្ករ ដែលបានបរិភោគ ឬ គេអាចពិចារណាថា **ខ** ត្រូវសងអង្ករ ៤ គីឡូក្រាម ដែលមានគុណភាពដូចគ្នា ព្រោះ កម្មវត្ថុដើម គឺជាវត្ថុ ដែលមិនត្រូវបានកំណត់ជាក់លាក់។

ដូច្នេះ ដោយផ្អែកលើគំនិត ១ ទំហំនៃកាតព្វកិច្ចដែលត្រូវបដិទាន ត្រូវបានពន្លាតចាប់ពី ផលប្រយោជន៍ទៅត្រឹមកម្រិតដែលផលប្រយោជន៍នោះមាន [56] រហូតដល់ធ្វើបដិទានទៅស្ថានភាពដើមរបស់ភាគី។[57]

**ទំនាក់ទំនងជាមួយការផ្ទេរកម្មសិទ្ធិ**

ដោយផ្អែកតាមគំនិត ១ ការផ្ទេរកម្មសិទ្ធិត្រូវរលត់ ដោយប្រតិសកម្ម ព្រោះការរំលាយ មានអានុភាពប្រតិសកម្ម។

ឧទាហរណ៍ **ក** បានធ្វើកិច្ចសន្យាលក់រថយន្តឱ្យទៅ **ខ** ហើយ **ក** បានប្រគល់ទៅឱ្យ **ខ** ប៉ុន្តែ ដល់ពេលបង់ថ្លៃលក់ **ខ** ខកខានមិនបានបង់ថ្លៃលក់មកឱ្យ **ក** ទោះបីជាមានការដាស់តឿនរបស់ **ក** ក៏ដោយ។ ហើយ **ក**បានរំលាយកិច្ចសន្យា។ គំនិតនេះ ទទួលស្គាល់ថា ការរំលាយកិច្ចសន្យា មានអានុភាពប្រតិសកម្ម។ ដូច្នេះអ្នកទិញ **ខ** មិនមែនជាកម្មសិទ្ធិករ តាំងពីដំបូងដោយសារការរំលាយកិច្ចសន្យា។ ឬនិយាយម្យ៉ាងទៀត កម្មសិទ្ធិ មិនត្រូវប្រគល់ត្រលប់ពី **ខ** ទៅ **ក** ទេ។ វាមានន័យថា **ក** ត្រូវបានចាត់ទុកថា ជាកម្មសិទ្ធិតាំងពីដំបូង។ ដូច្នេះ **ក** អាចទាមទារឱ្យប្រគល់រថយន្តមកវិញ ដោយផ្អែកលើកម្មសិទ្ធិ ប្រសិនបើ **ខ** កាន់កាប់រថយន្តនោះ។

---

[53] មាត្រា ៧៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[54] មាត្រា ៧៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[55] មាត្រា ៤១១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

[56] មាត្រា ៧៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[57] មាត្រា ៤១១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

**ខ. អានុភាពមិនប្រតិសកម្ម ( គំនិត ២)**

ផ្អែកតាមគំនិតនេះ ការរំលាយកិច្ចសន្យា ត្រូវបានចាត់ទុកថា គ្មានអានុភាពប្រតិសកម្ម។ ដូច្នេះ សិទ្ធិលើបំណុល និងកាតព្វកិច្ចដើមត្រូវផ្លាស់ប្តូរទៅជាសិទ្ធិទាមទារ និងកាតព្វកិច្ចធ្វើបដិទានទៅស្ថានភាពដើមរបស់គូភាគី។

តាមឧទាហរណ៍ ក្នុងករណីដែល **ក** បានរំលាយកិច្ចសន្យា នោះមិនត្រូវចាត់ទុកថា **ខ** គ្មានកម្មសិទ្ធិតាំងពីដំបូងឡើយ ប៉ុន្តែនៅពេលដែល **ក** រំលាយកិច្ចសន្យា **ខ** ត្រូវប្រគល់រថយន្តទៅឱ្យ **ក** វិញ ដែលជាកាតព្វកិច្ចថ្មីដោយផ្អែកលើកិច្ចសន្យា។

នៅក្នុងគំនិតនេះ បញ្ញត្តិនៃការរំលាយកិច្ចសន្យា ត្រូវយកមកអនុវត្តចំពោះពេលអនាគត ហើយ ទាក់ទងនឹងកាតព្វកិច្ច ដែលមិនទាន់ត្រូវបានអនុវត្ត គឺមិនមានអត្ថិភាពទៀងទាត់ទេ នៅពេលអនាគត។ ផ្ទុយទៅវិញ កាតព្វកិច្ច ដែលបានអនុវត្តរួចហើយ គឺមានសុពលភាពហើយ មិនអាចក្លាយជាសេចក្តីចម្រើនឥតហេតុទេ ។

គំនិត B រិះគន់នូវគំនិត A ដោយផ្អែកលើមូលហេតុថា គឺមិនមានបញ្ញត្តិ ចែងអំពីអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យា។ ក្នុងករណីនៃការលុបចោលកិច្ចសន្យា ក៏បានចែងអំពីអត្ថិភាពនៃអានុភាពប្រតិសកម្មយ៉ាងច្បាស់លាស់។[58] មូលហេតុដែលក្រមរដ្ឋប្បវេណីទទួលស្គាល់នូវអានុភាពប្រតិសកម្មលើការលុបចោល គឺថាវា មានវិការៈតាំងពីដំបូង។ ផ្ទុយទៅវិញ នៅក្នុងករណីនៃការរំលាយកិច្ចសន្យា កិច្ចសន្យាត្រូវបានបង្កើតឡើងដោយមានសុពលភាពយ៉ាងពេញលេញ ប៉ុន្តែ មូលហេតុនៃការ រំលាយ គឺកើតឡើងនៅពេលក្រោយមកទៀត។ គំនិត B បានលើកឡើងថា ដើម្បីទទួលស្គាល់នូវអានុភាពប្រតិសកម្ម ដែលបដិសេធនូវអានុភាពនៃកិច្ចសន្យា តាំងពីដំបូង នោះការអនុម័តឱ្យមានច្បាប់សារធាតុ គឺមានភាពចាំបាច់ត្រូវតែមាន ជាពិសេសនៅក្នុងករណីនៃការរំលាយកិច្ចសន្យា ព្រោះវា ត្រូវបានបង្កើតឡើងដោយមានសុពលភាពយ៉ាងពេញលេញ។

**ទំនាក់ទំនងជាមួយការផ្ទេរកម្មសិទ្ធិ**

ផ្អែកតាមគំនិត B កម្មសិទ្ធិត្រូវបានធ្វើបដិទាន ដោយស្វ័យប្រវត្តិដោយសារការរំលាយកិច្ចសន្យា នៅពេលដែលរំលាយកិច្ចសន្យានោះ។ ឧទាហរណ៍ កម្មសិទ្ធិត្រូវបានផ្ទេរទៅអ្នកទិញ **ខ** នៅពេលបង្កើតកិច្ចសន្យាហើយធ្វើបដិទានទៅឱ្យអ្នកលក់ **ក** វិញដោយស្វ័យប្រវត្តិ នៅពេលរំលាយកិច្ចសន្យា ដែលវាជាអានុភាពនៃការរំលាយកិច្ចសន្យា។ ដូច្នេះ **ខ** ត្រូវមានកាតព្វកិច្ចប្រគល់កម្មវត្ថុត្រឡប់ទៅវិញ ប្រសិនបើគាត់ បានទទួលវត្ថុនោះរួចហើយ។

**៣.៤.២. អានុភាពប្រតិសកម្ម**

យោងតាមគំនិតនេះ នៅពេលកិច្ចសន្យាត្រូវបានរំលាយ ត្រូវបានចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូង ដូច្នេះតាវកាលិកដែលភាគីម្ខាងបានទទួលត្រូវប្រគល់ទៅឱ្យភាគីម្ខាងទៀតវិញដោយផ្អែកលើសេចក្តីចម្រើនឥតហេតុ។[59]

**ឧទាហរណ៍៖** ក្នុងកិច្ចសន្យា **ក** បានទិញឡានពី **ខ** ដោយព្រមព្រៀងគ្នាថា **ក** ត្រូវបង់លុយថ្លៃឡាននៅថ្ងៃធ្វើកិច្ចសន្យា រីឯ **ខ** ត្រូវអនុវត្តកាតព្វកិច្ចនៅថ្ងៃដែលបានកំណត់មួយ។ លុះដល់ថ្ងៃកំណត់ **ខ** មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនឡើយ ដែលធ្វើឱ្យ **ក** បានសម្រេចចិត្តរំលាយកិច្ចសន្យា។ ដូច្នេះ នៅពេលដែលកិច្ចសន្យាត្រូវបានរំលាយអានុភាពដែលកើតឡើងមានអានុភាពប្រតិសកម្មនាំឱ្យស្មើនឹងគ្មានកិច្ចសន្យាតាំងពីដំបូង ដូចនេះលុយ

[58] មាត្រា ៣៥៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

[59] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, (រាជធានីភ្នំពេញ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រ ១៨៤

ដែល **ខ** ទទួលបាននឹងក្លាយទៅជាសេចក្ដីចម្រើនឥតហេតុដែលធ្វើឱ្យ **ក** អាចប្ដឹងទាមទារយកមកវិញបានដោយផ្អែកលើសិទ្ធិតាមច្បាប់សារធាតុ។

### ៣.៤.៣. អានុភាពមិនប្រតិសកម្ម

ផ្អែកតាមគំនិតនេះ ការរំលាយកិច្ចសន្យាត្រូវបានចាត់ទុកថាគ្មានអានុភាពប្រតិសកម្ម។ ដូច្នេះ សិទ្ធិលើបំណុល និងកាតព្វកិច្ចដើមត្រូវផ្លាស់ប្ដូរទៅជាសិទ្ធិទាមទារ និងកាតព្វកិច្ចធ្វើបដិទានទៅស្ថានភាពដើមរបស់គូភាគី។ [60] នេះគឺព្រោះតែមាត្រា ៤១១កថាខណ្ឌទី២ បានចែងបញ្ជាក់ច្បាស់ពីចំណុចបដិទាននូវតាវកាលិកដែលភាគីបានទទួល។

**ឧទាហរណ៍៖** ក្នុងកិច្ចសន្យាលក់ទិញ **គ** បានទិញទូរស័ព្ទមួយគ្រឿងពី **ឃ** ។ **ឃ** បានប្រគល់ទូរស័ព្ទឱ្យ **គ** រួចហើយ ប៉ុន្តែ **គ** មិនបានបង់ប្រាក់ឱ្យ **ឃ** ទេ។ ដែលជាហេតុធ្វើឱ្យ **ឃ** រំលាយកិច្ចសន្យា។ ដោយផ្អែកលើអានុភាពមិនប្រតិសកម្ម មានអានុភាពហូតដល់មានការរំលាយកិច្ចសន្យា។ រីឯតាវកាលិកដែលភាគីបានទទួលបានត្រូវតែបង្វិលឱ្យភាគី **ឃ** វិញ។ ការផ្ទេរទូរស័ព្ទទៅវិញនេះខុសពីករណីនៃអានុភាពប្រតិសកម្ម ព្រោះការសងតាវកាលិកត្រឡប់ទៅវិញនេះគឺជាកាតព្វកិច្ចថ្មី មិនមែនផ្អែកលើសេចក្ដីចម្រើនឥតហេតុដូចករណីដែលផ្អែកលើទ្រឹស្ដីអានុភាពប្រតិសកម្មនោះទេ។

សរុបមក លក្ខណៈនៃអានុភាពនៃការរំលាយកិច្ចសន្យាទាំង ២ ខាងលើ សុទ្ធតែចងកាតព្វកិច្ចដល់ភាគីត្រូវតែប្រគល់តាវកាលិកត្រលប់ទៅវិញទាំងអស់ឱ្យទៅម្ចាស់ដើមវិញ ហើយក៏មិនមានគំនិតណាមួយប្រឆាំងនឹងការត្រលប់ទៅវិញដែរ លើកលែងតែប្រភេទកិច្ចសន្យានោះមិនអាចប្រគល់ត្រលប់បានដូចការបកស្រាយខាងលើ។

### ៣.៤.៤. អានុភាពចំពោះភាគី

ភាគីនៃកិច្ចសន្យានឹងទទួលអានុភាពពីការរំលាយដូចជា ការរលត់នូវករណីកិច្ចនៃកិច្ចសន្យា (៣.៤.៤.១) លើកលែងតែការរួចផុតពីសំណងនៃការខូចខាត (៣.៤.៤.២)

#### ក. ការរលត់នូវករណីកិច្ចនៃកិច្ចសន្យា

ការរំលាយកិច្ចសន្យានាំឱ្យគូភាគីរួចផុតពីករណីកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីកិច្ចសងការខូចខាត។ បន្ទាប់ពីមានការរំលាយកិច្ចសន្យាបានន័យថា ភាគីគ្មានកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមកទៀតទេ។ យើងដឹងហើយថាភាគីមានកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមកគឺដោយសារអានុភាពចងនៃកិច្ចសន្យា ដូច្នេះបើសិនជាគ្មានកិច្ចសន្យាផងតើមានមូលហេតុគតិយុត្តអ្វីដែលត្រូវឱ្យមានការអនុវត្តនូវកាតព្វកិច្ចនោះ ដូចជាករណីដែល អ្នកទិញមិនចាំបាច់បង់ប្រាក់ឡើយ រីឯអ្នកលក់មិនចាំបាច់ប្រគល់កម្មវត្ថុនៃកិច្ចសន្យានោះឡើយ ក្នុងករណីដែលអ្នកទិញមិនទាន់បានបង់ប្រាក់ឡើយ ក្នុងករណីដែលអ្នកលក់មិនប្រគល់វត្ថុតាមកាលកំណត់ ហើយក្រោយមកអ្នកទិញសម្រេចចិត្តរំលាយកិច្ចសន្យាចោល។

##### ក.១ ការធ្វើបដិទាននៃការផ្ទេរកម្មសិទ្ធិ

ក្នុងគំនិតដែលទទួលស្គាល់អានុភាពនៃប្រតិសកម្ម អ្នកដែលទទួលបានការផ្ទេរកម្មសិទ្ធិគឺ ចាត់ទុកថាមិនដែលទទួលបានការលទ្ធកម្មសិទ្ធតាំងពីដំបូង។ ដូច្នេះអនុប្បទាយី អាចទាមទារឱ្យអនុប្បអានិកផ្ទេរកម្មសិទ្ធិមកវិញ

[60] ក្រុមការងារនៃអនាគតគ្រូបណ្ដុះបណ្ដាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, (រាជធានីភ្នំពេញ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រ ១៨៥

ដោយផ្អែកលើកម្មសិទ្ធិ។ ផ្ទុយទៅវិញគំនិតដែលមិនទទួលស្គាល់អានុភាពប្រតិសកម្មគឺកម្មសិទ្ធិត្រូវបានផ្ទេរ ហើយកាតព្វកិច្ចក្នុងការប្រគល់កម្មសិទ្ធិត្រលប់មកវិញគឺជាកាតព្វកិច្ចមួយថ្មី។ ទន្ទឹមនឹងនេះ កាតព្វកិច្ចត្រូវផ្ទេរមកវិញដោយស្វ័យប្រវត្តិ ។[61]

**ក.២ ការធ្វើបដិទានទៅស្ថានភាពដើម**

ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬទាំងអស់ ត្រូវមានករណីកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីនោះទទួលបដិទានឡើងវិញដោយសារការរំលាយ។ ក្នុងករណីដែលភាគីទាំងសងខាងមានករណីកិច្ចធ្វើបដិទានទៅវិញទៅមក ករណីកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។

ភាគីដែលមានករណីកិច្ចសងជាប្រាក់ដោយការរំលាយកិច្ចសន្យា ត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានទទួលប្រាក់ដើមនោះ។ ភាគីដែលមានករណីកិច្ចបង្វិលជាវត្ថុ ឬជាតាវកាលិកផ្សេងដែលខ្លួនបានទទួលទៅភាគីម្ខាងទៀត ដោយសារការរំលាយត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬតាវកាលិកនោះផងដែរ។[62]

❖ **ខ្លឹមសារនៃកាតព្វកិច្ចធ្វើបដិទាន**

ក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា ភាគីដែលទទួលបានតាវកាលិក ត្រូវសងតាវកាលិកនោះទៅឱ្យភាគីម្ខាងទៀតមិនត្រឹមតែអ្វីដែលគាត់ទទួលបាននោះទេគឺថែមទាំងត្រូវសងការប្រាក់ ឬផលប្រយោជន៍ដែលកើតឡើងពីសិទ្ធិលើបំណុលជាប្រាក់ ឬកម្មវត្ថុនោះទៀតផង។ ក្នុងន័យនេះកាតព្វកិច្ចធ្វើបដិទានមានន័យថា មិនត្រឹមតែជាការធ្វើបដិទានទៅស្ថានភាពពេលបង្កើតកិច្ចសន្យាទេ ប៉ុន្តែទៅដល់ស្ថានភាពដែលអាចមាន។ នេះក៏ព្រោះតែក្រមរដ្ឋប្បវេណីកម្ពុជាបានគិតគូរទៅដល់កាលៈទេសៈដែលភាគីមិនបានបង្កើតកិច្ចសន្យាទេនោះ តើនឹងមានផលប្រយោជន៍អ្វីខ្លះកើតឡើង ?

**ឧទាហរណ៍៖** លោក ដារ៉ា បានទិញក្របី (ញី) ពីលោក សុធី ដោយកាតព្វកិច្ចមិនអនុវត្តព្រមគ្នាទេ គឺលោក ដារ៉ា គាត់យកក្របីទៅផ្ទះមើលសិន ទើបគាត់បង់ប្រាក់តាមក្រោយ។ លុះពីរ បីថ្ងៃក្រោយមកលោក សុធី បានទៅដាស់តឿនឱ្យលោក ដារ៉ា អនុវត្តកាតព្វកិច្ច តែលោក ដារ៉ា គេចវេស ។ ហេតុផលនេះហើយធ្វើឱ្យលោក សុធី សម្រេចចិត្តរំលាយកិច្ចសន្យាចោល ហើយទាមទារឱ្យលោក ដារ៉ា ប្រគល់ក្របីមកវិញ។ លោកដារ៉ា គាត់យល់ព្រមប្រគល់ក្របីនោះមកវិញ ប៉ុន្តែក្របីនោះបានកើតកូនហើយគាត់ទាមទារកូនក្របីថាជារបស់គាត់ដោយមូលហេតុថា កូនក្របីនោះកើតនៅពេលដែលស្ថិតនៅក្រោមការកាន់កាប់របស់គាត់។ នៅក្នុងករណីនេះលោកសុធីមានសិទ្ធិទាមទារកូនក្របី នោះមកវិញផងដែរ ដោយហេតុថាកូនក្របីនោះគឺជាផលដែលកើតចេញកម្មវត្ថុនៃកិច្ចសន្យា ដូច្នេះវាមិនត្រឹមត្រូវទេដែលឱ្យបុគ្គលដែលបានបំពានកិច្ចសន្យា ធ្វើឱ្យខូចខាតផលប្រយោជន៍របស់ភាគីម្ខាងទៀតមានសិទ្ធិទទួលបានផលពីកម្មវត្ថុនៃកិច្ចសន្យា។

❖ **លក្ខណៈនៃកាតព្វកិច្ចធ្វើបដិទាន**

**គោលគំនិតប្រតិសកម្ម** កាតព្វកិច្ចដែលត្រូវធ្វើបដិទានត្រឡប់មកវិញនូវវត្ថុ ដែលបានប្រគល់តាមកិច្ចសន្យាបន្ទាប់ពីមានការរំលាយកិច្ចសន្យា គឺជាករណីកិច្ចពិសេសនៃសេចក្តីចម្រើនឥតហេតុ។ ជាទូទៅប្រសិនបើកិច្ចសន្យាត្រូវបានរំលាយនោះ ត្រូវចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូង ដូច្នេះទំហំនៃកាតព្វកិច្ចក្នុងការប្រគល់ ត្រូវបាន

[61] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សេចក្តីពន្យល់ ក្រមរដ្ឋប្បវេណី ភាគ ២, (រាជធានីភ្នំពេញ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសាឆ្នាំ ២០១៣), ទំព័រទី ១៦៨

[62] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧ មាត្រា ៤១១ ចំណុចទី២ និងទី៣

កម្រិតត្រឹមផលប្រយោជន៍ដែលមាន ដោយផ្អែកលើ មាត្រា ៧៣៦ កថាខណ្ឌទី២។ ក៏ប៉ុន្តែមាត្រា ៤១១ កថាខណ្ឌទី២ បានពង្រីកទំហំនៃកាតព្វកិច្ចធ្វើបដិទាននេះទៅស្ថានភាពដើមរបស់ភាគីដូចដែលបានរៀបរាប់ ។

**គោលគំនិតមិនប្រតិសកម្ម** កាតព្វកិច្ចដែលត្រូវធ្វើបដិទានត្រឡប់វិញនូវវត្ថុ ដែលបានប្រគល់តាមកិច្ចសន្យាបន្ទាប់ពីមានការរំលាយកិច្ចសន្យាគឺជាកាតព្វកិច្ចថ្មី ដោយផ្អែកលើការរំលាយកិច្ចសន្យា ចំណែកឯកាតព្វកិច្ចដែលបានអនុវត្តរួចហើយ គឺមានសុពលភាពព្រោះថាការរំលាយកិច្ចសន្យាមានឥទ្ធិពលឆ្ពោះទៅរកអនាគតតែប៉ុណ្ណោះ។[63]

❖ **ករណីកិច្ចដែលភាគីនៃកិច្ចសន្យាមិនអាចសងត្រឡប់ទៅវិញនូវវត្ថុ**

សិទ្ធិរំលាយកិច្ចសន្យាត្រូវរលត់ក្នុងករណីដែលភាគីមានសិទ្ធិរំលាយៈ

1. បានធ្វើឱ្យមានការខូចខាត ឬបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬមិនអាចសងវត្ថុនោះទៅវិញដោយចេតនា។
2. ធ្វើឱ្យវត្ថុនោះ ក្លាយជាវត្ថុផ្សេងដោយសារការកែច្នៃ ឬការផ្លាស់ប្តូរទ្រង់ទ្រាយ។

ឬនិយាយម្យ៉ាងទៀតថា នៅក្នុងករណីដែលកម្មវត្ថុត្រូវបានធ្វើឱ្យខូចខាត ឬបាត់បង់ ឬមិនអាចសងត្រឡប់មកវិញបាន ដោយចេតនា នោះសិទ្ធិរំលាយមិនត្រូវបានរំលត់ទេ មានន័យថាអ្នកមានសិទ្ធិរំលាយនៅតែមានរំលាយ ប៉ុន្តែត្រូវសងជាប្រាក់នូវតម្លៃដែលជាកម្មវត្ថុនោះ ត្រឹមកម្រិតតម្លៃដែលបានកំណត់នៅក្នុងកិច្ចសន្យា។[64]

**ក.៣ ករណីកិច្ចសងសំណងការខូចខាត**

សំណងការខូចខាត ជាវិធីមួយសម្រាប់សង្គ្រោះក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ច ឬកាតព្វកិច្ចត្រូវបានបំពានផងដែរ។ ថ្វីត្បិតតែភាគីបានជ្រើសរើសយកវិធីរំលាយកិច្ចសន្យាដើម្បីការពារប្រយោជន៍ខ្លួនក៏ពិតមែនក៏មិនមានន័យថាគាត់មិនអាចទាមទារសំណងការខូចខាតបាននោះដែរ។ នៅក្នុងវិធីនៃការសង្គ្រោះកិច្ចសន្យា ភាគីអាចប្រើវិធីសង្គ្រោះមួយ ឬច្រើនឱ្យតែវិធីសង្គ្រោះមិនមានលក្ខណៈផ្ទុយគ្នា ឧទាហរណ៍ដូចជា ភាគីអនុវត្តការសង្គ្រោះតាមរយៈការរំលាយកិច្ចសន្យាហើយ បន្ទាប់មកភាគីចង់អនុវត្តដោយបង្ខំទៀតដូច្នេះវាមិនសមហេតុផលទេដែល ភាគីបានរំលាយកិច្ចសន្យាហើយ (កាតព្វកិច្ចរលត់ហើយ) ភាគីចង់អនុវត្តដោយបង្ខំទៀត ព្រោះថាភាគីទាំងសងខាងអស់កាតព្វកិច្ចដែលត្រូវអនុវត្តដោយបង្ខំហើយ។ លើសពីនេះទៀតមាត្រា ៤១១ កថាខណ្ឌទី២ បានបញ្ជាក់ដែរថា គូភាគីមិនអាចរួចផុតពីករណីកិច្ចសងការខូចខាតទេ ទោះបីជាភាគីរួចផុតពីករណីកិច្ចក្នុងកិច្ចសន្យាក៏ដោយ។

ផលប្រយោជន៍ដែលត្រូវសងមាន ២គឺ ៖

1. **ផលប្រយោជន៍ពីការរំពឹងទុក** សម្តៅទៅលើផលប្រយោជន៍ដែលអាចនឹងទទួលបានប្រសិនបើកិច្ចសន្យាត្រូវបានអនុវត្តដូចការសន្យា។
2. **ផលប្រយោជន៍ពីការជឿទុកចិត្ត** គឺសម្តៅទៅលើ ការចំណាយរបស់ភាគីដែលបានជឿជាក់ថាកិច្ចសន្យាមិនត្រូវបានរំលាយនោះទេ។ ក្នុងករណីនេះ ភាគីដែលទទួលរងនូវការខូចខាតដោយសារការរំលាយកិច្ចសន្យា អាចទាមទារសំណងនៃការខូចខាតដែលនឹងមិនត្រូវបានចំណាយ ប្រសិនបើគាត់បានដឹងថា កិច្ចសន្យានឹងត្រូវរំលាយ។

---

[63] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, (រាជធានីភ្នំពេញ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រ ១៨៤

[64] មាត្រា ៤១២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

ក្រោយពីបានសិក្សាអានុភាពចំពោះភាគីរួចមកការពារតតិយជនពីអានុភាពនៃការរំលាយកិច្ចសន្យា គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះតតិយជនដែលត្រឹមត្រូវ។

### ៣.៤.៥. អានុភាពចំពោះតតិយជន

ការរំលាយកិច្ចសន្យា មិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ។ នេះគឺជាគោលបំណងក្នុងការការពារស្ថិរភាពជំនួញរបស់តតិយជន ដែលត្រឹមត្រូវមិនឱ្យស្ថិតនៅក្នុងស្ថានភាពមួយដែលមាននូវការព្រួយបារម្ភ។ មិនមែនគ្រប់តតិយជនសុទ្ធតែត្រូវបានការពារទាំងអស់នោះទេ លុះត្រាតែតតិយជននោះមានភាពត្រឹមត្រូវតាមច្បាប់។[65]

**ឧទាហរណ៍៖** ថ្ងៃទី ០១.០៤.២០១៩ **លោក ចន** បានលក់ដី ទៅឱ្យ **លោកស្រី បុផ្ផា** និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិ។ ថ្ងៃទី ០១.០៥.២០១៩ **លោក ចន** បានលក់ដីទៅឱ្យ **លោក វណ្ណា** និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិ។ ទោះបីជា **លោក ចន** បានដាស់តឿនក៏ **អ្នកស្រី បុផ្ផា** នៅតែមិនបង់ថ្លៃលក់ទិញដីបង្គ្រប់។ ថ្ងៃទី ០១.០៦.២០១៩ **លោក ចន** បានរំលាយកិច្ចសន្យា។

ប្រសិនបើការទិញលក់ដី ពី **លោក ចន** ទៅអ្នក**ស្រី បុផ្ផា** ក្លាយជានត្ថិភាពដោយសារការរំលាយ នោះផលប្រយោជន៍របស់ **លោក វណ្ណា** ដែលបានទិញដី ដោយការជឿជាក់លើការចុះបញ្ជីរបស់ **អ្នកស្រី បុផ្ផា** នឹងត្រូវខូចខាតយ៉ាងខ្លាំង ហើយសុវត្ថិភាពជំនួញក៏មានការខូចខាតផងដែរ។ ការរំលាយមិនអាចធ្វើឱ្យខូចខាតប្រយោជន៍ត្រឹមត្រូវរបស់ **លោក វណ្ណា** បានឡើយ។ **អានុភាពនៃការរំលាយមិនមានចំពោះ លោក វណ្ណា ទេ។ លោក វណ្ណា អាចតតាំងអំពីលទ្ធកម្មនៃកម្មសិទ្ធិលើដី ចំពោះលោក ចន។**

ផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនជាអ្វី? ដោយសារតែការបកស្រាយនេះមិនមានកំណត់ក្នុងច្បាប់ ហេតុនេះត្រូវពឹងផ្អែកទៅលើយុត្តិសាស្ត្ររបស់តុលាការ។ តើករណីណាខ្លះដែលយើងអាចនិយាយថា **លោក វណ្ណា** មានផលប្រយោជន៍ត្រឹមត្រូវ?

- ករណីដែល **លោក វណ្ណា** មិនទាន់បានចុះបញ្ជីដី រួចរាល់?
- ករណីដែល **លោក ចន** បានដឹងថា **អ្នកស្រី បុផ្ផា** មិនមានលទ្ធភាពបង់ប្រាក់ថ្លៃទិញបាន?
- ករណីដែល **អ្នកស្រី បុផ្ផា** បានប្រាប់ថា **លោក វណ្ណា** ថា ចង់លក់នេះ មុនពេលដែលលោក **ចន** រំលាយកិច្ចសន្យា?[66]

តើត្រូវការពារតតិយជន យ៉ាងដូចម្តេចនោះគឺអាស្រ័យទៅលើថា តើអានុភាពប្រតិសកម្ម ត្រូវទទួលស្គាល់ ឬមិនទទួលស្គាល់។

ឆ្លើយតបទៅនឹងចំណោទបញ្ហាគតិយុត្តខាងលើ ភាពប្រតិសកម្មយកមកសិក្សាដើម្បីការពារតតិយជនក្នុងគោលការណ៍ប្រតិសកម្ម (៣.៤.៥.១) និងតតិយជនក្នុងគោលការណ៍មិនប្រតិសកម្ម (៣.៤.៥.២) ។

---

[65] ប្រសាសន៍របស់លោកស្រីមេធាវី ទេព បូផល, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយ៖ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩)

[66] លោកស្រីមេធាវី ទេព បូផល, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយ៖ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩), ទំព័រទី ៦៤

### ក. តតិយជនក្នុងគោលការណ៍ប្រតិសកម្ម

ចំពោះតតិយជនមុនការរំលាយកិច្ចសន្យាវិញ គេអាចចាត់ទុកថា តតិយជនត្រូវទទួលបានការកាន់កាប់ ឬចុះបញ្ជី ដើម្បីទទួលបាននូវការការពារមាត្រា ៤១១ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីកម្ពុជា ព្រោះតតិយជនត្រូវបានគេចាត់ទុកថាបានខិតខំប្រឹងប្រែងជាអតិបរមាដើម្បីការពារសិទ្ធិរបស់ខ្លួន។ ដោយផ្អែកលើគំនិតនេះ ការកាន់កាប់ ឬការចុះបញ្ជីមានតួនាទី " លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃសិទ្ធិរក្សាការពារ "។ ផ្ទុយទៅវិញគេអាចគិតថាលក្ខខណ្ឌតាំងមិនមានលក្ខណៈចាំបាច់ សម្រាប់តតិយជនក្នុងការទទួលបានការការពារទេ ព្រោះមាត្រា ៤១១ កថាខណ្ឌទី ៤ មិនបានតម្រូវឱ្យមានលក្ខខណ្ឌតតាំងសម្រាប់តតិយជនទេ។

ផ្អែកលើភាពប្រតិសកម្មតតិយជនដែលបានចុះកិច្ចសន្យានៅក្រោយការរំលាយកិច្ចសន្យា មិនអាចទទួលបាននូវការការពារតាមមាត្រា ៤១១ កថាខណ្ឌទី៤ ទេ ព្រោះអានុភាពប្រតិសកម្មបានកើតឡើងរួចហើយ ។ តតិយជននៅក្រោយការរំលាយកិច្ចសន្យាត្រូវបានចាត់ ថាបានទទួលកម្មសិទ្ធិពីជនដែលមិនមានកម្មសិទ្ធិ។ ដូច្នេះតតិយជនមិនអាចធ្វើលទ្ធកម្មសិទ្ធិទេ។ ជាការពិត នៅក្នុងករណីដែលកម្មសិទ្ធិ គឺជាចលនវត្ថុ អនុប្បទានិកអាចធ្វើលទ្ធកម្មលើកម្មសិទ្ធិបាន បើសិនអនុប្បទានិកជាជនសុចរិត និងគ្មានកំហុស ដោយបំពេញលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា។ ក៏ប៉ុន្តែនៅក្នុងករណីកម្មវត្ថុ គឺជាអចលនវត្ថុតតិយជនមិនអាចទទួលបានកម្មសិទ្ធិតាមរយៈលទ្ធកម្មដោយសុចរិតនោះទេ។ ជាលទ្ធផលគឺមានគំនិតមួយ ដែលការពារតតិយជនប្រភេទនេះ តាមរយៈការអនុវត្តដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងមាត្រា ៣៥៣ កថាខណ្ឌទី២។ ព្រោះអាចនិយាយបានថា **ក** បានបន្សល់ទុកនូវការចុះបញ្ជី ហើយបានបង្កើតនូវទិដ្ឋភាពមួយដែលបង្ហាញថា **ខ** គឺជាកម្មសិទ្ធិករលើអចលនវត្ថុនោះ ហើយ **គ** បានជឿជាក់ថា **ខ** គឺជាម្ចាស់សិទ្ធិពិតប្រាកដមែន។ មូលហេតុដែលក្រមរដ្ឋប្បវេណីធ្វើការការពារតតិយជនដែលសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរព្រោះជនដែលបង្កើតនូវទិដ្ឋភាពមិនពិត មិនមានសិទ្ធិក្នុងការអះអាងនូវមោឃភាពនៃកិច្ចសន្យាចំពោះតតិយជនដែលបានជឿជាក់ទៅលើទិដ្ឋភាពនោះ ដោយមានហេតុផលឡើយ។ គោលការណ៍នេះទាញចេញពី « លទ្ធិដែលមានលក្ខណៈជារូបភាព »។[67]

### ខ. តតិយជនក្នុងគោលការណ៍មិនប្រតិសកម្ម

ដោយផ្អែកលើភាពមិនប្រតិសកម្ម ការរំលាយកិច្ចសន្យាមិនមានអានុភាពប្រតិសកម្មទេ។ ទោះបីជាមានការរំលាយកិច្ចសន្យាក៏ដោយ។ ប៉ុន្តែទោះបីជាការរំលាយមិនមានអានុភាពប្រតិសកម្មតែពេលមានការរំលាយកិច្ចសន្យាម្ចាស់កម្មសិទ្ធិអាចទាមទារឱ្យធ្វើការផ្ទេរកម្មវត្ថុត្រឡប់មកវិញបានទោះបីជាវត្ថុនោះត្រូវបានផ្ទេរឱ្យតតិយជនហើយក៏ដោយ។

ផ្អែកលើគំនិតនេះវាមានលក្ខណៈស្រដៀងគ្នាទៅនឹងការផ្ទេរពីរដងជាន់គ្នា ដោយមិនគិតថាតតិយជនបានទិញកម្មវត្ថុនៅមុន ឬនៅក្រោយការរំលាយកិច្ចសន្យាទេ ដូច្នេះ បុគ្គលណាដែលបានទទួលនូវលក្ខខណ្ឌតតាំងមុនបុគ្គលផ្សេងទៀត អាចអះអាងពីកម្មសិទ្ធិរបស់ខ្លួនបាន។ វាមានន័យថាទោះបីជាមិនមានបញ្ញត្តិដូចមាត្រា ៤១១ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណី ក៏លទ្ធផលដូចគ្នានឹងការផ្ទេរពីរដងជាន់គ្នា ដូច្នេះមាត្រា ៤១១ កថាខណ្ឌទី៤

[67] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, (រាជធានីភ្នំពេញ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រ ១៩៣

គឺមិនមែនជាបញ្ញត្តិពិសេស ដើម្បីការពារតតិយជនដែលមានផលប្រយោជន៍ស្របច្បាប់ គឺគ្រាន់តែជាបញ្ញត្តិបញ្ជាក់បន្ថែមតែប៉ុណ្ណោះ។[68]

### ៣.៤.៦. ការរំលាយកិច្ចសន្យា និងតតិយជន

ការរំលាយកិច្ចសន្យា មិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ។ ទស្សនៈនៃ « តតិយជន » សំដៅទៅលើជន ដែលក្រៅពីសាមីភាគី ឬជនទទួលបន្តទូទៅរបស់សាមីភាគី ដូចជាសន្តតិជន ឬ នីតិបុគ្គលដែលបានរួមបញ្ចូលគ្នា។ ដូចនេះ តើជនក្រៅពីសាមីភាគី អាចក្លាយជា « តតិយជន » ដែរ ឬ ទេ? មានតែតតិយជន ដែលមានផលប្រយោជន៍ត្រឹមត្រូវ ទើបជាតតិយជន។[69]

**ឧទាហរណ៍** នៅក្នុងករណីដែលរថយន្ត ត្រូវបានលក់ពី **ក** ទៅ **ខ** បន្ទាប់មក ពី **ខ** ទៅ **គ** ។ **គ** អាចជៀសផុតពីផលប៉ះពាល់ទេ ប្រសិនបើ **ក** រំលាយកិច្ចសន្យា។ គេអាចបែងចែក ករណីនេះ ជាពីរប្រភេទដោយផ្អែកលើវត្តមានរបស់តតិយជន។

**ឧទាហរណ៍** ករណីទី ១ គឺនៅក្រោយពេលដែល **ខ** បានប្រគល់រថយន្តទៅឱ្យ **គ** ហើយ **ក** រំលាយកិច្ចសន្យាលក់ទិញជាមួយនឹង **ខ**។ **គ** នៅក្នុងករណីនេះត្រូវបានហៅថា « តតិយជននៅមុនការរំលាយ »។ ករណីមួយទៀតគឺ « តតិយជននៅក្រោយការរំលាយ »។ ឧទាហរណ៍ **ក** រំលាយកិច្ចសន្យាជាមួយនឹង **ខ** ប៉ុន្តែ **ខ** បានលក់រថយន្តនោះបន្តឱ្យទៅ **គ** នៅក្រោយការរំលាយ។ នៅក្នុងករណីនេះ វាមានសារសំខាន់ណាស់ក្នុងការគិតថា ការលក់របស់ **ខ** គឺជាការកែបន្លំយកទ្រព្យ ដោយទុច្ចរិត។ ប៉ុន្តែអានុភាពរបស់កិច្ចសន្យាលក់បន្តនេះ ត្រូវធ្វើការពិចារណាដាច់ដោយឡែកពីករណីព្រហ្មទណ្ឌ។

## ៣.៥.. ការរំលត់នូវសិទ្ធិរំលាយកិច្ចសន្យា

### ៣.៥.១. នៅក្នុងករណីដែលការខូចខាត ជាអាទិ៍ នៃកម្មវត្ថុនៃកិច្ចសន្យា កើតឡើងដោយចេតនា

សិទ្ធិរំលាយ ត្រូវរលត់ នៅក្នុងករណីដែល ភាគីដែលមានសិទ្ធិរំលាយ ៖

i. ធ្វើឱ្យខូចខាត ឬ បាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬ មិនអាចសងវត្ថុនោះវិញដោយចេតនា។ **ឧទាហរណ៍** ក ម្មវត្ថុនៃកិច្ចសន្យា បានលក់បន្តបាត់ ឬបានបែកបាក់អស់។

ii. ធ្វើឱ្យវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេង ដោយការកែច្នៃ ឬការផ្លាស់ទម្រង់ដោយចេតនា។ **ឧទាហរណ៍** កិច្ចសន្យាទិញលក់អង្ករ តែអង្ករដែលបានទិញ លក់បានកិនក្លាយជាម្សៅអស់ហើយ នឹងបានផលិតជានំប៉ុងទៅហើយ។

មូលហេតុដែលសិទ្ធិរំលាយកិច្ចសន្យា ត្រូវរលត់នៅក្នុងករណីទាំងពីរខាងលើនេះ គឺដោយសារតែ វាផ្ទុយនឹង គោលការណ៍នៃភាពសុចរិត នឹងស្មោះត្រង់ [70] ប្រសិនបើភាគី ដែលបានធ្វើឱ្យខូចខាត ឬមិនអាចសងវត្ថុនោះវិញដោយចេតនា អាចរំលាយកិច្ចសន្យាបាន។

---

[68] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, (រាជធានីភ្នំពេញ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រ ១៩៣

[69] មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី ២០០៧

[70] មាត្រា ៥ នៃក្រមរដ្ឋប្បវេណី ២០០៧

សិទ្ធិរំលាយកិច្ចសន្យា មិនត្រូវបានរលត់ទេ នៅក្នុងករណីដែលកម្មវត្ថុ គឺត្រូវបានធ្វើឱ្យខូចខាត ឬបាត់បង់ ដល់វត្ថុដែលជា កម្មវត្ថុនៃកិច្ចសន្យា ឬមិនសងវត្ថុនោះវិញ ដោយចេតនា ។ នៅក្នុងករណីនេះ ភាគីដែលមានសិទ្ធិរំលាយកិច្ចសន្យា ត្រូវសងជា ប្រាក់នូវតំលៃដែលជាកម្មវត្ថុនោះ ត្រឹមកំរិតតំលៃដែលបានកំណត់ក្នុងកិច្ចសន្យា។[71]

### ៣.៥.២. ការរលត់ដោយសារអាជ្ញាយុកាល

សិទ្ធិរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និងសិទ្ធិទាមទារបដិទាន ត្រូវរលត់ដោយអាជ្ញាយុកាល ០៥ ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច។[72]

**ការមិនអនុវត្តកាតព្វកិច្ចៈ** ត្រូវបានគិតចាប់ពីពេលដែលមានការយឺតយ៉ាវ។

**ឯការយឺតយ៉ាវៈ** ត្រូវបានគិតចាប់ពីពេលដែល ភាគីម្ខាងបានអនុវត្តកាតព្វកិច្ចរួចរាល់។

ការទាមទារឱ្យធ្វើបដិទានឡើងវិញ ដោយផ្អែកលើការរំលាយកិច្ចសន្យា មិនត្រូវធ្វើដោយឯករាជ្យពីការរំលាយកិច្ចសន្យាទេ ហើយភាគី ដែលមានសិទ្ធិទាមទារឱ្យបដិទាន ត្រូវអនុវត្តសិទ្ធិនេះ នៅមុនពេលសិទ្ធិរំលាយត្រូវបានរលត់ ដោយអាជ្ញាយុកាល។

**ឧទាហរណ៍** នៅក្នុងករណីដែល **ក** និង **ខ** បានចុះកិច្ចសន្យាលក់ទិញ ប៉ុន្តែ **ខ** មិនបានបង់ប្រាក់ថ្លៃទិញ ទោះបីជាមានការប្រគល់របស់ **ក** ក៏ដោយ។ **ខ** ត្រូវស្ថិតនៅក្នុងភាពយឺតយ៉ាវ ចាប់ពីពេលដែល **ក** បានធ្វើការប្រគល់កម្មវត្ថុ។ នៅក្នុងករណីនេះអាជ្ញាយុកាលនៃការរំលត់ត្រូវចាប់គិតពីពេលដែល **ខ** ស្ថិតនៅក្នុងភាពយឺតយ៉ាវ។ ដូច្នេះ **ក** ត្រូវអនុវត្តសិទ្ធិរំលាយកិច្ចសន្យា និងសិទ្ធិទាមទារបដិទាន ក្នុងអំឡុងពេល ៥ ឆ្នាំ ចាប់ពីពេលប្រគល់របស់ **ក**។

### ៣.៥.៣. ការរំលត់ដោយសារអនុវត្តកាតព្វកិច្ច ឬដោយសារសំណើរផ្តល់ការអនុវត្តកាតព្វកិច្ច

លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃការរំលាយ ដោយផ្អែកលើមូលហេតុថា ការយឺតយ៉ាវនៅក្នុងការអនុវត្តកាតព្វកិច្ច គឺ ៖

i. ភាគីម្ខាងទៀត មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន

ii. ភាគីដែលចង់រំលាយកិច្ចសន្យា បានដាស់តឿនឱ្យអនុវត្តកាតព្វកិច្ច ដោយកំណត់អំឡុងពេលសមរម្យ

iii. កូនបំណុល មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន នៅក្នុងអំឡុងពេលកំណត់នោះ។

ដូច្នេះប្រសិនបើកូនបំណុល អនុវត្តកាតព្វកិច្ចនៅក្នុងអំឡុងពេលនោះ ហើយកាតព្វកិច្ច ត្រូវរលត់ដោយសារការសំរេចនូវគោលបំណងនោះ សិទ្ធិរំលាយក៏ត្រូវរលត់ដែរ។

បន្ទាប់ ចុះចំពោះករណីដែលម្ចាស់បំណុល ប្រកែកមិនព្រមទទួលយកកម្មវត្ថុ ទោះបីជា កូនបំណុល បានស្នើផ្តល់ការអនុវត្តកាតព្វកិច្ច ដោយយោងទៅតាមការដាស់តឿនរបស់ម្ចាស់បំណុល តើវានឹងទៅជាយ៉ាងណា? នៅក្នុងករណីនេះ ប្រសិនបើម្ចាស់បំណុល បានទទួលកម្មវត្ថុ នោះកាតព្វកិច្ចនឹងត្រូវរលត់ ។ ដូច្នេះ នៅក្នុងករណីនេះ គេ អាចទទួលស្គាល់ថា សិទ្ធិរំលាយរបស់ម្ចាស់បំណុល ត្រូវរលត់ ដោយសារតែការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ដោយផ្អែកលើគោលការណ៍នៃភាពយុត្តិធម៌។

---

[71] មាត្រា ៤១២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

[72] មាត្រា ៤១៣ នៃក្រមរដ្ឋប្បវេណី ២០០៧

# សេចក្ដីសន្និដ្ឋាន
# និង
# អនុសាសន៍

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

ឆ្លងតាមការបកស្រាយខាងលើ យើងសង្កេតឃើញថា នៅក្នុងទំនាក់ទំនងរដ្ឋប្បវេណីត្រូវបាន កំណត់ដោយច្បាប់ ។ កិច្ចសន្យាមានច្រើនប្រភេទ ក៏ប៉ុន្តែកិច្ចសន្យានីមួយៗវាផ្អែកទៅលើកម្មវត្ថុនៃកិច្ចសន្យានោះ កិច្ចសន្យានីមួយៗមានលក្ខណៈខុសប្លែកពីគ្នាជាច្រើនចំណុច ជាពិសេសគឺលក្ខណៈគ្រឹះខ្លះ និងលក្ខណៈទម្រង់ មួយចំនួន។ ចំពោះលក្ខខណ្ឌគ្រឹះ ថ្វីត្បិតតែកិច្ចសន្យាកើតមានត្រឹម ការព្រមព្រៀងក៏ដោយ ក៏កិច្ចសន្យា មិនអាចបង្កើតឡើងបានដែរ ប្រសិនបើបុគ្គលដែល ជាប្រធាននៃកិច្ចសន្យាជាជនដែលត្រូវបានកម្រិតសមត្ថភាពទទួលសិទ្ធិជាអាទិ៍ជនបរទេសដោយ យោងទៅតាមរដ្ឋធម្មនុញ្ញ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាក៏ប៉ុន្តែ ចំពោះលើកលែងមួយចំនួន គឺអគារសហកម្មសិទ្ធិដែលចាប់ពីជាន់ទី២ឡើងទៅជនដែលត្រូវបានកម្រិតសមត្ថភាព ទទួលបានសិទ្ធិ ពោលគឺជនបរទេស មានសិទ្ធិបង្កើតកិច្ចសន្យាលក់ទិញបាន។ ចំណែកឯជនដែលត្រូវបានច្បាប់កម្រិតសមត្ថភាពមួយចំនួនទៀតគឺ អនីតិជន ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភប៉ុន្តែជនទាំងនេះ អាចធ្វើសកម្មភាពក្នុងការបង្កើតកិច្ចសន្យាបានដែល លុះត្រាតែមានការយល់ព្រមពីអាណាព្យាបាល អាណាព្យាបាលទូទៅ និងហិតូបត្ថម្ភកៈ ទើបគាត់អាចធ្វើសកម្មភាពបានដោយស្របច្បាប់ និងធ្វើឱ្យកិច្ចសន្យាមានសុពលភាព។ ដើម្បីបង្កើតកិច្ចសន្យាបាន ហើយស្របទៅនឹងច្បាប់ កិច្ចសន្យានោះ ត្រូវមានការព្រមព្រៀងរវាងគូភាគីទាំងពីរដោយសុច្ចរិត នឹងស្មោះត្រង់ ពោលគឺ សំណើ និងស្វីការត្រូវគ្នា។

ក្រោយពីបង្កើតកិច្ចសន្យាឡើងហើយភាគីទាំងពីរ បានជាប់នូវចំណងគតិយុត្តរវាងគ្នា គឺបំពេញកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមក។ ដែលភាគីម្ខាងទទួលបានសិទ្ធិ និងផលប្រយោជន៍ពីកិច្ចសន្យា ហើយភាគីម្ខាងទៀតជាអ្នកទទួលបន្ទុកដើម្បីបំពេញកាតព្វកិច្ចទៅឱ្យភាគីម្ខាងទៀត។ ការបំពេញកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមករវាងគូភាគីទាំងពីរ ត្រូវបានកំណត់នៅក្នុងកិច្ចសន្យា ដោយមានចែងអំពីខលក្ខខណ្ឌ នៅក្នុងកិច្ចសន្យានោះ ហើយភាគីទាំងពីរចាប់ផ្តើមអនុវត្តកាតព្វកិច្ចចាប់តាំងពីពេលបង្កើតកិច្ចសន្យានោះឡើយ និងមានកំណត់អំពីចិរវេលាដើម្បីបញ្ចប់នូវកិច្ចសន្យានោះនៅកាលបរិច្ឆេទណាមួយ។ ការរំលាយកិច្ចសន្យាអាចត្រូវបានរំលាយតាមមធ្យោបាយជាច្រើនដែលក្នុងនោះអាចរំលាយតាមរយៈការកំណត់ដោយច្បាប់ ការរំលាយតាមកិច្ចសន្យា និង ដោយការព្រមព្រៀងរបស់គូភាគី។

ផ្ទុយទៅវិញប្រសិនបើភាគីមិនអាចរំលាយតាមកិច្ចសន្យាដោយមូលហេតុថាមិនបានកំណត់ជាមុន និងការមិនយល់ព្រមពីភាគីម្ខាងទៀតទេ នោះភាគីដែលមានសិទ្ធិរំលាយអាចរំលាយកិច្ចសន្យាបានតាមរយៈច្បាប់កំណត់ គឺធ្វើតាមបញ្ញត្តិច្បាប់សារធាតុក្រមរដ្ឋប្បវេណីដោយលើកឡើងអំពីលក្ខខណ្ឌ ដែលត្រូវបានបំពេញដូចជាប្រភេទនៃកិច្ចសន្យាអញ្ញមញ្ញ និងភាគីម្ខាងទៀតបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ ការបំពានកិច្ចសន្យាធ្ងន់ធ្ងរមានដូចជា ៖

1) ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀត ដោយភាគីម្ខាងទៀតមិនបានអនុវត្តកាតព្វកិច្ចតាមកាលកំណត់

2) ភាគីមិនអនុវត្តករណីកិច្ចតាមពេលកំណត់នៅក្នុងកិច្ចសន្យា

3) ភាគីមិនអាចអនុវត្តករណីកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ

4) ការបំពានកិច្ចសន្យាហួសហេតុ ដែលធ្វើឱ្យបាត់បង់ទំនុកចិត្តរវាងគូភាគី សម្រាប់អនុវត្តពេលអនាគត។

ការរំលាយកិច្ចសន្យាមិនត្រឹមតែមានអានុភាពចំពោះភាគីប៉ុណ្ណោះទេ ពោលគឺមានអានុភាពចំពោះ តតិយជនបានឡើយ ។ នេះគឺជាគោលបំណងក្នុងការការពារស្ថិរភាពជំនួញរបស់តតិយជន ដែលត្រឹមត្រូវមិនឱ្យស្ថិតក្នុងស្ថានភាពមួយដែលអស្ថិរភាព ដែលរំលត់នូវការព្រួយបារម្ភទាំងឡាយរបស់តតិយជនត្រឹមត្រូវផងដែរ ។ មិនមែនគ្រប់តតិយជនសុទ្ធតែត្រូវបានការពារទាំងអស់នោះទេ លុះត្រាតែ តតិយជននោះមានភាពត្រឹមត្រូវតាមច្បាប់ ។ តតិយជនដែលមានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់នឹងត្រូវទទួលបាននូវការការពារ ហើយនេះក៏ជាយុទ្ធសាស្ត្ររបស់តុលាការកម្ពុជានាពេលអនាគតផងដែរក្នុងការវិនិច្ឆ័យទៅតាមអង្គហេតុនីមួយៗ។

ដោយសង្ខេប កិច្ចសន្យា គឺជាច្បាប់របស់គូភាគី ឬជាកិច្ចព្រមព្រៀង ឬកុងត្រាផ្លូវការមួយដែលមានលក្ខណៈចងកាតព្វកិច្ចភាគី ត្រូវតែគោរព និងប្រតិបត្តិតាមកិច្ចសន្យា បន្ទាប់ពីមានភាពត្រូវគ្នានៃឆន្ទៈ និងគោលបំណងរបស់គូភាគីលើទំនាក់ទំនងនៃសិទ្ធិ និងកាតព្វកិច្ចទៅវិញទៅមក ក្នុងរយៈនៃកិច្ចសន្យាមានសុពលភាព។ ក្នុងករណីភាគីណាមួយមិនបានគោរពនូវអ្វីដែលខ្លួនបានព្រមព្រៀងគ្នាទេនោះ ភាគីម្ខាងទៀតអាចធ្វើការទាមទារ និងបង្ខំឱ្យភាគីនោះអនុវត្ត តាមខកិច្ចសន្យានៅតុលាការ ឬស្ថាប័នមានសមត្ថកិច្ច។

ស្របគ្នានេះដែរ ដោយសារតែតម្រូវការរបស់សង្គម និងការដើរទៅមុខដ៏លឿនស្ទើរគ្រប់វិស័យ រួមមានវិស័យការងារ វិស័យឧស្សាហកម្ម វិស័យកសិកម្ម ពាណិជ្ជកម្ម ព្រមទាំងមានការវិនិយោគទាំងក្នុងប្រទេស និងក្រៅប្រទេស ធ្វើឱ្យប្រទេសមានការរីកចម្រើន ផ្អែកចំណេះដឹងក្នុងការ ការពារផលប្រយោជន៍របស់ខ្លួនពីបុគ្គលឆ្លៀតឱកាស ទើបគេត្រូវបង្កើតកិច្ចសន្យា ដើម្បីចងភាគី យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ប្រធានបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រមួយនេះ នឹងចូលរួមចំណែកដ៏ប្រសើរលើការតាក់តែង ការចងក្រងការស្រាវជ្រាវ និងការវិភាគនាពេលអនាគតនិងការវិភាគនាពេលអនាគតជុំវិញទិដ្ឋភាពគតិយុត្តនៃកិច្ចសន្យា។

# ឯកសារយោង

# ឯកសារយោង


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២. ក្រមរដ្ឋប្បវេណី, លេខ សន/រកម/០៧០៦/០៣០, ប្រកាសឱ្យប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

៣. សមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី , ភាគ ១ , (ក្រសួងយុត្តិធម៌បោះពុម្ពលើកទី១. ខែធ្នូ ឆ្នាំ២០១៥)

៤. ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាល នៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ៣, ការកែសម្រួលលើការបោះពុម្ពលើកទី១(រាជធានីភ្នំពេញ ខែមេសា ឆ្នាំ២០១៣)

៥. កម្រងមេរៀនឆ្នាំ២០១៦ , រៀបរៀងដោយវិភាគទានច្បាប់

៦. គង់ សុភ័ក្រ, សញ្ញាណទូទៅនៃកាតព្វកិច្ច ឆ្នាំ២០១៨-២០១៩

៧. ញឹក វុទ្ធី, នីតិកាតព្វកិច្ច, ភាគ ១(សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)

៨. សាស្ត្រាចារ្យ UMEMOTO YUMI , ការរំលាយកិច្ចសន្យា, (ក្រសួងយុត្តិធម៌ វិទ្យាសាស្ត្រស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់, នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ)

៩. មេធាវី អ៊ីវ ប៉ូលី , ការរំលាយកិច្ចសន្យា, វិភាគទានច្បាប់ (ចែករំលែក), បោះពុម្ពថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧

១០. វិភាគទានច្បាប់ រៀបរៀងដោយ មជ្ឈមណ្ឌលសហប្រត្តិការកម្ពុជា-កូរ៉េ (CKCC) ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៩

# ឧបសម្ព័ន្ធ

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឍរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ២
# ការបង្ហាញឆន្ទៈ និង កិច្ចសន្យា

## ផ្នែកទី ១
## ការបង្កើតកិច្ចសន្យា

**មាត្រា ៣៣៦.–** ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្វីការ

១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្វីការត្រូវគ្នា ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទានន្ទូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត ។

**មាត្រា ៣៣៧.–** និយមន័យនៃសំណើ និង ស្វីការ

១-សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើង ដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ ។

២-សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ ។

៣-ស្វីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ ។

៤-ស្វីការត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្វីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្វីការដល់ ឬ មុនពេលស្វីការដល់ នោះអានុភាពនៃស្វីការ មិនត្រូវកើតឡើយ ។

**មាត្រា ៣៣៨.–** សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ

១-សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្វីការ ។ អំឡុងពេល

សម្រាប់ស្វីការ ត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ បើមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេង ។

២-សំណើដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសម្រាប់ស្វីការ មិនអាចដកវិញបានទេ ។

៣-ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្វីការ ក្នុងអំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះទេ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិនៅពេលផុតអំឡុងពេលសម្រាប់ស្វីការ ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្វីការនោះ សំណើនោះក៏ត្រូវបាត់បង់អានុភាពដែរ ។

**មាត្រា ៣៣៩.–** សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ

១-ចំពោះសំណើដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការរវាងគូភាគីដែលកំពុងនិយាយគ្នា នៅក្នុងស្ថានភាពដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព ។

២-ចំពោះសំណើដែលធ្វើរវាងគូភាគីដែលមិននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ ។

៣-ការដកសំណើត្រូវមានអានុភាព លុះត្រាតែការជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្វីការ ។

**មាត្រា ៣៤០.–** ពេលនៃការបង្កើតកិច្ចសន្យា : គោលការណ៍នៃការមកដល់នៃស្វីការ

កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលដំណឹងអំពីស្វីការបានមកដល់អ្នកស្នើ ។

**មាត្រា ៣៤១.–** ការមកដល់យឺតយ៉ាវនៃស្វីការ

១-ក្នុងករណីដែលការជូនដំណឹងអំពីស្វីការ ចំពោះសំណើដែលមានអំឡុងពេល

សម្រាប់ស្ទីការ មកដល់ភាគីម្ខាងទៀត ក្រោយពេលអំឡុងពេលសម្រាប់ស្ទីការនោះកន្លងផុត ប្រសិនបើអ្នកស្នើស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងថា ភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការនោះ នៅពេលដែលអាចមកដល់ក្នុងអំឡុងពេលសម្រាប់ស្ទីការក្នុងករណីធម្មតា នោះអ្នកស្នើត្រូវជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ទៅអ្នកធ្វើស្ទីការ ដោយគ្មានការយឺតយ៉ាវ ។ ក្នុងករណីដែលអ្នកស្នើធ្វេសប្រហែសក្នុងការជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ស្ទីការដែលមកដល់ដោយមានការយឺតយ៉ាវនោះ មានសុពលភាព ។

២-អ្នកស្នើ អាចចាត់ទុកថា ស្ទីការដែលបានមកដល់អ្នកស្នើក្រោយពេលផុតអំឡុងពេលសម្រាប់ស្ទីការ ជាសំណើថ្មី ។

**មាត្រា ៣៤២.–** ស្ទីការដោយមានបន្ថែមការកែប្រែ

១-ស្ទីការដែលអ្នកធ្វើស្ទីការបានដាក់ល័ក្ខខ័ណ្ឌលើសំណើ ឬ កែប្រែសារធាតុផ្សេងនៃសំណើ មិនត្រូវក្លាយជាស្ទីការសុពល តែស្ទីការនោះមានអានុភាពជាសំណើថ្មី ។ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើម ធ្វើស្ទីការចំពោះសំណើថ្មីនោះ ។

២-ប្រសិនបើល័ក្ខខ័ណ្ឌ ឬ ការកែប្រែដែលភ្ជាប់ជាមួយនឹងស្ទីការមិនធ្វើឱ្យមានការកែប្រែសារធាតុនៃសំណើទេ ស្ទីការនោះមានសុពលភាព លុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាម ។ អត្ថន័យនៃកិច្ចសន្យាដែលត្រូវកើតឡើងដោយស្ទីការនោះ ត្រូវទៅតាមអត្ថន័យនៃស្ទីការ លុះត្រាតែអ្នកស្នើដែលបានទទួលស្ទីការមិនតវ៉ាភ្លាមៗទេ ។

**មាត្រា ៣៤៣.–** ការបង្កើតកិច្ចសន្យាដោយសកម្មភាពដែលត្រូវបានចាត់ទុកថាជាស្ទីការ

ក្នុងករណីដែលមិនចាំបាច់ឱ្យមានដំណឹងអំពីស្ទីការ ដោយសារឆន្ទៈរបស់អ្នកស្នើ ឬ ដោយសារទំនៀមទម្លាប់នៃកិច្ចការជំនួញ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលមានសកម្មភាពអាចទទួលស្គាល់ថាជាស្ទីការ ។

**មាត្រា ៣៤៤.–** ការដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់

សំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់តាមការផ្សាយជាសាធារណៈ

ឬ តាមវិធីផ្សេងទៀត អាចដកបានតែតាមវិធីដូចគ្នានឹងសំណើនោះ ។

## ផ្នែកទី ២
## វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា

**មាត្រា ៣៤៥.–** ការបង្ហាញឆន្ទៈដែលមានវិការៈ

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ តាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) នេះ និង ផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ :

ក-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ។

ខ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។

គ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ ។

**មាត្រា ៣៤៦.–** ការភាន់ច្រឡំ

១-ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៣-ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៤-ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៧.–** ការឆបោក

១-បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ ។

៣-ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៨.–** ព័ត៌មានមិនពិត

១-នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមាន

វិការៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស ។

៣-ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៩.-** ការរំលោភបំពានលើស្ថានភាព

១-នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ ។

**មាត្រា ៣៥០.-** ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥១.-** អំពើកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយ

បានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥២.-** ថបនីយផ្លូវចិត្ត

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ។

**មាត្រា ៣៥៣.-** ការបង្ហាញឆន្ទៈមិនពិត

១-កិច្ចសន្យា ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ ។

២-មោឃភាពនៃកិច្ចសន្យាដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬ មិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ ។

**មាត្រា ៣៥៤.-** ភាពខុសច្បាប់ ឬ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ក្នុងអត្ថន័យនៃកិច្ចសន្យា

១-ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈ ក្នុងករណីខាងក្រោមនេះ :

ក-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ។

ខ-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។

២-ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិដែល

អនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងទៀត ក៏មិនធ្វើឱ្យខូចសេចក្ដីសង្ឃឹមសមហេតុសមផលរបស់គូភាគីទេ នោះមានតែចំណុចដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អតែប៉ុណ្ណោះទេ ដែលត្រូវទុកជាមោឃៈ ។

**មាត្រា ៣៥៥.–** អលទ្ធភាពតាំងពីដំបូង

១-ទោះបីជាអត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចបានតាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះមិនត្រូវបានចាត់ទុកជាមោឃៈដោយយកមូលហេតុនៃអលទ្ធភាពនោះដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងភាគីក្នុងការលុបចោលនូវកិច្ចសន្យាដោយយកមូលហេតុនៃការភាន់ច្រឡំឡើយ ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំត្រូវបានបំពេញ ។

២-ក្នុងករណីដែលភាគីដែលគួរតែអាចដឹងថា អត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចតាំងពីដំបូងបាន នាំឱ្យមានការខូចខាតដល់ភាគីម្ខាងទៀតដោយសារការបង្កើតកិច្ចសន្យា ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់ភាគីម្ខាងទៀត ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៣៩៨ (ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត) នៃក្រមនេះ ។

## ផ្នែកទី ៣
## មោឃភាព និង ការលុបចោល

**មាត្រា ៣៥៦.–** និយមន័យនៃសកម្មភាព

ពាក្យ “សកម្មភាព” ក្នុងផ្នែកទី ៣ (មោឃភាព និង ការលុបចោល) នេះ សំដៅទៅលើកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី ។

ឬ ឱ្យរំលាយកិច្ចសន្យាទេ ។ ក្នុងករណីដែលម្ចាស់បំណុលរំលាយកិច្ចសន្យា ហើយទាមទារសំណងនៃការខូចខាតដែលជាការជំនួសកម្មវត្ថុនៃកិច្ចសន្យា ចំនួនទឹកប្រាក់នៃសំណងដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នាដោយគិតជាមុន អំពីការខូចខាតដែលកើតឡើងដោយការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចនោះ មិនត្រូវចងគូភាគីទេ ។

៥-ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ត្រូវសន្មតថាជាការកំណត់ជាមុននូវចំនួននៃសំណង ។

**មាត្រា ៤០៤.–** គោលការណ៍នៃការសងការខូចខាតជាប្រាក់

ចំពោះសំណងនៃការខូចខាតដែលកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច កូនបំណុលត្រូវសងជាប្រាក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីទាំងសងខាងបានកំណត់ផ្សេងពីនេះដោយការសន្យាពិសេស ។

**មាត្រា ៤០៥.–** ឧបាទេសកម្មនៃអ្នកសង

ប្រសិនបើម្ចាស់បំណុលបានទទួលនូវសំណងនៃការខូចខាតដោយការសងតម្លៃនៃវត្ថុ ឬ សិទ្ធិដែលជាអត្ថន័យនៃសិទ្ធិលើបំណុល កូនបំណុលត្រូវទទួលឋានៈដែលម្ចាស់បំណុលធ្លាប់មានចំពោះវត្ថុ ឬ សិទ្ធិនោះ ដោយស្វ័យប្រវត្តិ ។

**មាត្រា ៤០៦.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណង

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យសងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលការខូចខាតនោះកើតឡើង ។

## ផ្នែកទី ៤
## ការរំលាយកិច្ចសន្យា

**មាត្រា ៤០៧.–** ការរំលាយដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច

ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។

**មាត្រា ៤០៨.-** ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ

១-ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត ។ ត្រូវចាត់ទុកថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដូចខាងក្រោមនេះ :

ក- ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ ដោយកំណត់អំឡុងពេលសមរម្យដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ ។

ខ-ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ ។

គ-ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ ។

ឃ-ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន ។

២-ភាគីដែលបំពានកិច្ចសន្យា មិនអាចរារាំងការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ដោយយកមូលហេតុថាខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន បានឡើយ ។

**មាត្រា ៤០៩.-** វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា

១-ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន ។ ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន ។

២-ការបង្ហាញឆន្ទៈរំលាយនេះ មិនអាចដកវិញបានទេ ។

៣-ការបង្ហាញឆន្ទៈរំលាយនេះ អាចដាក់ល័ក្ខខ័ណ្ឌបង្អង់បាន ។

**មាត្រា ៤១០.-** ការរំលាយកិច្ចសន្យាដែលភាគីម្ខាងមានច្រើននាក់

១-ក្នុងករណីដែលភាគីម្ខាងមានច្រើននាក់ ការរំលាយកិច្ចសន្យាត្រូវធ្វើឡើងដោយ

បុគ្គលទាំងអស់នោះចំពោះភាគីម្ខាងទៀត ឬ ដោយភាគីម្ខាងទៀតចំពោះបុគ្គលទាំងអស់នោះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើសិទ្ធិរំលាយកិច្ចសន្យាបានរលត់ចំពោះបុគ្គលណាម្នាក់ ក្នុងចំណោមបុគ្គលនៃភាគីដែលមានច្រើននាក់ សិទ្ធិរំលាយនោះក៏ត្រូវរលត់ចំពោះបុគ្គលផ្សេងទៀតនៃភាគីនោះដែរ ។

**មាត្រា ៤១១.-** អានុភាពនៃការរំលាយកិច្ចសន្យា

១-ការរំលាយកិច្ចសន្យានាំឱ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត ។

២-ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីនោះទទួលបដិទានឡើងវិញ ដោយសារការរំលាយ ។ ក្នុងករណីដែលភាគីទាំងសងខាង មានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា ។

៣-ភាគីដែលមានករណីយកិច្ចសងជាប្រាក់ដោយការរំលាយកិច្ចសន្យា ត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានទទួលប្រាក់ដើមនោះ ។ ភាគីដែលមានករណីយកិច្ចបង្វិលជាវត្ថុ ឬ ជាតាវកាលិកផ្សេងដែលខ្លួនបានទទួល ទៅភាគីម្ខាងទៀតដោយសារការរំលាយ ត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬ តាវកាលិកនោះផងដែរ ។

៤-ការរំលាយកិច្ចសន្យាមិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ ។

**មាត្រា ៤១២.-** សិទ្ធិរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់

១-សិទ្ធិរំលាយត្រូវរលត់ ក្នុងករណីភាគីដែលមានសិទ្ធិរំលាយបានធ្វើឱ្យមានការខូចខាត ឬ ការបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬ មិនអាចសងវត្ថុនោះវិញបានដោយចេតនា ឬ ធ្វើឱ្យវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេង ដោយការកែច្នៃ ឬ ការផ្លាស់ទម្រង់ដោយចេតនា ។

២-ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ បើភាគីបានអនុវត្តសិទ្ធិរំលាយ ភាគីនោះត្រូវសងជាប្រាក់នូវតម្លៃនៃវត្ថុដែលជាកម្មវត្ថុនោះ ត្រឹមកម្រិតតម្លៃដែលបានកំណត់ក្នុងកិច្ចសន្យា ។

៣-ក្នុងករណីដែលភាគីម្ខាងទៀតមានកំហុស ឬ មានមូលហេតុក្នុងការខូចខាត ឬ ការមិនបានសងវត្ថុដែលជាកម្មវត្ថុនោះ ភាគីដែលមានសិទ្ធិរំលាយ គ្មានករណីយកិច្ចក្នុងការសងជាប្រាក់នូវតម្លៃនៃវត្ថុនោះ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះឡើយ ។

**មាត្រា ៤១៣.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និង សិទ្ធិទាមទារបដិទាន មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច ។

**មាត្រា ៤១៤.-** សិទ្ធិរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និង ការរំលាយដោយការព្រមព្រៀងគ្នា

១-គូភាគីនៃកិច្ចសន្យាអាចសន្យាឱ្យភាគីម្ខាង ឬ សងខាងមានសិទ្ធិរំលាយ នៅក្នុងកិច្ចសន្យានោះបាន ។ បញ្ញត្តិពីមាត្រា ៤០៩ (វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា) ដល់មាត្រា ៤១២ (សិទ្ធិរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់) នៃក្រមនេះ ស្តីពីការរំលាយដែលច្បាប់បានកំណត់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះវិធីអនុវត្ត និង អានុភាពនៃសិទ្ធិរំលាយ ដែលបានកំណត់ដោយកិច្ចសន្យា លើកលែងតែមានការព្រមព្រៀងគ្នាផ្សេង ។

២-ទោះបីជាគ្មានការកំណត់សិទ្ធិរំលាយក្នុងកិច្ចសន្យាក៏ដោយ ក៏គូភាគីអាចរំលាយកិច្ចសន្យាដោយការព្រមព្រៀងគ្នាបានដែរ ។ ប៉ុន្តែ ការរំលាយនោះមិនអាចធ្វើឱ្យខូចផលប្រយោជន៍របស់តតិយជនបានទេ ។